ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 10-Apr-2012, 14:08
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៥៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក រ៉ូជ័រ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក សេង ប៊ុនឃាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក វ៉េង ហ៊ត់

លោក ប៉ាក ចន្ទលីណូ

លោក ពេជ្រ សម្បត្តិ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រីនណា

លោកស្រី ជេត វណ្ណលី

លោក ឡោ ជុនធី

កញ្ញា លី ម៉ាញៀន *(Ms.Lyma NGUYEN)*

លោកស្រី ម៉ារី ហ្គីរ៉ូដ *(Marie GUIRAUD)*

លោក បាណាបេ ណេគ្វី *(Mr. Barnabé NEKUIE)*

លោក អេម៉ានូអែល ហ្សាកូមី
*(Ms.Emanuel JACOMY)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| កញ្ញា លី ម៉ាញៀន | អង់គ្លេស |
| លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅលោក ÷ កាំង ហ្កេកអ៊ាវ ហៅ ឌុច

សួរដោយលោក ម៉ៃខល កាណាវាស ផ្តើមពី៖ ............................................................ ទំព័រ០១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការតាមកាលវិភាគដែលបានគ្រោងទុក។ ថ្ងៃនេះគឺជាថ្ងៃដែលក្រុមមេធាវីការពារក្ដីលោក អៀង សារី មានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច។ មុននឹងផ្ដល់វេទិកាទៅ អង្គជំនុំជម្រះក៏សូមជម្រាបជូនភាគីផងដែរថា ថ្ងៃនេះលោកចៅក្រម ហ្សង់ម៉ាក បានមានសុខភាពល្អឡើងវិញ ហើយបានមានវត្តមាន និងមានលទ្ធភាពចូលរួមក្នុងកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងវិញបានហើយ។

ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី ដើម្បីអាចមានលទ្ធភាពតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

[០៩:០២:៥៨]

**លោក ម៉ៃខល កាណាវាស៖**

អរគុណសួស្ដីលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់ ព្រមទាំងប្រិយមិត្តទាំងអស់ដែលនៅជុំវិញសាលសវនាការ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ជាដំបូង ខ្ញុំសូមចោទសួរលោកនូវសំណួរទូទៅមួយចំនួន ហើយបន្ទាប់មកយើងនឹងឈានទៅពិនិត្យទៅលើឯកសារមួយចំនួនដែលជាប្រធានបទមួយដ៏សំខាន់។ ហើយខ្ញុំរៀបចំជាឯកសារបែបអេឡិចត្រូនិក ហើយយើងខ្ញុំក៏បានគូសនូវចំណុចដែលយើងខ្ញុំចង់ចោទសួរទៅលោកផងដែរ។ ដូច្នេះ យើងសូមចាប់ផ្ដើមជាមួយរយៈពេលដែលលោកធ្វើការនៅមន្ទីរស-២១។ តាមដែលខ្ញុំដឹង សកម្មភាពរបស់លោកនៅពេលនោះ គឺថាមានកម្រិតកំណត់ត្រឹមតែតួនាទីរបស់លោកនៅមន្ទីរស-២១។ តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន សម្ដីរបស់លោកមេធាវីត្រឹមត្រូវហើយ។

**សៈ** ហើយការផ្លាស់ទីរបស់លោកក៏មានកម្រិតកំណត់ផងដែរ តើមែនដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកប្រធាន ការផ្លាស់ទីនេះ បើសំដៅត្រឹមតែការដើរហើរពិតប្រាកដ ជាត្រូវមានកំណត់មែន មានព្រំដែនកំណត់មែន។

**សៈ** ហើយបើតាមដែលលោកដឹង អាការដើរហើរហ្នឹងក៏វាមាន-- ហើយការដឹងរបស់លោកហ្នឹងក៏មានការកម្រិតកំណត់ផងដែរ។ បានន័យថា ការយល់របស់លោកទាក់ទងសកម្មភាពនានា ក៏មានកម្រិតកំណត់ផងដែរ។ តើមែនទេ?

**ឆៈ** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ពិតជាមានកម្រិតមួយជាកំណត់។

**សៈ** គេប្រាប់ខ្ញុំថា អត់មានការបកប្រែជាភាសាបារាំងទេ។ ដូច្នេះ ខ្ញុំសូមចោទសំណួរឡើងវិញ ដើម្បីទទួលបានការបកប្រែ។ ហើយខ្ញុំចោទសួរលោកថា តើការយល់ដឹងរបស់លោកក៏មានការកម្រិតកំណត់ដែរ? តើមែនដែរឬទេ? សូមលោកឆ្លើយឡើងវិញម្តងទៀត។ សូមអរគុណ។

[០៩:០៥:៤៧]

**ឆៈ** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ការយល់ដឹងរបស់ខ្ញុំក៏នៅមានកំណត់ដែរ។

**សៈ** តាមដែលខ្ញុំដឹង តើយល់ដឹងរបស់លោក គឺមានលក្ខណៈថាកម្រិតមធ្យម ព្រោះលោកជាមន្ត្រីកម្រិតមធ្យម មិនមែនកម្រិតខ្ពស់បំផុត ហើយក៏មិនមែនកម្រិតទាបបំផុតដែរ។ តើត្រឹមត្រូវដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកប្រធាន ត្រឹមត្រូវហើយ។

**សៈ** ហើយតាមរយៈការស្តាប់សក្ខីកម្មរបស់លោក គឺខ្ញុំអាចនិយាយបានថា លោកគ្រប់ពេលទាំងអស់ គឺថាព្យាយាមដើម្បីឲ្យទទួលបាននូវអ្វីដែលរំពឹងចង់បាន។

**លោក កាំង ហ្កេកអ៊ាវ៖**

ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមបញ្ជាក់មួយម៉ាត់ទៅលោកមេធាវី។ តើលោកចង់និយាយពីអ្នកណារំពឹងចង់បាន? នេះសូមលោកប្រធានឲ្យលោកមេធាវីបញ្ជាក់ឲ្យច្បាស់។

[០៩:០៧:១៥]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី បែបទំនងជាសាក្សីស្តាប់សំណួររបស់លោកមិនយល់ទេ។ អ៊ីចឹងសូមលោកតាំងសំណួរចុងក្រោយអម្បាញ់មិញឲ្យបានជាក់ច្បាស់សាជាថ្មីម្តងទៀត ដើម្បីឲ្យសាក្សីស្តាប់យល់ ឬមួយ

អាចមកពីការបកប្រែ ឬមួយមកពីជម្រៅនៃបច្ចេកទេសក្នុងការតាំងសំណួរ ដែលរហូតដល់សាក្សីយល់មិនយល់ យល់មិនបាននូវការតាំងសំណួររបស់លោក។

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ខ្ញុំនិយាយអំពីអាកប្បកិរិយាជាទូទៅ ជារួមរបស់លោក គឺបានន័យថាលោកព្យាយាមបញ្ចេញអាកប្បកិរិយាឲ្យស្រប ឲ្យត្រឹមត្រូវទៅច្បាប់ តាមទម្លាប់។ តើមែនដែរឬទេ?

[០៩:០៨:០៧]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន អាកប្បកិរិយារបស់ខ្ញុំនៅក្នុងអង្គសវនាការនេះគឺខំពុះពាររកយល់ ដើម្បីនឹងឆ្លើយតាមសំណូមពររបស់អង្គជំនុំជម្រះ។ នេះគឺខ្ញុំមាន ពិតជាមានគោលគំនិតអ៊ីចឹងមួយមែន។

**ស៖** ប្រហែលជាមានការខុសបន្តិចបន្តួចនៅក្នុងការបកប្រែ។ ការពិតខ្ញុំចង់និយាយពីការបំពេញការងារ គឺការគោរពច្បាប់នៅសម័យកម្ពុជាប្រជាធិបតេយ្យ គឺនៅសម័យស-២១។ តើការបំពេញការងាររបស់លោកនោះ វាត្រឹមត្រូវតាមក្រឹត្យក្រមនៅពេលនោះដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បើនិយាយអំពីការពុះពារនៅពេលនោះ គឺពិតជាខំធ្វើម៉េចឲ្យត្រឹមត្រូវតាមមាគ៌ា ហើយនិងការណែនាំជាបន្តបន្ទាប់របស់ខាងលើ។ មាគ៌ានេះ គឺសំដៅមាគ៌ាបក្ស។ ការណែនាំជាបន្តបន្ទាប់របស់ខាងលើ គឺការណែនាំរបស់ សុន សេន ដល់ក្រោយមកការណែនាំរបស់ បងនួន គឺលោក នួន ជា នេះ។

[០៩:០៩:២៨]

**ស៖** សូមអរគុណ។ ហើយខ្ញុំគិតថា តាមរយៈអ្វីដែលបានស្តាប់ឮ គឺលោកបានប្រាប់សហចៅក្រមស៊ើបអង្កេតដូចដែលលោកបានប្រាប់នៅទីនេះថា នៅពេលនោះកម្រិតនៃការភ័យខ្លាច គឺមានការខ្ពស់ កម្រិតនៃការភ័យខ្លាច គឺខ្ពស់នៅពេលនោះ នៅសម័យនោះ។ តើមែនដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន កម្រិតនៃការភ័យខ្លាចរបស់ខ្ញុំខ្ពស់មែន។ ចាប់ផ្តើមខ្ពស់មែនទែន ចាប់តាំងពីបក្សសម្រេចចាប់ ង៉ែត យូ ហៅ ហុង អនុប្រធានគណៈកម្មាធិការពាណិជ្ជកម្មមក

មន្ទីរស-២១។ ហើយរហូតដល់តក់ស្លុតបំផុត នៅពេលដែលបងនួន ឲ្យកម្មេចបង្ហើយ ជនរងគ្រោះដែលទៅជាប់ទោសទៅទីនោះ នៅថ្ងៃទី១ ខែមករា ១៩៧៩។ តក់ស្លុតរហូតធ្វើអីលែងកើត លែងប៊ានចេញពីផ្ទះ។ នេះ ខ្ញុំសូមបញ្ចប់ប៉ុណ្ណោះ។

**ស៖** សូមអរគុណលោក ហើយខ្ញុំគិតថា ដោយសារតែការភ័យខ្លាច ការភ័យខ្លាចនេះ គឺជាហេតុផលមួយដែលលោកព្យាយាមមិនធ្វើអ្វីដើម្បីឲ្យមានការសង្ស័យ ដើម្បី បានន័យថា លោកព្យាយាមមិនធ្វើឲ្យមានការសង្ស័យដែលអាចនាំទៅដល់ការចាប់ខ្លួនរបស់លោក។ តើមែនដែរឬទេ?

[០៩:១១:២៦]

**ឆ៖** អរគុណ។ ពិតជាមែន។

**ស៖** ឥឡូវយើងពិនិត្យមើលអំពីការសារភាព គឺថាមានមធ្យោបាយ ឬក៏វិធានការថ្មីៗដើម្បីទទួលបាននូវចម្លើយភាព។ លោកព្យាយាមប្រើប្រាស់នូវសមត្ថភាព ឲ្យអស់ពីសមត្ថភាពដើម្បីធានថា ចម្លើយសារភាពនោះ ទទួលនូវព័ត៌មានដូចដែលបានបញ្ជា ដូចដែលបានណែនាំពីខាងលើ។ តើមែនដែរឬទេ?

[០៩:១២:០៧]

**ឆ៖** អរគុណ។ ការងាររបស់ខ្ញុំ ហើយគឺដឹកនាំអង្គភាពនេះ ពុះពារធ្វើម៉េចចង់ឲ្យបានចម្លើយភាពមួយដែលស្របបង្គួរទៅតាមរឿងសត្យានុម័ត។ នេះគឺពិតជាប្រឹងប្រែងអ៊ីចឹងមែន។

**ស៖** អរគុណ។ ដូច្នេះ ដូចដែលលោកចូលរួមនៅទីនេះ គឺថាលោកមិនចង់និយាយថា ចម្លើយសារភាពមានគោលដៅបង្ហាញនូវការពិត តើមែនដែរឬទេ? លោកមិនមែនចង់និយាយថា ចម្លើយសារភាពហ្នឹង មិនប្រាប់នូវការពិត។ តើមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ថ្ងៃមុន ខ្ញុំបានបញ្ជាក់ហើយ ខ្ញុំមិនដែលទទួលស្គាល់ស្អីថាពិតទាំងស្រុង ហើយស្អីក៏មិនពិតទាំងស្រុងដែរ។ សូមជូនឧទាហរណ៍ជាក់ស្តែងមួយ បើលោកមេធាវីអនុញ្ញាត។

**ស៖** អរគុណ។ ប្រសិនបើលោកមិនប្រកាន់ ខ្ញុំមិនចង់ស្តាប់អំពីចម្លើយជាក់លាក់មួយណានោះទេ ខ្ញុំគ្រាន់តែចង់ដឹងជាទូទៅ។ ដូច្នេះ ខ្ញុំសូមទោស ដែលខ្ញុំរំខាន កាត់លោក។ ឥឡូវ យើងបន្តមួយដំណាក់កាលម្តងៗ។ ឲ្យខ្ញុំសូមរៀប-- ចាប់ផ្តើមដូចតទៅ៖ លោកដឹងច្បាស់ថា ចម្លើយសារភាពនុំង គឺអ្វីដែលអាចចាត់ទុកថាជាការកុហក អ្វីដែលៗយើងគិតថាជាការភូតកុហក។ តើត្រឹមត្រូវដែរឬទេ?

[០៩:១៤:១០]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ចម្លើយសារភាព ដូចខ្ញុំបាននិយាយហើយអ៊ីចឹង យើងមិនអាចសន្មតទុកថា ជាការភូតកុហកទាំងស្រុង ហើយក៏មិនអាចសន្និដ្ឋានបានថាជាការពិតទាំងងស្រុងដែរ។

**ស៖** ខ្ញុំយល់ស្រប។ អ្វីដែលខ្ញុំចង់និយាយ មិនមែនបានន័យថា ខ្ញុំព្យាយាមសម្រេច ឬក៏កំណត់ទេ ប៉ុន្តែយើងអាចនិយាយបានថា មានបុគ្គលមួយចំនួនដែលគេជម្រាបលោក បានន័យថា គេប្រាប់លោកជាមុន ថាតើគេចង់បានអ្វីនៅក្នុងចម្លើយសារភាពរបស់បុគ្គលទាំងនោះ។ តើមែនដែរឬទេ?

[០៩:១៥:១៥]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ជាគោលការណ៍ មនុស្សដែលបក្សចាប់គឺបក្សកំណត់ថាជាខ្មាំង។ ដូច្នេះស-២១ ត្រូវពុះពារធ្វើម៉េចឲ្យមនុស្សនោះទទួលស្គាល់ថាខ្លួនឯងបានប្រព្រឹត្តខុស ធ្លាក់ទៅក្នុងពិរុទ្ធភាពជាខ្មាំងដែលបក្សសង្ស័យ ហើយសម្រេចចាប់ខ្លួន។ នេះជាបញ្ហាទូទៅដែលមានស-២១ ជាពិសេស គ្រប់មន្ទីរនគរបាលគិតជារួម។

**ស៖** ហើយផ្នែកមួយចំនួននៃព័ត៌មាននេះគឺដើម្បីធ្វើឲ្យបុគ្គលមួយចំនួនទទួលស្គាល់ថា ខ្លួនហ្នឹងគឺជាភ្នាក់ងារ សេ.អ៊ី.អា ជាភ្នាក់ងារ កា.ហ្សេ.បេ ឬក៏ស្ថិតក្រោមឥទ្ធិពលរបស់វៀតណាម។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្មាំងដែលបក្សកំណត់ថាជាសត្រូវស្លាប់រស់ត្រូវតែចាប់មកកម្ទេចចាប់ សួរចម្លើយហើយកម្ទេច មានបីប្រភេទហ្នឹងឯង។ ទីមួយ គឺភ្នាក់ងារ សេ.អ៊ី.អា។ ទីពីរ គឺភ្នាក់ងារ កា.ហ្សេ.បេ ហើយទីបី គឺភ្នាក់ងារយួនវៀតទី លេបទឹកដី ប្រល័យពូជសាសន៍។ នេះតាមភាសាដែលបក្សកំណត់ជាផ្លូវការ និងជាសាធារណៈ។

[០៩:១៧:០៣]

**ស៖** ដូច្នេះវាជាតួនាទីរបស់លោក ជាកាតព្វកិច្ចរបស់លោកដើម្បីធ្វើឲ្យប្រាកដថា នៅក្នុងចម្លើយសារភាពរបស់ពួកគេទាំងនោះ គឺមាននូវព័ត៌មានដែលបង្ហាញថា បុគ្គលទាំងនោះទទួលស្គាល់ថាគាត់បន្ទាប់ពីត្រូវបានគេធ្វើទារុណកម្ម និងចោទសួរ ហើយបានសារភាពថា ពួកគាត់បានចូលរួមនៅក្នុងសកម្មភាពក្បត់ សកម្មភាពខ្មាំងទាំងនោះ។ តើមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន និយាយត្រឹមតែថាពួកអ្នកដែលចាប់ចងយកមក ហើយចូលស-២១ ពុះពារធ្វើម៉េចសួរចម្លើយឲ្យឃើញថាខ្លួនបានប្រព្រឹត្តខុស។ នេះទីមួយ។ អាហ្នឹងបញ្ហា

ច្បាស់លាស់ហើយ តើខុសហ្នឹងស្ថិតក្នុងប្រភេទណា? អានេះទីពីរ ប្រភេទ សេ.អ៊ី.អា ប្រភេទ កា.ហ្សេ.បេ ឬក៏ប្រភេទភ្នាក់ងារយួន? នេះក៏ដើរច្បាស់ទៅអ៊ីចឹង។

[០៩:១៨:២៨]

**ស៖** លោកសាក្សី ខ្ញុំមិនព្យាយាមនិយាយអ្វីឲ្យខ្លាំងក្លាទេ ប៉ុន្តែអ្វីដែលលោកព្យាយាម គឺថា តាមរយៈការជួយរបស់លោក គឺថាលោកព្យាយាមប្រើប្រាស់ការធ្វើទារុណកម្មដើម្បីទទួលបានចម្លើយពីអ្នកទទួលរងការធ្វើទារុណកម្មដើម្បីឲ្យអ្នកទាំងនោះសារភាព ឬក៏និយាយដោយកុហកថា ពួកគេគឺជាភ្នាក់ងារ សេ.អ៊ី.អា, កា.ហ្សេ.បេ ឬក៏ជាភ្នាក់ងារយួន។ តើមែនដែរឬទេ? សូមលោកឆ្លើយថា បាទ ឬក៏មិនមែនទេ។

**ឆ៖** អរគុណ។ ការសួរចម្លើយទារុណកម្មជាវិធានការចុងក្រោយគេ ទិសដែលចង់បាន គឺពិតជាចង់ឲ្យគេសារភាព ក៏ប៉ុន្តែទារុណកម្មគឺជាទិសចុងក្រោយ។ វិធានការចុងក្រោយដែលដោះស្រាយតាមការត្រជាក់មិនបាន។ នេះខ្ញុំសូមបញ្ជាក់ពីរមាត់អ៊ីចឹង។

**ស៖** ខ្ញុំសូមបញ្ជាក់លោកឲ្យច្បាស់ ខ្ញុំចង់ឲ្យលោកឆ្លើយ។ បានន័យថា ខ្ញុំសួរសំណួរដោយផ្ទាល់ តើលោកចង់ឲ្យអ្នកដែលត្រូវធ្វើទារុណកម្ម ឬក៏អ្នកដែលមិនទាន់ធ្វើទារុណកម្ម តើលោកចង់ឲ្យពួកគេនិយាយកុហកអំពីសកម្មភាពដែលពាក់ព័ន្ធជាមួយនឹងពួកខ្មាំងហ្នឹង។ សូមលោកឆ្លើយថា មែន ឬក៏មិនមែនបានហើយ។ គឺខ្ញុំចង់បានតែប៉ុណ្ណេះទេ។ សូមអរគុណ។

[០៩:២០:១៤]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន សំណួរនេះខ្ញុំឆ្លើយមិនបានទេ។ សំណួរបែបបិទមុខអ៊ីចឹង។

**ស៖** អ៊ីចឹងខ្ញុំបន្តទៅសំណួរបន្ទាប់។ តើលោកធ្លាប់មានបុគ្គលណាមួយដែលចោទសួរហើយៗបន្ទាប់មកធ្វើទារុណកម្ម ហើយឲ្យពួកគាត់សរសេរនូវចម្លើយសារភាពជាថ្មី ម្តងហើយម្តងទៀតៗ ដើម្បីទទួលបាននូវចម្លើយសារភាពដែលត្រឹមត្រូវ ដូចដែលចង់បាន។ តើមែន ឬក៏មិនមែន?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ការដែលឲ្យអ្នកជាប់ទោសសរសេរចម្លើយសារភាពម្តងហើយម្តងទៀត "មាន"។ ជាក់ស្តែង កុយ ធួន។

**ស៖** ហើយគោលដៅនៃការសរសេរឡើងវិញម្តងហើយម្តងទៀតហ្នឹង គឺព្រោះថាដើម្បីឲ្យពួកគាត់ហ្នឹងនិយាយកុហក គឺតើមែនដែរឬទេ? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ការដែលឲ្យសរសេរម្តងហើយម្តងទៀត មិនមែនមាន

ទិសដៅឲ្យពួកនោះនិយាយកុហកទេ គឺឲ្យពួកនោះសរសេរឲ្យច្បាស់។ ដោយឡែកចម្លើយ កុយ ធួន ខាងលើបញ្ហា។ ខាងលើបញ្ហាឲ្យសរសេរម្តងហើយម្តងទៀត។ បួនលើក។ ដូច្នេះ សូមបញ្ជាក់ថា ការដែលយើងខ្ញុំឲ្យសរសេរម្តងហើយម្តងទៀតនេះ មិនមែនបានន័យថា ជំរុញឲ្យគេកុហកទេ។

[០៩:២២:៣៩]

**ស៖** ឥឡូវដូច្នេះតាមដែលខ្ញុំយល់ គឺថា តួនាទីរបស់លោក គឺពិនិត្យមើលទៅលើចម្លើយសារភាពទាំងនោះដោយប្រុងប្រយ័ត្នមុនពេលនឹងបញ្ជូនចម្លើយសារភាពនោះទៅ សុន សេន។ ហើយលោកនឹងទទួលបញ្ជាពី សុន សេន ហើយដើម្បីបញ្ជាក់អំពីចំណុចដែលត្រូវបញ្ជាក់។ តើមែនដែរឬទេ?

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក!

**លោក វីល្លៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ភាគីទាំងអស់គ្នា ព្រមទាំងប្រិយមិត្តទាំងអស់។ ដំណាក់កាលនេះ គឺមិនមែនជាការពិនិត្យភស្តុតាងរបស់សាក្សីនោះទេ គឺថាការបញ្ជូនចម្លើយសារភាពទៅ សុន សេន ហ្នឹងគឺត្រឹមតែមួយ-- ត្រឹមតែពាក់កណ្តាលនោះទេ នៅពេលសល់គឺបញ្ជូនទៅ នួន ជា។ ដូច្នេះ អ្វីដែលគាត់ចោទសួរហ្នឹង គឺមិនមានជាលក្ខណៈឲ្យត្រឹមត្រូវឲ្យមួយរយភាគរយទេ។ ដូច្នេះ ស្នើឲ្យមេធាវី អៀង សារី គាត់ចោទសួរឲ្យបានត្រឹមត្រូវ។

[០៩:២៣:៥៥]

**សួរដោយលោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** ទោះបីថាលោកបញ្ជូនទៅសុន សេន ឬក៏នួន ជា ក៏ដោយ ប៉ុន្តែជាៗទូទៅ គឺលោកបញ្ជូនទៅ សុន សេន។ ដូច្នេះ គឺថាលោកបញ្ជូនទៅ ហើយនិងទទួលបានមកវិញនូវការបញ្ជាណែនាំ តើត្រឹមត្រូវដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ការបញ្ជូនចម្លើយទៅលើនេះ វាមានពីររយៈអ៊ីចឹងមែន។ មុន និងក្រោយថ្ងៃ១៥ សីហា ១៩៧៧។ ហើយការដែលបញ្ជូនទៅហើយ ជូនអ៊ីបង សុន សេន ឲ្យសួរ

ឡើងវិញ។ ជូនអីបង នួន ឲ្យគេមកបញ្ជាក់ពាក្យមួយម៉ាត់ ពីរម៉ាត់ ឬក៏មួយឃ្លា ឲ្យខ្ញុំបញ្ជាក់ទៅជូនគាត់ ព្រោះគាត់ស្ដាប់មិនបាន មិនច្បាស់។ នេះគឺមានបញ្ជាក់អ៊ីចឹងមែន។ ក៏ប៉ុន្តែចម្លើយខ្លះដូចជាអត់ទេ បញ្ជូនទៅស្ងាត់។ នេះក៏មានដែរ។

[០៩:២៥:០០]

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងសូមប្ដូរទៅប្រធានបទថ្មីមួយទៀត។ ហើយប្រធានបទនេះក៏គ្របដណ្ដប់ទៅលើអ្វីដែលលោកបានផ្ដល់សក្ខីកម្មព្រមទាំងចំណុចនោះ ប៉ុន្តែខ្ញុំសូមលើកនូវចំណុចមួយចំនួន។ បើតាមខ្ញុំយល់ គឺលោកមិនមានការទំនាក់ទំនងទៅវិញទៅមកជាមួយ ប៉ុល ពត ទេ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំគ្មានការទាក់ទងផ្ទាល់ជាមួយនឹង ប៉ុល ពត ទេ។

**ស៖** តាមពិតទៅ គឺថាសូម្បីតែក្នុងកិច្ចប្រជុំគឺលោកមិនដែលចូលរួមប្រជុំដែរ ក្នុងកិច្ចប្រជុំដែលមាន ប៉ុល ពត ជាប្រធានដែរ។ តើមែនដែរឬទេ?

[០៩:២៦:០៥]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បងប៉ុល ហើយនិង បងនួន ទៅដឹកនាំធ្វើមីទ្ទិង។ ហ្នឹងខ្ញុំមានពេលទៅចូលរួមមែន ប៉ុន្តែចម្ងាយប្រហែលជា១០ម៉ែត្រពីគ្នា។ ឯចំណែកអង្គុយទល់មុខមួយម៉ែត្រ ឬកន្លះម៉ែត្រ គ្មានទេ មានតែជាមួយ បងខៀវ សុន សេន, ហើយបន្ទាប់មកជាមួយ បងនួន គឺនួន ជា នេះ។

**ស៖** ថាតើវាជាវគ្គបណ្ដុះបណ្ដាល ឬក៏ជាការប្រជុំពិភាក្សា ដូចជាប្រជុំពិភាក្សាអំពីបញ្ហាសន្តិសុខជាដើម។ ថាតើជាបញ្ហាមួយណា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ការប្រជុំពិភាក្សានេះ គឺមីទ្ទិង "បុណ្យខួប ១៧មេសា" ហើយនិង "មីទ្ទិងបុណ្យខួប ៣០កញ្ញា"។ គឺមីទ្ទិងកំណើតបក្ស ហើយនិង--

[០៩:២៧:០៣]

**ស៖** សូមអរគុណ។ ខ្ញុំចង់និយាយអំពីកិច្ចប្រជុំ។ តើកិច្ចប្រជុំហ្នឹងពិភាក្សាអំពីបញ្ហាសំខាន់ៗ បញ្ហារសើបច្រើន។ តើលោកធ្លាប់ចូលរួមនៅក្នុងកិច្ចប្រជុំបែបនោះទេ? សូមលោកឆ្លើយថា ធ្លាប់ ឬក៏មិនធ្លាប់បានហើយ។ សូមអរគុណ។

**ផ៖** អរគុណ។ កិច្ចប្រជុំ គេហៅថា "ប្រជុំការងារ" ឬក៏ "ធ្វើការងារ" នោះ ខ្ញុំមិនដែលជួបមុខ ប៉ុល ពត ទេ។

[០៩:២៧:៣៦]

**ស៖** សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ឈប់! ឈប់សិនលោកមេធាវី!

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោក កាណាវាស លោកដឹងហើយថា លោកមិនអាចរារាំងសាក្សី មិនអាចរារាំងឲ្យគាត់ត្រឹមតែឆ្លើយ "បាទ" ឬក៏ "មិនមែន"។ ដូច្នេះសូមលោកឈប់ធ្វើសកម្មភាពបែប នេះ។ គឺថា ប្រសិនបើនេះលោកអាចដាក់ជាសំណួរសាមញ្ញៗ កុំដាក់សំណួរពិបាកៗ ព្រោះថាកន្លងមក នេះយើងសង្កេតឃើញថា លោកដាក់នូវសំណួរដែលមានជាច្រើនជាន់ ជាច្រើនចំណោទ។ ដូច្នេះហើយ ខ្ញុំសូមជម្រាបលោកថា ហើយលោកកុំនិយាយនៅមុនពេលដែលមីក្រូហ្វូនមិនទាន់បើក។

[០៩:២៨:៣០]

**លោក ម៉ៃខល កាណាវាស៖**

ការពិតទៅ ខ្ញុំមិនដឹងថា តើវាជាចម្លើយ "មែន" ឬក៏ "មិនមែន"។ ហើយខ្ញុំអត់ដឹងថា ចម្លើយ បែបនេះមិនអនុញ្ញាតឲ្យធ្វើនៅតុលាការ។ ប៉ុន្តែនៅពេលដែលអ្វីដែលខ្ញុំដឹងគឺថា មិនអាចសួរសំណួរនាំ មុខ ឬក៏សំណួរអីផ្សេង។ ដូច្នេះ ប្រហែលជាខ្ញុំទទួលយកដោយ-- ទទួលបាន។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

លោកអាចចោទសួរសំណួរ "មែន" ឬក៏ "មិនមែន" ប៉ុន្តែលោកមិនអាចរារាំងសាក្សី ឬក៏មិន អាចតម្រូវឲ្យសាក្សីឆ្លើយ "មែន" ឬក៏ "មិនមែន" នោះទេ។ លោកអាចចោទជាសំណួរ។

**អ្នកបកប្រែ៖**

លោកៗប្រធាន សូមជម្រាបដល់មេធាវី កុំឲ្យគាត់នេះនិយាយលឿនពេក ទុកឱកាសឲ្យអ្នកបក ប្រែ ដើម្បីតាមទាន់ផង។

**លោក ម៉ៃខល កាណាវ៉ាស៖**

ដូច្នេះហើយគឺថា មិន-- ដែលៗ នេះគឺជាអ្វីដែលមិនអាចចោទសួរបាន។ បញ្ហាដែលសំខាន់គឺថាការចោទសំណួរនាំមុខ ឬក៏សំណួរបើក គឺយើងមិនរារាំងសាក្សីនោះទេ។ ខ្ញុំ-- ប្រសិនបើខ្ញុំចោទសួរសំណួរបើក ឬក៏សំណួរបែបនេះ ខ្ញុំត្រូវការពេលពីរបីថ្ងៃឯណោះ។ ប្រសិនបើយើងសួរសំណួរបិទ គឺយើងអាចពេលមួយថ្ងៃបាន។ ដោយសារតែខ្ញុំមានពេលតែមួយថ្ងៃ ដូច្នេះខ្ញុំធ្វើសកម្មភាពបែបនេះ។ ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំនឹងព្យាយាមឲ្យអស់ពីសមត្ថភាព។

[០៩:៣០:០២]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

លោកមេធាវី ខ្ញុំយល់ពីអ្វីដែលលោកចង់ជម្រាបទៅតុលាការ ប៉ុន្តែយើងមានវិធីសាស្ត្រផ្សេងៗគ្នា។ នេះគឺជាវិធីសាស្ត្រចោទសួរផ្ទាល់។ ដូច្នេះ សូមលោកមេត្តាគ្រប់គ្រងទៅលើការចោទសួរដេញដោលហើយមេត្តាគ្រប់គ្រងទៅលើចេតនារបស់លោក។ សូមអរគុណ។

**សួរដោយលោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** ខ្ញុំគិតថា ខ្ញុំអាចមានសមត្ថភាពធ្វើតាមការណែនាំនេះ។ ប្រសិនបើយើងនិយាយអំពីទំនាក់ទំនងរបស់លោកជាមួយនឹងលោក អៀង សារី ខ្ញុំគិតថាលោកមិនមានទំនាក់ទំនងអ្វីជាមួយលោក អៀង សារី ទេ ក្រៅពីការឃើញមុខគ្នាពីចម្ងាយ ហើយពីរបីដងប៉ុណ្ណោះ។ តើមែនឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំនិងបងវ៉ាន់ ខ្ញុំឃើញគាត់ពីចម្ងាយតែពីរដងទេ។ មិនមែនពីរ ឬបីដង គឺពិតជាពីរដង។

**ស៖** លោកមិនបានធ្វើការទាក់ទង ជាមួយនឹងក្រសួងការបរទេសដោយផ្ទាល់នោះទេ។ តើមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ មែន។

**ស៖** ជាការពិតលោកក៏មិនដែលទៅទស្សនកិច្ច ឬក៏ទៅចូលនៅក្នុងទីស្ដីការក្រសួងដែរ ក្រសួងការបរទេសនោះដែរ។ តើមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មែន។

[០៩:៣១:៤៧]

**ស៖** ហើយលោកក៏មិនដែលធ្លាប់ពិភាក្សាវែកញែក ជាមួយនឹងបុគ្គលិកធ្វើការនៅក្រសួងការបរទេសផងដែរ។ តើមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មែន!

**ស៖** លោកក៏មិនដែលទទួលការណែនាំពីលោក អៀង សារី មិនថាផ្ទាល់ ឬក៏តាមរយៈបុគ្គលណាមួយដូចជា សុន សេន តើមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មែន! លោកគ្រូ អៀង សារី មិនដែលណែនាំខ្ញុំតាមរយៈលោកគ្រូ សុន សេន ទេ។

[០៩:៣២:៣២]

**ស៖** វាក៏ត្រឹមត្រូវដែរនៅពេលដែលយើងលើកឡើងថា លោកក៏មិនដែលផ្តល់ជូន ឬក៏ពិនិត្យមើលកាលវិភាគធ្វើដំណើររបស់លោក អៀង សារី ផងដែរ តើមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ មែន! ខ្ញុំមិនដែលវិភាគដំណើរ បងវ៉ាន់ ទេ គាត់អញ្ជើញទៅណាអញ្ជើញទៅរឿងគាត់។

**ស៖** និងកាលវិភាគការងារប្រចាំថ្ងៃរបស់គាត់ ក៏លោកមិនដែលពិនិត្យមើលដែរ។ តើមែនដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់មាននឹកនាអីទៅពិនិត្យសកម្មភាពបងវ៉ាន់ទេ មួយបន្តិចក៏អត់ដែរ។

**ស៖** ខ្ញុំមិនមែនជាការសួររិះគន់ទេ ខ្ញុំគ្រាន់តែសួរឲ្យលោកឆ្លើយ។ លោកក៏មិនដែលទៅធ្វើទស្សនកិច្ចកន្លែងដែលលោក អៀង សារី ធ្វើការ ឬក៏រស់នៅផងដែរ។ ខ្ញុំរៀបចំសួរឡើងវិញ លោកមិនដែលទៅពិនិត្យមើល ឬទៅលេងកន្លែងស្នាក់នៅរបស់លោក អៀង សារី នោះទេ។ តើមែនដែរឬទេ?

[០៩:៣៣:៥២]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវី! លោកតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន យើងហាក់ដូចជាមិន ឃើញថាមិនមានគោលបំណងច្បាស់លាស់នៅក្នុងសំណួរ ទោះបីសំណួរនោះមានលំហូរទៅក៏ដោយ។ ចៅក្រម ខាតវ៉ាយថ៍ បញ្ជាក់ហើយថា សំណួរនាំមុខមិនអាចសួរបានទេ សំណួរគួរតែមានលក្ខណៈងាយៗ និងជាសំណួរបិទបើក។ មេធាវីគួរតែសួរថា តើលោកធ្លាប់ទៅទស្សនកិច្ចកន្លែងស្នាក់នៅរបស់លោក អៀង សារី ដែរឬទេ? ខ្ញុំគិតថា លោកមេធាវី អៀង សារី គាត់សើច។ ដូច្នេះគាត់ទៅលើចំណុចហ្នឹង។ ទោះបីយ៉ាងណាក៏ដោយ ខ្ញុំសូមឲ្យមេធាវីការពារក្ដីរៀបចំសំណួរឡើងវិញ។

**លោក ម៉ៃខល កាណាវាស៖**

បាទលោកប្រធាន។ ខ្ញុំនឹងរៀបចំសំណួរនេះឡើងវិញ។

[០៩:៣៤:៥៥]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តើលោកដឹងទំនាក់ទំនងពិតប្រាកដរវាង អៀង សារី និង សុន សេន ដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនដឹងទេ។

**ស៖** ត្រង់ចំណុចនេះ ខ្ញុំមានន័យថា ទំនាក់ទំនងការងារ។ ខ្ញុំសួរអំពីទំនាក់ទំនងការងារ។ តើលោកដឹងថា លោក អៀង សារី មានទំនាក់ទំនងការងារយ៉ាងម៉េចដែរជាមួយនិងលោក នួន ជា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បើនិយាយអំពីទំនាក់ទំនងការងារ យើងខ្ញុំដឹងជាគោលការណ៍ចាត់តាំងរបស់បក្ស។ គោលកាណ៍ចាត់តាំងរបស់បក្ស--

**ស៖** ខ្ញុំសូមឈប់កាត់លោក សម្ដីលោកត្រង់នេះ។ តើលោកដឹងអ្វីទៅលើទំនាក់ទំនងការងារ? លោកជាសាក្សីប្រធានស-២១ កាលពីសម័យកាលនោះ ដូច្នេះតើលោកដឹងទំនាក់ទំនងការងារជាក់ស្ដែងរវាងអ្នកទាំងពីរនោះយ៉ាងម៉េចដែរ?

[០៩:៣៦:៣១]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន សំណួរនេះធ្វើឲ្យខ្ញុំលំបាកឆ្លើយណាស់។ ខ្ញុំមិនចេះឆ្លើយទេ។ សូមជម្រាបថា ខ្ញុំអត់ចេះឆ្លើយតែម្ដង។

**ស៖** សូមអរគុណ។ សំណួរ ខ្ញុំសួរដូចគ្នាក្នុងករណី ប៉ុល ពត។ តើលោកពិតជាដឹង តើទំនាក់

ទំនងរបស់លោក ប៉ុល ពត ជាមួយនិងលោក អៀង សារី ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ជាគោលការណ៍ដឹង។ មេធំហើយនិងមេតាមផ្នែក ក៏ប៉ុន្តែ ដល់និយាយថាជាក់ស្តែងយ៉ាងម៉េច? អីយ៉ាងម៉េច? ខ្ញុំមិនដឹងទេ។ ជាគោលការណ៍ គឺច្បាស់ណាស់ មេពីរនាក់ហ្នឹងមេធំ។ ឯចំណែក អៀង សារី គឺមេជាក់ស្តែងតាមការងារ។ វាមិនដែលមេជាក់ស្តែង តាមការងារមិនគោរពមេធំទេ។

[០៩:៣៧:៥០]

**ស៖** វន វ៉េត គឺជាបុគ្គលមួយសំខាន់ផងដែរ តើមែន ឬក៏មិនមែន? តើ វន វ៉េត ជាបុគ្គលមួយ សំខាន់ផងដែរ តើមែន ឬក៏មិនមែន?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន វន វ៉េត សំខាន់ ឧបនាយករដ្ឋមន្ត្រីទីពីរ។

**ស៖** សូមអរគុណ។ តើលោកដឹងទំនាក់ទំនងពិតប្រាកដរបស់លោក វន វ៉េត ជាមួយនិង ប៉ុល ពត ដែរឬទេ? កុំនិយាយអំពីជាគោលការណ៍។

**ឆ៖** បើមិននិយាយជាគោលការណ៍ គឺមិនដឹង មិនឃើញគាត់ប្រជុំអង្គាល់ និយាយពីរឿងអី គឺ មិនដឹង មិនឃើញ។

[០៩:៣៨:៥២]

**ស៖** សូមអរគុណ។ តើលោកធ្លាប់ទៅលេង ដែលគេធ្លាប់ហៅថា មន្ទីរ៨៧០ តើលោកធ្លាប់ទៅ មើលកន្លែងនោះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន រឿង៨៧០នេះ ខ្ញុំមិនដែលចូលសោះ។

**ស៖** តើលោកអាចរៀបរាប់-- សូមឲ្យលោកជួយរៀបរាប់អំពីមន្ទីរ៨៧០ តើលោកអាចដែរឬ ទេ?

**ឆ៖** និយាយមួយម៉ាត់ ជារួមបែបនេះ ខ្ញុំមិនអាចទេ។ មិនអាចរាប់រៀបបានទេ។

[០៩:៤០:០០]

**ស៖** អរគុណ។ តើលោកដឹងថាតើនៅកន្លែងណាដែរមន្ទីរហ្នឹង?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មន្ទីរហ្នឹងខ្ញុំជាមួយ បងពីន ស្ទានខុសម្តងរួចទៅហើយ ជាពិសេសខ្ញុំស្មានខុសរួចម្តងរួចទៅហើយ គឺនៅត្រង់ហ្វ្រុងបាសាក់ នៅផ្ទះដួរមួយ ដែលគេហៅថាហ្វ្រុង បាសាក់ហ្នឹង។ ហ្នឹងគឺខ្ញុំស្មានខុសរួចទៅហើយ។

**ស៖** សូមអរគុណ។ មានចំណុចលម្អិតតូចៗមួយចំនួន ដែលខ្ញុំចង់សួរ។ តើលោកធ្លាប់ទទួលកំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែរឬទេ កាលពីសម័យនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនដែលបានទទួលទេ។

**ស៖** តើលោកធ្លាប់ទទួលកំណត់ហេតុកិច្ចប្រជុំរបស់គណៈមជ្ឈិមដែរឬទេ កាលពីសម័យនោះ?

**ឆ៖** ខ្ញុំមិនដែលទេ។

[០៩:៤១:៣៥]

**ស៖** តើលោកធ្លាប់ទទួលកំណត់ហេតុទាំងឡាយដែល ប៉ុល ពត បានរៀបចំឡើងជាមួយនឹងមេដឹកនាំភូមិភាគ ឬក៏កំណត់ហេតុគណៈកម្មការមួយចំនួនដែលលោក ប៉ុល ពត ប្រជុំជាមួយនឹងអ្នកទាំងអស់នោះ តើធ្លាប់ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន កំណត់ហេតុដែល ប៉ុល ពត ទៅប្រជុំជាមួយនឹងភូមិភាគបស្ចិមមានចុះនៅក្នុងទង់បដិវត្តម្តង។ ខ្ញុំឃើញទង់បដិវត្តនុ៎ង ក្រៅពីនុ៎ងខ្ញុំមិនឃើញស្អីទៀតទេ។

**ស៖** ដូច្នេះប្រសិនបើលោកមិនដែលធ្លាប់ចូលរួមក្នុងកិច្ចប្រជុំនានានោះទេ ហើយមិនដែលធ្លាប់ទទួលបាន និងពិនិត្យមើលកំណត់ហេតុកិច្ចប្រជុំទាំងអស់នោះ លើកលែងតែកំណត់ហេតុមួយដែលលោកទើបតែរៀបរាប់អម្បាញ់មិញនេះ។ តើលោកអាចជម្រាបដែរឬទេ? តើលោកពិតប្រាកដប៉ុនណាដែរ ដែលថាកិច្ចប្រជុំទាំងអស់នោះ គឺឆ្លុះបញ្ចាំងយ៉ាងពិតប្រាកដនូវអ្វីដែលបានពិភាក្សានៅក្នុងពេលកិច្ចប្រជុំនោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[០៩:៤៣:១៣]

**លោក វីល្លៀម ស្មីត៖**

ខ្ញុំយល់អំពីអ្វីដែលមេធាវីសួរ ក៏ប៉ុន្តែប្រសិនបើចង់ឲ្យសាក្សីយល់ច្បាស់នោះ គឺមេធាវីគួរតែនិយាយថា កំណត់ហេតុណាមួយ? កំណត់ហេតុដែលបញ្ចាំងនៅក្នុងតុលាការ ឬកំណត់ហេតុណាមួយ? យើងមិនយល់ច្បាស់ថា តើគាត់កំពុងសំដៅលើកំណត់ហេតុណាមួយនោះទេ?

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសូមធ្វើការឆ្លើយតបដោយខ្លីៗ។ ខ្ញុំយល់នូវអ្វីដែលសហព្រះរាជអាជ្ញាចង់និយាយ។

កន្លងមកគឺយើងកំពុងតែបង្ហាញមូលដ្ឋានដែលថាកិច្ចសាក្សីមិនដែលចូលរួមក្នុងកិច្ចប្រជុំ ហើយក៏មិនដែលទទួលបានកំណត់ហេតុនោះផងដែរ។ ដូច្នេះមិនដឹងថាតើគាត់បានដឹងពិតប្រាកដយ៉ាងណាក្រោយពីរយៈពេលកន្លងមកនេះ នៅពេលដែលគាត់បានអានកំណត់ហេតុទាំងអស់នោះ។ ខ្ញុំសួរអំពីកាលសម័យនោះ ខ្ញុំដឹងថាសាក្សីអាចប្រាប់ពន្យល់បញ្ជាក់យើង ហើយយើងខ្ញុំនឹងសួរបញ្ជាក់បន្ថែមទៀត។ ដូច្នេះ ខ្ញុំសួរសំណួរនេះឡើងវិញ។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** លោកសាក្សី តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ ថាកំណត់កិច្ចប្រជុំទាំងឡាយមិនថាមកពីគណៈអចិន្ត្រៃយ៍ ឬក៏គណៈមជ្ឈិម ឬក៏មកពីគណៈកម្មការណានោះទេ តើកំណត់ហេតុទាំងអស់នោះពិតជាកត់ត្រាបានត្រឹមត្រូវដែរឬទេ? លោកអាចជម្រាបត្រង់ចំណុចហ្នឹងបានដែរឬទេ?

[០៩:៤៤:៥១]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន កំណត់ហេតុខ្លះ និយាយខ្លះវាមិនត្រូវទេ។ ភាគច្រើនលើសលប់កត់ត្រាបានត្រឹមត្រូវ។ ឧទាហរណ៍ កំណត់ហេតុសំខាន់បំផុតមួយ គឺកំណត់ហេតុថ្ងៃ៣០ មីនា ១៩៧៦ ខ្ញុំជឿថា ជាសម្ដីរបស់ ប៉ុល ពត ហ្នឹងតែម្ដង។ ឯចំណែកកំណត់ហេតុផ្សេងទៀត ដែលសល់ទុកមកឲ្យយើងនេះមានកែ។ កំណត់ហេតុថ្ងៃ០៩ តុលា ១៩៧៥ ប៉ុល ពត សមមិត្តលេខា ក្ដាប់រួម--

**ស៖** ខ្ញុំសូមកាត់សម្ដីលោកត្រង់នេះ។ តើលោកធ្លាប់ចូលរួមកិច្ចប្រជុំទាំងអស់នោះដែរឬទេ? លោកមិនដែលធ្លាប់ចូលរួមកិច្ចប្រជុំទាំងអស់នោះទេ មែនដែរឬទេ?

[០៩:៤៥:៤៦]

**ឆ៖** ឥឡូវៗមុននឹងបន្តទៅទៀត ខ្ញុំសូមនិយាយពាក្យនេះឲ្យចប់របស់ខ្ញុំ។ ឧទាហរណ៍--

**ស៖** សូមអធ្យាស្រ័យ លោកសាក្សី--

**ប្រធានអង្គជំនុំ៖**

ឥឡូវឆ្លើយឲ្យចប់សិនទៅ លោកសាក្សីអាចឆ្លើយឲ្យចប់បាន។ ឆ្លើយឲ្យចប់សិននូវសំណួរអំមិញពីព្រោះនេះជាសំណួររបស់គាត់។ លោកត្រូវតែឆ្លើយឲ្យចប់តបនឹងសំណួរ។

**លោក ម៉ែខល កាណាវាស៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សាក្សីអាចបន្តចម្លើយឲ្យចប់ ព្រោះនេះជាបំណងប្រាថ្នារបស់មេធាវី។

[០៩:៤៦:១៩]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន កំណត់ហេតុខ្លះកត់ត្រាមិនបានត្រឹមត្រូវទាំងស្រុងទាំងទេ មានយកទៅកែតម្រូវ។ ឧទាហរណ៍ ដូចកំណត់ហេតុថ្ងៃ០៩ តុលា ១៩៧៥ “លេខា សមមិត្តលេខា ក្តាប់រួម” គេសរសេរជាប់ ពិបាកយល់ណាស់។ ហើយបាន បើសិនជាដកឃ្លាបន្តិច “សេដ្ឋកិច្ច និងយោធា” អាហ្នឹងបាននេះ។ ដូច្នេះ កំណត់ហេតុខ្លះវាមិនបានត្រឹមត្រូវទាំងស្រុងទេ វាមានការល្អៀងអ៊ីចឹងមែន។ សរុបមក គឺប៉ុនន៉ុង។ នេះចម្លើយដែលខ្ញុំសូមឆ្លើយទៅនឹងសំណួរមុនរបស់លោកមេធាវី។ ឥឡូវសូមលោកមេធាវីសួរសំណួរអំមិញ សំណួរចុងក្រោយដែលលោកសួរខ្ញុំតទៅទៀតចុះ។ ខ្ញុំនឹងឆ្លើយ។

[០៩:៤៧:១០]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តើលោកធ្លាប់ចូលរួមកិច្ចប្រជុំទាំងអស់នោះដែរឬទេលោក? មិនថាមានកិច្ចកំណត់ហេតុធ្វើឡើង ឬក៏មិនធ្វើឡើងនោះ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនដែលចូលរួមនឹងគេទេ។

**ស៖** តើលោកដឹងការពិភាក្សាជាក់លាក់នៅក្នុងកិច្ចប្រជុំទាំងអស់នោះដែរឬទេ? ខ្ញុំមិនសួរលោកធ្លាប់អានទេ តើលោកមានធ្លាប់ដឹងដែរឬទេ នៅការពិភាក្សាជាក់លាក់ក្នុងពេលប្រជុំនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំដឹងតាមការប្រាប់របស់មេខ្ញុំ តែមួយរឿងទេច្បាស់លាស់ គឺករណីដែលប្រជុំអចិន្ត្រៃយ៍ដើម្បីសម្រេចចាប់ សួស នៅ ហៅ ឈូក។ នេះខ្ញុំដឹង មេប្រាប់។ រឿងរ៉ាវល្អិតខ្ញុំបានរាយការណ៍ជូនអង្គជំនុំជម្រះរួចអស់ហើយ បើសិនជាលោកមេធាវីចង់ឲ្យខ្ញុំរាយការណ៍ទៀត ខ្ញុំរាយការណ៍។

[០៩:៤៨:៣៥]

**ស៖** សំណួររបស់ខ្ញុំ គឺសួរអំពីសេចក្តីសម្រេចខែមីនា ថ្ងៃទី៣០ ឆ្នាំ១៩៧៦ ដូច្នេះហើយទើបខ្ញុំកាត់សម្តីលោក ដោយសារលោកមិនបានឆ្លើយ។ លោកប្រាប់ថា មេរបស់លោកជាអ្នកប្រាប់លោក តើលោកនិយាយសំដៅមេនេះ តើអ្នកណាដែរ? តើ សុន សេន ឬក៏អ្នកណា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន សំណួរលោកមេធាវីអំមិញចុងក្រោយនេះ សំដៅថាថ្ងៃ ៣០ មីនា ១៩៧៦។ ខ្ញុំនិយាយអំពីសេចក្តីប្រជុំក្នុងការសម្រេចចាប់ សួស នៅ ហៅ ឈូក។ ដូច្នេះ វាយើងស្តាប់គ្នាមិនបានច្បាស់លាស់រួចទៅហើយ។ ដូច្នេះសូមលោកមេធាវីលោកបញ្ជាក់សួរខ្ញុំ តើសេចក្តីប្រជុំថ្ងៃណា? ពេលណា?

**ស៖** លោកទើបតែនិយាយថា លោកដឹងតាមរយៈមេរបស់លោក។ លោកនិយាយមេរបស់លោកនេះ ថាតើលោកនិយាយសំដៅលើលោក សុន សេន ដែលជាមេរបស់លោក ឬក៏អ្នកណា?

[០៩:៤៩:៤៧]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ដើម្បីច្បាស់លាស់ខ្ញុំសូមបញ្ជាក់។ ករណីប្រជុំអចិន្ត្រៃយ៍មជ្ឈិមដើម្បីសម្រេចចាប់ សួស នៅ ហៅ ឈូក ខ្ញុំដឹងតាមមេ។ មេនេះ គឺ សុន សេន។ នេះដើម្បីសម្រេចចាប់ សួស នៅ ហៅ ឈូក ខ្ញុំដឹងតាមមេ។ មេនេះគឺ សុន សេន។ នេះ ដើម្បីចាប់ សួស នៅ ហៅ ឈូក។

**ស៖** សូមអរគុណ។ ឥឡូវនេះ តើលោកអាចចង្អុលបញ្ជាក់ឯកសារណាមួយ ដែលលើកឡើងថាលោកបានជជែកជាមួយនឹងលោក សុន សេន លើបញ្ហានេះ។ តើមានឯកសារណាមួយដែលបញ្ជាក់ថា លោកពិតជាបានជជែកនិយាយជាមួយនឹងលោក សុន សេន លើករណីនេះ ដែរឬទេ?

**ឆ៖** ទីមួយ យើងត្រូវមើលខ្លឹមសារឯកសារទាំងស្រុង ខ្ញុំមិនដែលបានជជែកជាមួយនឹងមេខ្ញុំទេ។ ក៏ប៉ុន្តែជួនអី គោលការណ៍ខ្លះដែលកំណត់នៅក្នុងកំណត់ហេតុណាមួយ វាមាននិយាយគ្នា។ ក្នុងឋានៈគាត់ជាមេ គាត់ណែនាំខ្ញុំ។

[០៩:៥១:១៩]

**ស៖** ខ្ញុំសូមសួរលោកឡើងវិញ។ នៅពេលនេះ លោកប្រធាន ខ្ញុំនឹងកាត់សម្តីសាក្សី ប្រសិនបើគាត់មិនឆ្លើយ។ តើមានឯកសារណាមួយដែរឬទេ ដែលឯកសារនោះ បង្ហាញថា លោកនិយាយបញ្ហាហ្នឹងជាមួយនឹងមេរបស់លោក សុន សេន កាលពីសម័យនោះ។ ខ្ញុំសូមលើឧទាហរណ៍ជូនលោក ឧទាហរណ៍ថា កំណត់ហេតុប្រចាំថ្ងៃ ដែលលោករក្សាទុក ឬក៏ចំណារណាមួយដែលលោកបានសរសេរទុក គឺឯកសារណាមួយដែលបានបង្ហាញថាលោកពិតជាបានសន្ទនា ឬជជែកជាមួយនឹងលោក សុន សេន មែន លើករណីនេះ។

[០៩:៥២:០៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា ហើយសាក្សីកុំអាលឆ្លើយ ចាំស្ដាប់ការសម្រេចលើការជំទាស់របស់ភាគីសិន។

**លោក វីល្លៀម ស្មីត៖**

យើងខ្ញុំគ្រាន់តែចង់ឲ្យបញ្ជាក់បំភ្លឺតែប៉ុណ្ណោះ។ តែការពិត សាក្សីគឺខ្ញុំចូលរួមក្នុងពេលដែលស្ដាប់ចម្លើយជាមួយនឹងចៅក្រមស៊ើបអង្កេតផងដែរ។ ចំពោះបញ្ហាជជែកជាមួយនឹងថ្នាក់លើរបស់គាត់នោះ គឺខ្ញុំចង់តើថាមេធាវីកំពុងតែយោងកំណត់ហេតុស្ដាប់ចម្លើយដែលសាក្សីរូបនេះដែលផ្ដល់ជូនសហចៅក្រមស៊ើបអង្កេត ឬក៏លោកសំដៅលើកំណត់ហេតុស្ដាប់ចម្លើយណាមួយដែលបានកត់ត្រាទុក។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំមិនប្រាកដនោះទេ ថាសាក្សី គាត់យល់ច្បាស់ ឬក៏មិនច្បាស់ទៅលើសំណួររបស់ខ្ញុំ។ ខ្ញុំចង់សុំសួរសាក្សីអំពីឯកសារដែលកត់ត្រាដោយខ្លួនគាត់ផ្ទាល់ ឬក៏ឯកសារណាមួយដែលបានកត់ត្រាទុកកាលពីសម័យនោះ ថាគាត់ពិតជាបានពិភាក្សាជាមួយនឹង សុន សេន មែន។ ខ្ញុំគ្រាន់តែសួរថា តើមានឯកសារសម័យនោះ មានកត់ត្រាទុកដែរឬទេ? អាចជាកំណត់ហេតុប្រចាំថ្ងៃរបស់គាត់ ឬក៏ឯកសារផ្សេង ឬក៏យើងត្រូវស្ដាប់-- តើយើងត្រូវតែសំអាងស្ដាប់តែទៅលើអ្វីដែលចេញពីលោកសាក្សី ថានៅពេលនោះ គឺគាត់បានជជែកវែកជាមួយនឹង សុន សេន ឬក៏យ៉ាងណា?

[០៩:៥៣:៤៤]

**លោក វីល្លៀម ស្មីត៖**

ខ្ញុំដឹងថា នៅពេលនេះច្បាស់ហើយ។ គាត់អំមិញ មិនបានលើកឡើងអំពីឯកសារកាលពីសម័យនោះទេ។ ដូច្នេះហើយ នៅពេលនេះគឺយើងដឹងច្បាស់ហើយ យើងដឹងថាឯកសារគាត់សំដៅទៅលើឯកសារដែលបានបង្កើតឡើងកាលពីសម័យនោះ។ ដូច្នេះ យើងខ្ញុំយល់ច្បាស់។

**ប្រធានអង្គជំនុំ៖**

សាក្សីយល់សំណួរទេ? យល់សំណួររបស់លោកមេធាវី កាណាវាស ចុងក្រោយនេះទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បើតាមការយល់ដឹងរបស់ខ្ញុំ សំណួរគាត់ចង់និយាយថានៅពេលដែលខ្ញុំជជែកជាមួយនឹងមេ។ និយាយពិសេស គឺជាមួយនឹងមេទីមួយចុះ លោក សុន សេន។

តើខ្ញុំមានកត់ត្រាការជជែកគ្នាហ្នឹងទេ? ខ្ញុំសូមបញ្ជាក់ថា ពេលដែលគាត់ហៅខ្ញុំទៅការម្តងៗ ខ្ញុំយកសៀវភៅទៅ។ របៀបវារៈ គាត់កំណត់។ ដូច្នេះ ខ្ញុំកត់ត្រួសៗ ការងារខ្លីៗ កំណត់ដែររបស់ខ្ញុំនៅហ្នឹង ស-២១ ស្រាប់។ ធ្វើការជាមួយ បងនួន ក៏អ៊ីចឹង ខ្ញុំយកសៀវភៅទៅ ទៅដល់គាត់មានប្រសាសន៍មួយម៉ាត់ពីរមក ខ្ញុំកត់ទុក។ មកដល់វិញ ដឹកនាំការងារដែលគាត់បញ្ជាមកទាំងអស់។ ដូច្នេះ វាមានតែប៉ុនុ៎ងទេ អត់មានពិភាក្សាណា យើងខ្ញុំបានកំណត់ហេតុជាភស្តុតាងស្អីទេ។

[០៩:៥៥:៤៣]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំសូមសួរឲ្យបានជាក់លាក់ជាងនេះ។ ខ្ញុំមិនសួរថាតើលោកបានកត់ត្រាការងារដែលលោកត្រូវតែអនុវត្តថាតើលោកកត់ត្រាត្រូវតែសួរចម្លើយបន្ថែម ប្រើប្រាស់វិធីក្តៅ ឬក៏វិធីត្រជាក់ ឬក៏កត់ត្រាថាតើបុគ្គលណាមួយមានកំហុសសីលធម៌ជាមួយនឹងកូនរបស់ខ្លួន ឬក៏យ៉ាងណានោះទេ។ ខ្ញុំចង់សួរថាតើលោកមានកត់ត្រាទុកអ្វីដែរ សុន សេន បានប្រាប់មកលោកនូវហេតុការណ៍ការងារ ឬក៏ការពិភាក្សានៅក្នុងគណៈអចិន្ត្រៃយ៍ដែរឬទេ? ខ្ញុំសួរសំណួរនេះដោយសារតែជាច្រើនលោកមកហើយ លោកបានលើកឡើងថា ព័ត៌មានទាំងអស់មួយចំនួននេះគឺដឹងតាមរយៈមេ។ ដូច្នេះ តើលោកមានកត់ត្រាព័ត៌មានលម្អិតទាំងអស់ដែរឬទេ នៅពេលដែលលោកពិភាក្សាជាមួយនឹងមេនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ការណែនាំរបស់មេ លម្អិតអំពីបញ្ហាមួយៗគឺអត់ដែលបានកត់ទេ។

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលថា នៅពេលដែលលោកនិយាយអំពីការភ័យខ្លាច ហើយលោកនិយាយថា លោកមានការភ័យខ្លាចណាស់កាលពីសម័យនោះ។ តើវាត្រឹមត្រូវដែរឬទេដែលថា វាមិនល្អចំពោះលោកទេដែរថា នៅពេលដែលលោកសួរសំណួរពី សុន សេន ថាមានអ្វីកើតឡើងនៅក្នុងគណៈអចិន្ត្រៃយ៍ ឬគណៈមជ្ឈិមនោះ។ តើមែនដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបនឹងសំណួរ ចាំស្តាប់អង្គជំនុំជម្រះសម្រេចលើការជំទាស់របស់ភាគីតំណាងព្រះរាជាអាជ្ញាជាមុនសិន លើបញ្ហាសួរសំណួរចុងក្រោយនេះ។

**លោក វីល្លៀម ស្មីត៖**

ខ្ញុំយល់អំពីចេតនានៃការសួរសំណួរ ក៏ប៉ុន្តែវាអាចឲ្យមានការយល់ច្រឡំ។ គឺយើងដឹងហើយថា

សុន សេន-- អំ! វន វ៉េត ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៨ យើងមិនដឹងថាគាត់សំដៅទៅលើ នួន ជា ឬក៏យ៉ាងណានោះទេ។ ដូច្នេះហើយ សំណួរចៀសវាងការបង្ហាញ សំណួរត្រូវតែបង្ហាញឲ្យបានច្បាស់ ថាតើពេលនេះសំដៅទៅអ្នកណាគេ សុន សេន ឬក៏ នួន ជា ដែលយើងដឹងថា វន វ៉េត ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៨។

**លោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំមិនធ្វើការឆ្លើយតបទៅការជំទាស់របស់សហព្រះរាជអាជ្ញាទេ។ ខ្ញុំសូមសួរសំណួរឡើងវិញ។ នៅក្នុងឆ្នាំ១៩៧៦ តើមានការភ័យខ្លាច ពេលដែលលោកបម្រើការងារនៅស-២១ ដែរឬទេ?

[០៩:៥៩:០៨]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នៅក្នុងឆ្នាំ១៩៧៦ ពេលនុងខ្ញុំគ្រាន់តែភ័យខ្លាចអស់ជីវិតដោយចេះតែដើរចាប់គេផ្ដេសផ្ដាស ម្ល៉ោះហើយប្រយ័ត្នណាស់ នេះទីមួយ។ ទីពីរ ចម្លើយវាលដាលពាសវាល ពាសកាលនេះទីពីរ។ ដូច្នេះហើយបានជា ឲ្យតែគេឆ្លើយដាក់អ្នកធំ ខ្ញុំតែងតែទៅសុំយោបល់ពីខាងលើ នេះទីពីរច្បាស់លាស់ណាស់។ ហើយទីបី ដើរទៅណាមកណាសេរីមិនបានទេ។ មិនបានទាល់តែសោះ។

[១០:០០:០០]

**ស៖** សូមអរគុណ។ តើវាត្រឹមត្រូវដែរឬទេ ផ្អែកទៅតាមអ្វីដែលលោកឆ្លើយ។ លោកមានការប្រុងប្រយ័ត្នណាស់ ដែលថាលោកមិនត្រូវធ្វើអ្វីមួយ ដែលវាអាចនាំឲ្យមានការចាប់ខ្លួនទៅដល់រូបលោកនោះទេ។ តើមែនដែរឬទេ?

**ឆ៖** ច្បាស់ហើយ!

**ស៖** លោកបាននិយាយកាលពីសម័យនោះ និយាយអំពីបញ្ហាការរក្សាការសម្ងាត់ ហើយលោកបានជម្រាបថា គឺមិនត្រូវនិយាយអ្វីទាំងអស់ ហើយមិនត្រូវស្ដាប់អ្វីទាំងអស់។ បានន័យថា យើងធ្វើតែការងារដែលយើងដឹង។ យើងដូចជាដើមគអ៊ីចឹង។ តើនេះគឺយើង ខ្ញុំលើកចំណុចនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ពាក្យស្លោករបស់គេគឺ "ការងារគេ គេដឹង ការងារយើង យើងដឹង"។ ការងារស-២១ ខ្ញុំត្រូវតែដឹង។ ក្រៅពីការងារ ស-២១ ខ្ញុំគ្មានសិទ្ធិដឹងទេ។

[១០:០១:១៣]

**ស៖** ដូច្នេះហើយ ឧទាហរណ៍-- ចំណុចនេះបានន័យថា វាមិនមែនជាការងាររបស់លោក ដែលត្រូវទៅសួរគេ ថាតើមានអ្វីកើតឡើងពិភាក្សាអ្វីខ្លះនៅក្នុងគណៈអចិន្ត្រៃយ៍នោះទេ។ តើចំណុចនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយនឹងសំណួរ សួរដោយមេធាវី អៀង សារី ចុងក្រោយអម្បាញ់មិញនេះ។ ចាំស្ដាប់ការជំទាស់សម្រេច-- អង្គជំនុំជម្រះសម្រេចលើការជំទាស់របស់ភាគីតំណាងសហព្រះរាជអាជ្ញា។ អញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

យើងហាក់ដូចជាឃើញថា មេធាវីកំពុងតែសួរសំណួរនាំមុខហើយ។ ថាតើវាជាការងាររបស់សាក្សីសួរ--

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន គឺខ្ញុំដឹងអំពីពេលវេលា ហើយខ្ញុំយល់។ ហើយខ្ញុំមិនចង់ឲ្យសហព្រះរាជអាជ្ញាគាត់កាត់សម្ដីរបស់ខ្ញុំដូចដែលគាត់ធ្វើនៅក្នុងថ្ងៃនេះនោះទេ។

[១០:០២:២២]

**លោក វីល្លៀម ស្មីត៖**

គឺយើងខ្ញុំមិនមែនកាត់សម្ដី ធ្វើការកាត់ការតាំងសំណួររបស់មេធាវីការពារក្ដីនោះទេ។ គ្រាន់តែយើងចង់ឲ្យអនុវត្តវិធានដូចគ្នានៅក្នុងតុលាការ។ បញ្ហាចោទនោះគឺមេធាវីសួរថា តើវាជាការងាររបស់សាក្សីដែលត្រូវតែសួរគណៈអចិន្ត្រៃយ៍ធ្វើអ្វីខ្លះដែរឬទេ? នេះជាការណែនាំពីអង្គជំនុំជម្រះ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំសូមសួរឡើងវិញ ថាតើវាជាការងាររបស់លោក ដែលលោកត្រូវទៅសួរថា តើគណៈអចិន្ត្រៃយ៍នោះ គេពិភាក្សាលើអ្វីខ្លះដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនដែលបានសួរមេខ្ញុំទេ។ អត់បានសោះ។ បើមេ

បងនួន នេះកាន់តែលែងបាានទៅទៀត។

[១០:០៣:២០]

**ស៖** ចុះតើលោកធ្លាប់សួរអ្នកដទៃឬទេ? តើវាជាការងាររបស់លោកដែរឬទេ? តើវាជាការងាររបស់លោកដែរឬទេ ដែលទៅសួរអ្នកដទៃអំពីអ្វីដែលកើតឡើង? បានន័យថា គឺថាលោកសួរថាមានអ្វីកើតឡើងនៅគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិម ឬក៏គណៈកម្មាធិការផ្សេងៗទៀត។ តើវាជាការងាររបស់លោកដែរឬទេ?

**ឆ៖** ជាក់ស្តែងវាមិនមែនជាការងាររបស់ខ្ញុំទេ។ តែខ្ញុំពិតជាបានសួរ ប៉ង់ ពីរឿងប្រជុំអចិន្ត្រៃយ៍ មជ្ឈិម ពីក្នុងករណីចាប់ ជូ ជេត ហៅ ស៊ី ព្រោះគេនៅក្បែរនោះ។

**ស៖** ដូច្នេះ យើងសូមលើកឧទាហរណ៍ដែលលោកបានលើកឡើងជាក់លាក់មួយនេះ។ តើយើងអាចសន្និដ្ឋានបានទេថា លោកទុកចិត្ត ប៉ង់ ដែលជម្រាបអ្នកដទៃដែលថា ប៉ង់ មិនទៅប្រាប់អ្នកដទៃថាលោកសួរសំណួរសំខាន់ ឬក៏សំណួរដែលរសើបទាក់ទងទៅនឹងការពិភាក្សារបស់គណៈកម្មាធិការនានានោះ?

[១០:០៤:៤៤]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ប៉ង់ ជាមនុស្សម្នាក់ដែល បងនួន គាត់ឧទ្ទេសនាមឲ្យចុះឡើងមកស-២១។ ប៉ង់ មានសិទ្ធិក្តាប់រហូតទៅដល់ចម្លើយសារភាពរបស់ពួកអ្នកទោសទៅទៀត។ ហើយជាអ្នកមានសិទ្ធិនាំសេចក្តីសម្រេចរបស់ខាងលើមកវិញទៀត។ ខ្ញុំជឿថា ប៉ង់ នៅនុ៎ង ជាអ្នករៀបចំតុកៅអីសម្រាប់ចូលប្រជុំ ប៉ង់ យល់។ ដូច្នេះ ប៉ង់ មានសមត្ថកិច្ចនឹងឲ្យខ្ញុំដឹងនូវអ្វីដែលអាចដឹងបានជាតម្លាភាព មិនមែនទៅដល់ការសម្ងាត់ឯណា ប្រទេសជាតិទេ។ ដូច្នេះបើ បង់ យករឿងនេះទៅជម្រាបបងប៉ុល ស្រេចតែគាត់ទៅ។ បងប៉ុល សម្រេចកាត់ទោសខ្ញុំ ក៏កាត់ទៅ។ នេះវានៅក្របខ័ណ្ឌចង់ដឹងរបស់ខ្ញុំ។

**ស៖** ខ្ញុំមិនចង់ពិភាក្សាអំពីបញ្ហានេះទេ ប៉ុន្តែលោកនិយាយថា ក្នុងករណីមួយនេះ គឺលោកសួរសំណួរទៅ ប៉ង់។ លោកព្យាយាមស្វែងរកព័ត៌មានពី ប៉ង់។ ហើយសំណួររបស់ខ្ញុំគឺថា តើលោកទុកចិត្ត ប៉ង់ ដល់ថ្នាក់ហ្នឹង ដែលដល់ថ្នាក់លោកបាានសួរ ប៉ង់ អំពីព័ត៌មានសំខាន់ៗដែលលោកមិនមានសិទ្ធិក្នុងការដឹង និងការដែលលោកទុកចិត្ត ប៉ង់ ដល់ថ្នាក់ហ្នឹងឬ?

[១០:០៦:០៩]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំទុកចិត្ត។ ហើយនេះនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលគេអាចឲ្យខ្ញុំដឹងបាន សមត្ថកិច្ចរបស់គេ។ បើគេឲ្យខ្ញុំដឹងបាន គេឲ្យដឹង បើគេមិនឲ្យដឹងបានអាហ្នឹងវាការសម្ងាត់ អាហ្នឹងវាគេ។ គេមិនឲ្យដឹង ធ្វើអីគេ។

**ស៖** តើលោកអាចជម្រាបយើងបានដែរឬទេ តើមានអីកើតឡើង ប្រសិនបើ ប៉ង់ ត្រឡប់ទៅវិញ ហើយប្រាប់មេរបស់គាត់ថា លោកចោទសួរទៅគាត់អំពីសំណួរបែបនេះ។ តើលោកអាចដឹងទេថាតើនឹងមានអ្វីអាចកើតឡើងចំពោះលោក ប្រសិនបើជាមានរឿងនេះកើតឡើង?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ប្រសិនបើ ប៉ង់ ទៅវិញរាយការណ៍ជម្រាប បងប៉ុលជម្រាបទៅ។ បើបងប៉ុល គាត់ដាក់ទោសខ្ញុំក៏ដាក់ទៅ ខ្ញុំមានខ្លួនសម្រាប់រង់ចាំទទួលទោស។

**ស៖** អ៊ីចឹងលោកមិនភ័យខ្លាចគេឆ្លើយដាក់ថា ជាខ្មាំង ដែលព្យាយាមតាមដាន ឬក៏ស៊ើបអង្កេតអំពីសកម្មភាព ឬក៏ពីការងាររបស់គណៈកម្មាធិការមជ្ឈិមអចិន្ត្រៃយ៍ទេឬ?

[១០:០៧:២៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា! មេធាវីកុំអាល-- សាក្សីកុំអាលឆ្លើយតបទៅនឹងសំណួរចុងក្រោយនេះ។

**លោក វីណ្ឌៀម ស្មីត៖**

លោកប្រធាន ខ្ញុំជំទាស់ទៅសំណួរ ព្រោះសំណួរនេះជាសំណួរនាំមុខ។ សាក្សីមិនបាននិយាយថាការពិភាក្សាជាមួយ ប៉ង់ អំពីបញ្ហាគណៈកម្មាធិការ ឬក៏បញ្ហាគណៈកម្មាធិការនានាហ្នឹងមានន័យថាគាត់ហ្នឹងជាតិញសម្ងាត់នោះទេ។ ដូច្នេះគាត់បានបញ្ជាក់ហើយថា គាត់អាចពិភាក្សាអំពីបញ្ហានេះ ហើយគាត់មានតួនាទីក្នុងការពិភាក្សាអំពីបញ្ហានេះ។ ដូច្នេះ សំណួរនេះមិនមែនជាអ្វីដែលសាក្សីបានលើកឡើងនោះឡើយ។ ដូច្នេះហើយខ្ញុំគិតថា គួរតែរៀបចំសំណួរឲ្យបានត្រឹមត្រូវប្រសើរជាងនេះ។

[១០:០៨:០៧]

**ប្រធានអង្គជំនុំ៖**

ជំទាស់មានរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិមានប្រសិទ្ធភាព។ សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរចុងក្រោយដែលសួរឡើងដោយមេធាវីការពារក្តីលោក អៀង សារី នេះទេ។ លើកលែងតែគាត់កែសម្រួល ផ្លាស់ប្តូរនូវរបៀបសួរ តាំងសំណួរត្រឹមត្រូវ សមស្រប។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី តើមានអ្វីកើតឡើងចំពោះបុគ្គលដទៃដែលព្យាយាមតាមដាន ឬក៏ស៊ើបអំពីព័ត៌មានទាក់ទងទៅនឹងគណៈកម្មាធិការអចិន្ត្រៃយ៍ ឬក៏គណៈកម្មាធិការការងារ។ តើលោកដឹងដែរឬទេ តើមានអ្វីកើតឡើងចំពោះពួកទាំងអស់នោះ? បានន័យថា ផ្អែកទៅតាមអ្វីដែលលោកដឹង តើអាចមានអ្វីកើតឡើង? គឺថាតើបើតាមដែលលោកដឹង តើអាចមានអ្វីកើតឡើងចំពោះអ្នកទាំងអស់នោះ?

[១០:០៩:០៩]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ចំពោះខ្ញុំដែលចង់ដឹងរឿងនេះ។ ខ្ញុំសូមនិយាយតែប៉ុណ្ណឹង ព្រោះអាហ្នឹងវាជាក់ស្តែង។ រឿងនេះវាស្ថិតនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្ញុំ។ ខ្ញុំជឿថា ប៉ង់ គេប៉ាន ប្រាប់ខ្ញុំក្នុងឋានៈគេជាអ្នកកាន់កាប់ការណ៍ហ្នឹង ដើម្បីឲ្យដឹងតម្លាភាព ដើម្បីឲ្យខ្ញុំជ្រះស្រឡះតែប៉ុណ្ណោះ។ ខ្ញុំមិនមែនចង់ដឹងព័ត៌មានសម្ងាត់ ហើយទៅតាមដានបំផ្លាញអចិន្ត្រៃយ៍មជ្ឈិមទេ។ បើសិនជាខ្ញុំចង់ដឹងព័ត៌មានសម្ងាត់ ហើយទៅតាមដានបំផ្លាញអចិន្ត្រៃយ៍មជ្ឈិម អាហ្នឹងទោសក្បត់ជាតិហើយ កាត់ក។ ដូច្នេះវាខុសគ្នា។ ចង់ដឹងដើម្បីយល់ ហើយដើម្បីជ្រះស្រឡះ ដើម្បីភ្លឺស្វាង វាផ្សេង។ ចង់ដឹងដើម្បីតាមដាន ហើយបំផ្លាញអចិន្ត្រៃយ៍មជ្ឈិមវាផ្សេង។ សារធាតុនៃបញ្ហាចង់ដឹង ស៊ើបសួរវាខុសគ្នា។ សូមលោកមេធាវីមេត្តាពិចារណាបញ្ហានេះ នេះជាក្នុងការអនុវត្ត ខ្ញុំជឿថា ស្ទើរតែគ្រប់ប្រទេស។

**ស៖** ដូច្នេះ ខ្ញុំធ្វើការបញ្ជាក់ឡើងវិញប្រសិនបើលោកបានជម្រាបខ្ញុំ។ លោកបានជម្រាបយើងថា ប៉ង់ បានត្រឡប់ទៅវិញ ហើយនិយាយថា សមមិត្ត ឌុច បានសួរសំណួរប្រភេទនេះៗ។ ដូច្នេះគឺថានៅពេលនុ៎ងប្រហែលជាលោកមិនទទួលការចោទប្រកាន់ថា ជាជនក្បត់នោះទេ តើលោកចង់មានន័យបែបនេះដែរឬទេ?

[១០:១០:៥១]

**ឆ៖** ខ្ញុំសូមមិនឆ្លើយសំណួរនេះទេ ដូចជាលោកមេធាវីវិភាគ ហើយសន្និដ្ឋាន ហើយឲ្យខ្ញុំឆ្លើយនឹងសំណួរសន្និដ្ឋានរបស់លោក ដូចជាវាឆ្ងាយពីការពិតណាស់។

**ប្រធានអង្គជំនុំ៖**

ត្រឹមត្រូវ ហើយមេធាវីអាចតសំណួរផ្សេងទៀត ហើយព្យាយាមជៀសឲ្យផុតនូវតាំងសំណួរក្នុងន័យឲ្យសាក្សីផ្តល់នូវសេចក្តីសន្និដ្ឋាន ឬការយល់ដឹងអត្តនោម័តរបស់ខ្លួននូវបញ្ហាណាដែលមិនជាក់ស្តែង។

**លោក ម៉ៃខល កាណាវ៉ាស៖**

ព្រោះថា អ្វីលោកប្រធានបានលើកឡើង ដើម្បីកំណត់ត្រា គឺថាខ្ញុំសូមជម្រាបដោយគោរពថា អ្វីដែលលោកប្រធានមានប្រសាសន៍ គឺហាក់ដូចជាត្រឹមត្រូវទេ ព្រោះថា អ្វីដែលយើងនិយាយនេះ គឺថាសាក្សីគាត់-- គឺថា ខ្ញុំដាក់សំណួរដោយសាមញ្ញ ដោយងាយស្រួល ខ្ញុំនឹងបន្តទៅទៀត ប៉ុន្តែតាមដែលខ្ញុំជម្រាបដោយសេចក្តីគោរពគឺថា ហាក់ដូចជាមានបញ្ហានៅក្នុងការសម្រេច។

**ប្រធានអង្គជំនុំ៖**

សាក្សីឈប់ឆ្លើយ កុំឆ្លើយទៅនឹងសំណួរទាំងឡាយដែលភាគីឯណាក៏ដោយ សួរក្នុងន័យឲ្យសាក្សីធ្វើសេចក្តីសន្និដ្ឋាននូវបញ្ហាដែលមិនជាក់លាក់ ដែលមិនមានកើតឡើងនៅក្នុងអំឡុងពេលណាមួយនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។

[១០:១២:៣២]

**លោក ម៉ៃខល កាណាវ៉ាស៖**

ការពិត ខ្ញុំមិនមែនស្នើឲ្យសាក្សីឆ្លើយដោយការសន្មតនោះទេ។

**សួរដោយលោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** លោកសាក្សី បុគ្គលដែលត្រូវគេឆ្លើយដាក់ ដែលត្រូវគេសួរសំណួរធ្វើទារុណកម្ម ហើយសម្លាប់ ដែលពួកគាត់ទាំងអស់នេះ សុទ្ធតែជាមនុស្សស្លូតត្រង់នៅពេលនោះ។ តើមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នេះឲ្យខ្ញុំសន្និដ្ឋាន តើអ្នកត្រូវសម្លាប់១២.២៧៣នាក់នេះសុទ្ធតែជាមនុស្សស្លូតត្រង់ទាំងអស់ ឬអី? ខ្ញុំមិនសន្និដ្ឋានទេ។

**ស៖** លោកសាក្សី តើបុគ្គលដែលត្រូវ-- ដែលមានឈ្មោះនៅក្នុងចម្លើយសារភាពនៅពេលក្រោយមកគាត់ចូលមកមន្ទីរស-២១ ដែលស្ថិតក្រោមកាតព្វ-- ស្ថិតក្រោមអំណាច និងការគ្រប់គ្រងរបស់លោក ហើយពួកទាំងអស់នោះក្រោយមកត្រូវគេធ្វើទារុណកម្ម សួរចម្លើយ និងស្លាប់ តើមែនដែរឬទេ?

[១០:១៤:00]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មនុស្សដែលមានចម្លើយចេញពីស-២១ មានមួយចំនួនត្រូវអចិន្ត្រៃយ៍សម្រេចបញ្ជូនមកស-២១។ នេះជារឿងពិត រឿងពិតឲ្យតែបញ្ជូនមកដល់ស-២១ ហើយអត់រួចទេ ត្រូវតែសួរចម្លើយ ហើយចុងបញ្ចប់ត្រូវតែកម្ទេច។

**ស៖** លោកសាក្សី លោកអត់ឆ្លើយសំណួររបស់ខ្ញុំបានត្រឹមត្រូវទេ។ ការងាររបស់លោកមួយចំនួនគឺចោទសួរ ហើយការចោទសួរហ្នឹង គឺដើម្បីទទួលបានឈ្មោះ ហើយឈ្មោះបុគ្គលដែលគេឆ្លើយដាក់ហ្នឹងត្រូវយកមកដាក់នៅក្នុងស-២១ ហើយពួកគាត់ត្រូវគេធ្វើទារុណកម្ម និងសម្លាប់។ សំណួររបស់ខ្ញុំគឺថា តើពួកគេទាំងនោះត្រូវបានគេចាប់មក ដោយសារតែការឆ្លើយដាក់ពីអ្នកដទៃតើមែនដែរឬទេ? ខ្ញុំមិនស្នើសុំឲ្យលោកធ្វើការទាយស្មាននោះទេ។

[១០:១៥:០៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបទៅនឹងសំណួរ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

លោកប្រធានប្រធាន អ្វីដែលខ្ញុំយល់គឺថា គាត់យល់ស្រប។ សាក្សីយល់ស្របជាមួយមេធាវីគឺថាអ្នកដែលត្រូវបានគេឆ្លើយដាក់ត្រូវគេបញ្ជូនមកស-២១ ហើយគ្មាននរណាម្នាក់នៅស-២១ រួចជីវិតនោះទេ។ ដូច្នេះ ខ្ញុំគិតថា សាក្សីគាត់ឆ្លើយទៅនឹងសំណួររបស់មេធាវីរួចទៅហើយ។ ដូច្នេះហើយ ខ្ញុំគិតថាសាក្សីបានឆ្លើយបាទរួចទៅហើយ នៅពេលដែលគាត់និយាយថា អ្នកដែលគេឆ្លើយដាក់ ហើយយកមកស-២១ ហ្នឹងត្រូវបានគេសម្លាប់។ អានេះ គឺជាអ្វីដែលគាត់បានឆ្លើយ។

[១០:១៥:៤៩]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

ខ្ញុំគិតថា ប្រហែលជាព្រះរាជអាជ្ញា គាត់យល់ស្របហើយ ប៉ុន្តែគឺថាអាចនឹងមានការឆ្លើយដាក់ដោយបង្ខំ ហើយបុគ្គលដែលគេឆ្លើយដាក់ ត្រូវបានគេកម្ទេច ត្រូវបានគេសម្លាប់។ ដូច្នេះ ខ្ញុំគិតថាប្រសិនបើសាក្សីហ្នឹងគាត់ដឹងអ៊ីចឹងគឺគ្រប់គ្រាន់ហើយ។

**ស៖** ដូច្នេះ ឥឡូវយើងបន្តទៅផ្នែកដទៃមួយទៀត។ យើងនិយាយអំពីការសម្ភាស និងអំពីការរៀបចំមុននឹងលោកមកទីនេះ។ តើលោកអាចជម្រាបយើងបានដែរឬទេ? ថាតើលោកមានបានអានឯកសារណាមួយមុននឹងពេលផ្តល់សក្ខីកម្ម នៅក្នុងសំណុំរឿងជាក់ស្តែងមួយនេះគឺ០០២ មួយនេះ។

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន លោកមេធាវីចង់សួរថាម៉េច? សូមលោកមេធាវីមេត្តាសួរម្តងទៀតមក។

**ស៖** ឥឡូវខ្ញុំសូមសួរជាទូទៅ មុន-- ឥឡូវនៅថ្ងៃនេះ មុនពេលលោកមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿងនេះ តើព្រះរាជអាជ្ញាមានផ្តល់ឯកសារមួយដុំ ដើម្បីឲ្យលោកធ្វើការពិនិត្យដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ឯកសារហ្នឹង ព្រះរាជអាជ្ញាផ្តល់ឲ្យ ព្រោះឯកសារហ្នឹងខ្ញុំត្រូវតែមាន ព្រោះជាចម្លើយរបស់ខ្ញុំជូនសហចៅក្រមស៊ើបអង្កេត។

[១០:១៧:២៧]

**ស៖** អត់មាននរណានិយាយពីចំណុចនេះទេ។ ខ្ញុំអត់បាននិយាយពីសិទ្ធិនេះទេ ប៉ុន្តែខ្ញុំមិន-- មុននឹងពេលដែលលោកមកបង្ហាញនៅក្នុងសំណុំរឿងផ្ទាល់ខ្លួនរបស់លោក គឺសំណុំរឿង០០១នោះ តើលោកទទួលបានសិទ្ធិចូលទៅក្នុងឯកសារទាំងនោះដែរឬទេ? តើលោកមានសិទ្ធិចូលពិនិត្យឯកសារទាំងនោះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់យល់ទេ មិនដឹងសួររឿងអីទេ។

**ស៖** លោកមានមេធាវីតំណាង តើមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ច្បាប់អនុញ្ញាតឲ្យខ្ញុំមានមេធាវីពីររូប។

**ស៖** ថាតើមេធាវីនុ៎ងមានផ្តល់ឯកសារ ឬក៏ផ្តល់ឯកសារណាមួយទៅដល់លោកទាក់ទងនៅក្នុងសំណុំរឿងមុនពេលដែលជួបជាមួយចៅក្រមស៊ើបដែរឬទេ?

**ឆ៖** គ្មានទេៗ។

[១០:១៨:៥០]

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ម្តងទៀត ដើម្បីកុំឲ្យមានភាពអយុត្តិធម៌ចំពោះលោក។ តើលោកចង់ជម្រាបយើងថា មេធាវីរបស់លោកមិនមានផ្តល់ឯកសារណាមួយឲ្យលោក ដើម្បីពិនិត្យមើលទេនៅពេលដែលលោកផ្តល់ការសម្ភាសជាមួយនឹងមេធាវីការពារក្តី។ បានន័យថា មេធាវីរបស់លោកហ្នឹងមិនបានឲ្យនូវឯកសារណាមួយដល់លោកទេ។ តើលោកចង់មានន័យបែបនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ជាភាសាខ្មែរ ដូចជាអត់អាចស្តាប់បានទេ។ មិនមែនធ្វើសម្ភាសដោយមេធាវីខ្លួនឯង ផ្តល់ឯកសារខ្លួនឯង ហើយឲ្យមេធាវីធ្វើសម្ភាសន៍ទេ។ អាចលោកមេធាវីតាំងសំណួរសាជាថ្មីម្តងទៀត ហើយសូមអ្នកបកប្រែរៀបចំនូវការបកប្រែឲ្យបានត្រឹមត្រូវ។ មិនមែនមេធាវីផ្តល់ឯកសារឲ្យទៅគាត់ ឲ្យទៅសាក្សី ហើយសាក្សីផ្តល់បទសម្ភាសន៍មកវិញ មកមេធាវីរបស់គាត់ដដែលទេ។ ទំនងជាខាងសហចៅក្រម

សុើបអង្កេត នេះជាសំណួរខាងដើម។

[១០:២០:០០]

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ខ្ញុំមិននិយាយថាមេធាវីត្រូវបានសម្លាសដោយ មិនបានថាមេធាវីសម្លាសជនជាប់ចោទនោះឡើយ គឺថាចង់និយាយថា ជនជាប់ចោទគាត់ទទួលបានសិទ្ធិចូលទៅក្នុងសំណុំរឿងដែរឬអត់?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ស្អីទៅសិទ្ធិចូលទៅក្នុងសំណុំរឿង? ខ្ញុំអត់យល់។

**ស៖** ថាតើគេផ្តល់សិទ្ធិពិនិត្យសំណុំរឿងជូនលោកដែរឬទេ?

**ឆ៖** សិទ្ធិនោះមាន ឬគ្មាន ខ្ញុំអត់ដឹងទេ។ ក៏ប៉ុន្តែគេសួរអី ខ្ញុំឆ្លើយនុ៎ង។

**ស៖** តើ ថាតើលោកមានស្នើសុំ ឬក៏គេមានផ្តល់នូវសៀវភៅអ្វីដល់លោក ដើម្បីឱ្យលោកអានដែរឬទេ?

[១០:២១:០៧]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ដូចជាអត់ទេ។ នេះបើតាមខ្ញុំចាំ។ ទូលាយណាស់ បើចង់ច្បាស់សួរឯកសារណា ដែលគេផ្តល់ឱ្យ? កុំឱ្យវាទូលាយពាសវាលពាសកាលអ៊ីចឹង។ ខ្ញុំសូមលើកសំណូមពរនេះចំពោះលោកមេធាវី តាមរយៈអង្គជំនុំជម្រះ។

**ស៖** តើលោកមានអានសៀវភៅណាមួយនៅក្នុងពេលនោះ ឬក៏អាចថានៅពេលមុននៅពេលដែលលោកជាប់នៅពន្ធនាគារតុលាការយោធា? ហើយថាតើដែលផ្អែកទៅលើសៀវភៅនេះ គឺលោកអាចនឹងផ្អែកទៅលើសៀវភៅទាំងអស់នោះ?

**ឆ៖** ខ្ញុំគ្មានផ្អែកទៅលើសៀវភៅណាទេ។ ប៉ុន្តែដល់ក្រោយមកនេះ--

**ស៖** តើលោកមានធ្លាប់អានសៀវភៅអីដែរឬទេ? ខ្ញុំមិនសួរថាតើលោកផ្អែកមិនផ្អែកទេ ថាតើលោកធ្លាប់អានសៀវភៅអីដែរឬទេ?

**ឆ៖** អត់ទេៗ។

**ស៖** ដូច្នេះនៅពេលដែលលោកផ្តល់សក្ខីកម្មកាលពីពេលមុនទាក់ទងទៅនឹង នួន ជា លោកបាននិយាយថាលោកបានអានសៀវភៅមួយចំនួន។ តើលោកឆ្លើយខុសទៅនឹងសំណួរ ឬមួយក៏លោកមានភាពមិនស្មោះត្រង់ ដែលលោកបានផ្តល់សម្បថរួចទៅហើយនោះ?

[១០:២២:៤៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅលើសំណួរនេះ។ ខ្ញុំគិតថាសំណួរនេះវាមានលក្ខណៈច្របូកច្របល់។ ខ្ញុំយល់ថាសំណួរបន្ទាប់ហ្នឹង គឺថាវាមានលក្ខណៈច្របូកច្របល់។ សំណួរខាងដើមវាមានលក្ខណៈច្របូកច្របល់ ព្រោះថា ដំបូងសួរអំពីឯកសារទទួលបានតាមរយៈមេធាវី ឬក៏អត់នោះ? ប៉ុន្តែអ្វីដែលខ្ញុំយល់គឺថាមានលក្ខណៈច្បាស់លាស់ លោកសាក្សីបាននិយាយថាគាត់មានសិទ្ធិទទួលបាននូវ-- មានសិទ្ធិចូលទៅពិនិត្យនៅក្នុងសំណុំរឿង។

**លោក ម៉ៃខល កាណាវាស៖**

*(គ្មានការបកប្រែ)*

[១០:២៣:២២]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី កាណាវាស លោកអាចបង្អង់នៅក្នុងការប្រតិកម្មរបស់លោក ទុកឲ្យលទ្ធភាពឲ្យអ្នកបកប្រែអាចបកប្រែនូវគំនិតយល់ការស្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាចប់សព្វគ្រប់ជាមុនសិន សុំចាប់ផ្ដើមលោក ដើម្បីឲ្យការប្រតិចារឹកបានត្រឹមត្រូវ។ ហើយភាគីដែលពាក់ព័ន្ធនៅក្នុងរឿងក្ដីទាំងអង្គជំនុំជម្រះផងស្ដាប់បាននូវខ្លឹមសារជំទាស់តវ៉ា ហើយនិងការឆ្លើយតបរបស់លោកទៅនឹងការជំទាស់ មុននឹងផ្ដល់ថាអង្គជំនុំជម្រះសម្រេចលើបញ្ហាសំណួរនេះ ថាតើត្រូវឲ្យសួរ ឲ្យឆ្លើយ ឬក៏មិនបាច់ឲ្យឆ្លើយទេ។

សូមលោកតំណាងសហព្រះរាជអាជ្ញា ធ្វើការបង្ហាញអំពីសេចក្ដីជំទាស់របស់ខ្លួនសាជាថ្មីម្ដងទៀត។ ហើយអង្គជំនុំជម្រះសង្ឃឹមថាលោកមេធាវីយល់អំពីបញ្ហានៃការបកប្រែភាសាដេញដោលនៅក្នុងអង្គជំនុំជម្រះហើយ គឺយើងបាននិយាយច្បាស់ណាស់ថាឲ្យនិយាយឲ្យបានចប់ហើយ បង្អង់បន្តិចដើម្បីឲ្យភាគីមួយទៀតហ្នឹងអាចបន្តបាន ពីព្រោះដើម្បីឲ្យការបកប្រែហ្នឹងបញ្ចប់សព្វគ្រប់។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំ-- អ្វីដែលខ្ញុំចង់ធ្វើគឺថា មានសំណួរជាបន្តបន្ទាប់ដែលបន្តពីខាង

ដើមមក ដែលបានចោទសួរទៅលើសាក្សី។ ហើយសំណួរចុងក្រោយនេះ គឺបានដាក់នូវឃ្លាមួយដែលមិនផ្អែកទៅលើអ្វីដែលសាក្សីបានផ្តល់នោះទេ ដែលៗនិយាយថា សាក្សីគាត់មានការមិនស្មោះត្រង់។ ដូច្នេះ ខ្ញុំសូមជំទាស់នៅទៅនឹងអ្វីដែលបានលើកឡើង។ ព្រោះអ្វីដែលលើកឡើងនេះ គឺវាមិនផ្ទុះបញ្ចាំងពីអ្វីដែលបានឆ្លើយនៅក្នុងសំណួរខាងដើមនោះឡើយ។ ដូច្នេះខ្ញុំគិតថា ប្រហែលជាមានវិធីសាស្ត្រថ្មី ឬក៏វិធីសាស្ត្រផ្សេងៗទៀតដើម្បីចោទសួរ ថាតើលោកធ្លាប់អាន ឬក៏ពិនិត្យមើលទៅលើសំណុំរឿង?

[១០:២៥:៣១]

**លោក ម៉ែខល កាណាវាស៖**

លោកចៅក្រម លោកប្រធាន ខ្ញុំមានសិទ្ធិក្នុងការធ្វើការសួរដេញដោលទៅលើសាក្សី។

លោកសាក្សីតាមលោកបានស្បថរួចទៅហើយ ហើយនៅពេលដែលលោកផ្តល់សក្ខីកម្មទាក់ទងទៅនឹង នួន ជា លោកបាននិយាយថា លោកបានអានសៀវភៅបីក្បាល ហើយនៅពេលនោះលោកឆ្លើយថា "បាទ" ប៉ុន្តែថ្ងៃនេះលោកបែរនិយាយថា លោកអត់បានអានទេ។ ដូច្នេះ ខ្ញុំព្យាយាមឲ្យមានភាពយុត្តិធម៌ជាមួយនឹងសាក្សី ថាតើសាក្សីគាត់យល់ច្រឡំទៅលើសំណួរ ឬមួយក៏គាត់បង្ហាញភាពមិនត្រឹមត្រូវនៅពេលដែលគាត់ឆ្លើយទៅលើសំណួរទាំងអស់នេះ? ខ្ញុំផ្តល់ឱកាសដល់គាត់ ប៉ុន្តែប្រសិនបើនេះ ខ្ញុំអាចបន្តទៅមុខទៀតបាន។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** លោកសាក្សីនៅពេលដែលលោកជួបជាមួយនឹងចៅក្រមស៊ើប ហើយចៅក្រមស៊ើបបានស្នើឲ្យលោកផ្តល់នូវចម្លើយជាលាយលក្ខណ៍អក្សរ តើលោកបានពិភាក្សាជាមួយមេធាវីរបស់លោកដែរឬទេ អំពីអ្វីដែលត្រូវឆ្លើយ អំពីអ្វីដែលត្រូវរៀបរាប់?

[១០:២៦:៤២]

**លោក កាំង ហ្កេកអ៊ាវ៖**

ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំចង់រំឭករឿងមុននេះអំមិញបន្តិច។ បើលោកប្រធានអនុញ្ញាត ខ្ញុំសូមមេត្តារំឭក។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក កាំង ហ្គេកអ៊ាវ៖**

បញ្ហាទីមួយ គឺអំមិញហ្នឹងតែម្តង លោកមេធាវីសួរខ្ញុំ។ មុនខ្ញុំចូលទៅការិយាល័យសហចៅក្រមស៊ើបអង្កេត គេមានផ្តល់ឯកសារអីឲ្យខ្លះទេ? សូមបញ្ជាក់ថា ខ្ញុំនៅចាំច្បាស់ណាស់ពាក្យ "មុន"ៗៗ។ តាមពិតឯកសារទាំងអស់នោះគេឲ្យខ្ញុំអាន ជាបន្តបន្ទាប់ ហើយដល់និយាយមុនគឺវាអត់។ នេះសូមបញ្ជាក់បញ្ហានេះមួយ។

[១០:២៧:៣២]

ហើយបញ្ហាដំបូងមួយទៀត លោកមេធាវីសួរខ្ញុំ ថាមនុស្សដែលមានជាប់ចម្លើយនៅស-២១ វាមកនុំង មែន វាមកហ្នឹងមែន ក៏ប៉ុន្តែមិនមែនដោយចេះតែជាប់ ហើយចេះតែមកទេ។ ខ្ញុំសូមអានជូនសេចក្តីណែនាំរបស់ ប៉ុល ពត នៅក្នុងឯកសារលេខ E3/183--

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន គឺថាអ្វីគាត់និយាយ--

**លោក កាំង ហ្គេកអ៊ាវ៖**

ខ្ញុំសូមអានឲ្យចប់--

**លោក ម៉ៃខល កាណាវាស៖**

គឺថាគាត់ ដោយការគោរព ខ្ញុំសូមជម្រាបថា លោកសាក្សីមិនមែនជាអ្នកទទួលខុសត្រូវនៅមន្ទីរស-២១ ទេ នៅក្នុងតុលាការមួយនេះ គឺថាខ្ញុំមានសិទ្ធិក្នុងការចោទសំណួរ។ ដូច្នេះហើយខ្ញុំមានសិទ្ធិលើកនូវសំណួរនេះ។ គាត់អាចបញ្ជាក់ទៅលើចំណុចរបស់គាត់បាន។ ឥឡូវខ្ញុំសូមបន្តទៅមុខទៀត។

[១០:២៨:២១]

**ប្រធានអង្គជំនុំ៖**

ស្តាប់បានហើយសាក្សី! ហើយឯកសារដទៃទៀតទុកមួយដុំសិន ហើយចាំឆ្លើយតបនឹងសំណួរ ហើយចងចាំនូវអ្វីដែលយើងបានណែនាំ។ មិនត្រូវឆ្លើយតបទៅនឹងសំណួរ ដែលសំណួរដែលនាំឲ្យលោកធ្វើសេចក្តីសន្និដ្ឋានទេ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី ខ្ញុំសូមបញ្ជាក់លោកសាជាថ្មី ដើម្បីឲ្យដឹងថាលោកឆ្លើយបានត្រឹមត្រូវ។ ដូច្នេះតើចម្លើយរបស់លោកថា មុនពេលជួបជាមួយសហចៅក្រមស៊ើបអង្កេត ព្រមទាំងនៅក្នុងពេល

ផ្សេងៗទៀតក៏ដូចជានៅពេលដែលផ្តល់សក្ខីកម្មនៅទីនេះ គឺលោកមិនបានយោងទៅលើឯកសារណាមួយទេ ឬមួយក៏ថានៅពេលតែលើកទីមួយដែលលោកជួបជាមួយពួកគាត់ទាំងអស់នោះ?

[១០:២៩:២៣]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បញ្ហានេះខ្ញុំនិយាយអំមិញច្បាស់ហើយ។ មុនពេលដែលខ្ញុំចូលទៅជួបចៅក្រមស៊ើបអង្កេតអត់ទេ គ្មានឯកសារអីទេ។ ខ្ញុំធ្វើការផ្តល់ព័ត៌មានជូនសហចៅក្រមស៊ើបអង្កេតច្រើនខែ ច្រើនឆ្នាំ គេផ្តល់ឯកសារមកខ្ញុំបន្តបន្ទាប់។ នេះពិត។ គេផ្តល់ឯកសារមកខ្ញុំបន្តបន្ទាប់ដូច្នេះបើនិយាយខុសកាលពេលវេលា គឺមិនជាក់ស្តែង គឺខុស។

[១០:៣០:០០]

**ស៖** ដូច្នេះហើយ មានការត្រឹមត្រូវដែរឬទេ នៅពេលដែលយើងលើកឡើងថា តាមរយៈមេធាវីរបស់លោក លោកមានសិទ្ធិពិនិត្យមើលសំណុំរឿងដែលមាននៅ-- ពិនិត្យមើលឯកសារដែលមាននៅក្នុងសំណុំរឿងរបស់លោក។ តើពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** នេះភាសាច្បាប់ គេនិយាយម៉េច ខ្ញុំមិនដឹងទេ។ ប៉ុន្តែខ្ញុំនិយាយតាមជាក់ស្តែង ឲ្យតែចៅក្រមស៊ើបអង្កេតគាត់ប្រុងសួររឿងអី គាត់ផ្តល់ឯកសារនុ៎ងមកឲ្យខ្ញុំ។ ខ្ញុំចេះតែប៉ុននុ៎ង ហើយថាពីមុនមក មុនជួបគាត់ គេផ្តល់ឲ្យ អត់មានទេ។

**ស៖** ថាតើលោកពិនិត្យមើលឯកសារទាំងអស់នោះ ជាឯកសារក្រដាសនៅលើក្រដាស ឬក៏តាមរយៈប្រព័ន្ធអេឡិចត្រូនិក? បានន័យថា លោកមើលតាមប្រព័ន្ធកុំព្យូទ័រ ហើយចូលទៅមើលឯកសារនោះ តាមរយៈប្រព័ន្ធកុំព្យូទ័រ ឬក៏គេផ្តល់ឯកសារក្រដាសឲ្យលោកនោះ លោកមានសិទ្ធិពិនិត្យ និងអានមើលឯកសារទាំងអស់នោះ នៅលើក្រដាស?

**ឆ៖** ក្នុងរយៈកាលស៊ើបអង្កេត បើតាមខ្ញុំចាំ មកសុទ្ធតែជាក្រដាស ហើយនិងជាសៀវភៅបោះពុម្ព។

[១០:៣១:២០]

**ស៖** សំណួរចុងក្រោយមួយ មុនពេលដែលយើងឈប់សម្រាក ហើយសំណួរនេះ នឹងបញ្ចប់ប្រធានបទនេះមួយផងដែរ។ ខ្ញុំយល់ថា លោកមានសិទ្ធិទាក់ទង និងជជែកជាមួយនឹងអ្នកជំនាញមួយរូបដែលគាត់ស្ថិតនៅក្នុងក្រុមសាក្សីជំនាញរបស់លោក កាលពីពេលនោះ គឺលោក ដេវីដ ឆេនដ៍ល័រ។

តើពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ជាមួយ ដេវីដ ឆេនដ៍ល័រ អត់ទេ។ ខ្ញុំមកជួប ដេវីដ ឆេនដ៍ល័រ នៅក្នុងសវនាការ សំណុំរឿងលេខ០០១ ហ្នឹង! នៅក្នុងសម័យកាលស៊ើបអង្កេត គ្មានឃើញមុខ ដេវីដ ឆេនដ៍ល័រ ទេ។

[១០:៣២:២១]

**ស៖** ប្រហែលជាមានការបាត់នៅក្នុងការបកប្រែ។ លោក ម៉ាកចេនណា ដែលគាត់ជាអ្នកជំនាញមួយរូបនៅក្នុងក្រុមរបស់លោក។ ដូច្នេះ តើលោកមានធ្លាប់បាននិយាយជាមួយគាត់ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី ដែរឬទេ នៅពេលដែលៗនៅក្នុងនីតិវិធី តើលោកធ្លាប់ជួបពិភាក្សាជាមួយនឹងលោក រ៉ាអ៊ូល ម៉ាកចេនណា ដែរឬទេ?

**ឆ៖** មែន! ជាមួយសាស្ត្រាចារ្យ រ៉ាអ៊ូល ម៉ាកចេនណា ខ្ញុំជួប។ ជួប! ពិតជាជួប។

**ស៖** ក្នុងពេលដែលលោកជួបនោះ លោកបានពិភាក្សាបញ្ហាទាំងឡាយដែលពាក់ព័ន្ធនៅក្នុងរឿងក្តីរបស់លោក។ តើពិតជាត្រឹមត្រូវ ដែរឬទេ?

**លោក វីណ្ឌៀម ស្មីត៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

លោកសាក្សីកុំអាលឆ្លើយទៅនឹងសំណួរចុងក្រោយនេះ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំស្តាប់ឮពីសាក្សី ថាជួបជាមួយនឹង ចេនណា តែម្តង ដូចជាមិនច្រើនដងនោះទេ។ ដូច្នេះហើយ សូមឲ្យមេធាវីនោះ បញ្ជាក់សំណួរ ថាតើសាក្សីជួបតែម្តង ឬក៏ច្រើនដង?

[០៩:៣៣:៤៥]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តើលោកជួបតែម្តង ឬក៏ច្រើនដង ជាមួយនឹងលោក រ៉ាអ៊ូល ម៉ាកចេនណា ដែលគាត់ជាបុគ្គលមួយរូប នៅក្នុងក្រុមរបស់លោក? ហើយយើងដឹងហើយថា ទោះបីជាមិនបានជួបក្នុងរយៈពេលច្រើនខែក៏ដោយ។

[១០:៣៤:១៣]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** មុនសវនាការ ខ្ញុំដូចជាជួបបានតែម្តង។ នេះបើតាមខ្ញុំចាំ។ ដូចជួបបានតែម្តងប៉ុនន៎ុងឯង ឬក៏ពីរដងយ៉ាងច្រើន។ អ្វេ! ដូចជាម្តង។ នេះ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**សៈ** គោលបំណងនៃការប្រជុំនោះ គឺដើម្បីឲ្យលោកពិភាក្សាជាមួយគាត់លើបញ្ហាដែលពាក់ព័ន្ធនៅក្នុងរឿងក្តីរបស់លោក។ តើពិតជាអ៊ីចឹងទេ ឬក៏មិនមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំភ្លេចទៅហើយ ខ្ញុំមិនចាំទេ។ គ្រាន់តែខ្ញុំបានជម្រាបសាស្ត្រាចារ្យ វ៉ាអ៊ូល ម៉ាកចេនណា អំពីអត្ថន័យនៃទង់ផ្កាយប្រាំរបស់បក្សកុម្មុយនីស្ត-- អ៊ំន៎េ! របស់សាធារណរដ្ឋប្រជាមានិចិន ហើយពេលន៎ុង ខ្ញុំសូមសៀវភៅគាត់មួយ។ សៀវភៅហ្នឹងឈ្មោះថា "និវេទបក្សកុម្មុយនីស្ត" រៀបរៀងឡើងដោយ ម៉ាក្ស និង អង់ហ្គេល។ គាត់ឲ្យខ្ញុំ។ នេះឯកសារហ្នឹងនៅនឹងផ្ទះបន្ទប់ខ្ញុំ។ នេះរឿងរ៉ាវដែលខ្ញុំធ្លាប់បានពិភាក្សាជាមួយនឹងសាស្ត្រាចារ្យ វ៉ាអ៊ូល ម៉ាកចេនណា ប៉ុណ្ណឹង។

[១០:៣៥:២៦]

**សៈ** សូមអរគុណលោកសាក្សី។ លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំមើលនាឡិកាហើយគិតថា ពេលនេះប្រហែលជាអាចជាពេលសមស្របយើងសម្រាកសិនទៅ។ យើងខ្ញុំបានបញ្ចប់ប្រធានបទត្រង់ចំណុចនេះរួចហើយ ហើយបន្ទាប់មក គឺយើងខ្ញុំនឹងសួរសំណួរប្រធានបទមួយទៀត។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះទៅ រហូតដល់ម៉ោងដប់មួយខ្វះប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ អនុរក្សមន្ទីរឃុំឃាំងឲ្យអញ្ជើញសាក្សីទៅកន្លែង ទៅតាមបន្ទប់សម្រាកសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅម៉ោងដប់មួយខ្វះប្រាំនាទី។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម លោកអៀង សារី ថ្ងៃនេះស្នើសុំលះបង់សិទ្ធិ

ក្នុងការចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ សម្រាប់ថ្ងៃនេះពេញតែម្តង។ ប៉ុន្តែសូមចូលរួមដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោម។ នេះអាស្រ័យដោយហេតុថា បញ្ហាសុខភាព ជាពិសេសបញ្ហាចង្កេះ ខ្នង និងជើងរបស់គាត់ ដែលគាត់ពិបាកក្នុងការទ្រាំអង្គុយនៅទីនេះ។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាពិចារណា និងសម្រេច។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំលះបង់សិទ្ធិមិនចូលរួមតាមដានកិច្ចដំណើរការសវនាការផ្ទាល់ក្នុងបន្ទប់សវនាការនេះ សម្រាប់ពេលវេលាបន្ទាប់តទៅ រហូតដល់ពេញមួយថ្ងៃនេះ ដោយសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីប្រព័ន្ធសោតទស្សន៍ ពីបន្ទប់ឃុំខ្លួនមួយនៅខាងក្រោមបន្ទប់សវនាការ ដោយមូលហេតុបញ្ហាសុខភាព មិនអាចអង្គុយតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ-- ពីដោយផ្ទាល់បាន។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិមិនចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយនៅខាងក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍ពេញមួយថ្ងៃ ចាប់ពីពេលនេះតទៅ។ តែអង្គជំនុំជម្រះតម្រូវក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ប្រគល់មកអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមមេដៃរបស់ជនជាប់ចោទ។

និងបង្គាប់ឲ្យផ្នែកខាងសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់ ចាប់ពីពេលនេះទៅរហូតដល់ចប់សវនាការថ្ងៃនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ខាងក្រោម ដែលមានរៀបចំនូវប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៨ នាទី ដល់ម៉ោង ១០:៥៨ នាទី)*

[១០:៥៨:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានលទ្ធភាពបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ហើយសូមគោរពដល់ប្រិយមិត្តទាំងអស់។ ដូច្នេះខ្ញុំសូមជម្រាបថា កិច្ចដំណើរការនីតិវិធីប្រព្រឹត្តឡើងទៅតាមដំណើរការ។ មុននឹងខ្ញុំចាប់ផ្តើមលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំមានឯកសារមួយចំនួនដែលខ្ញុំរៀបចំជាដុំៗរួចទៅហើយ។ ហើយឯកសារនេះអាចជួយសម្រួល ប្រសិនបើយើងផ្តល់ឯកសារនេះទាំងដុំទៅមន្ត្រីតុលាការ ដើម្បីកុំឲ្យគាត់ដើរទៅដើរមក ទាំងអស់បែបនេះ។ បានន័យថា គឺខ្ញុំចង់ផ្តល់មកឯកសារមួយដុំទៅដល់លោកមន្ត្រីតុលាការ ហើយនិងឯកសារមួយដុំទៅដល់មេធាវី ដើម្បីជួយសម្រួល។

[១១:០០:១២]

ដូច្នេះ ខ្ញុំស្នើសុំថាផ្តល់ឯកសារមួយដុំដំបូងទៅមន្ត្រីតុលាការ បន្ទាប់មកខ្ញុំនឹងហៅនូវលេខប្រសិនបើលោកប្រធាន លោក លោកស្រីចៅក្រមអនុញ្ញាត ដើម្បីអាចប្រគល់ទៅដល់សាក្សី។ ហើយខ្ញុំក៏បានផ្តល់នូវបញ្ជីនៃឯកសារទាំងអស់នេះ ហើយឯកសារនេះបានបង្ហាញនូវផ្នែកបានគូស នូវផ្នែកដែលយើងខ្ញុំចង់ឲ្យសាក្សីផ្តោតទៅលើផ្នែកទាំងអស់នោះ ទាំងនៅក្នុងឯកសារជាក្រដាស ក៏ដូចជាឯកសារនៅលើកុំព្យូទ័រ ដើម្បីបញ្ជាក់ថា តើឯកសារនេះគាត់ធ្លាប់ឃើញក៏អត់? ថាតើគាត់ធ្លាប់ពិនិត្យមើល? ហើយឯកសារជាច្រើនត្រូវបានបង្កើតឡើងដោយលោកសាក្សី ឬដោយមានការជំនួយពីលោកសាក្សី។ ដូច្នេះប្រហែលជាមិនមានការជំទាស់ពីភាគីណាមួយនោះទេ។ ប្រសិនបើមិនមានការជំទាស់ទេខ្ញុំសូមបន្ត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត មន្ត្រីរដ្ឋបាលតុលាការអញ្ជើញយកឯកសារពីមេធាវី! ហើយលំហូរនីតិ

វិធីនៃការបង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍ដូចគ្នា គឺនៅពេលដែលមេធាវីចាប់ផ្ដើមបង្ហាញនូវឯកសារ សូមជំនួយការដាក់បញ្ចាំងឯកសារនោះនៅលើអេក្រង់ទូរទស្សន៍តែម្ដងទៅ ដើម្បីពន្លឿនកិច្ចពិភាក្សារបស់យើង។ លើកលែងតែឯកសារណាដែលមានការជំទាស់ ដោយមូលហេតុផ្សេងដែលអង្គជំនុំជម្រះ-- ទាមទារឲ្យអង្គជំនុំជម្រះសម្រេចជាមុន។

សូមអញ្ជើញលោកមេធាវី!

[១១:០២:០១]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសង្ឃឹមថាដំណើរការរបស់យើងដើរទៅដោយរលូន។ ហើយនេះគឺជាសវនាការលើកទីមួយរបស់ខ្ញុំនៅក្នុងតុលាការមួយនេះ។ ដូច្នេះខ្ញុំសូមបង្ហាញដល់លោកសាក្សីនូវឯកសារដែលមានលេខ E118-- 180 សូមអភ័យទោស ប្រសិនបើជាតុលាការអនុញ្ញាត ខ្ញុំសូមផ្ដល់គឺឯកសារបង្ហាញពីការសិក្សារបស់មេធាវី គឺមេរៀនដកស្រង់បទពិសោធន៍នៃចាស់ទុំជំនាន់មុន។ យើងអាចនិយាយបានថាឯកសារមួយនេះ គឺជាឯកសារដែលលោកបាននិពន្ធបានតាក់តែងឡើង។ តើត្រឹមត្រូវដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ឆ្លើយតប-- សាក្សីឆ្លើបតបនឹងសំណួររបស់មេធាវី!

[១១:០៣:១៥]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះជាឯកសារដែលខ្ញុំបានចងក្រងឡើង។

**លោក ម៉ៃខល កាណាវាស៖**

*(និយាយមិនបើកមីក្រូហ្វូន)*

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យលោកមេធាវី បើកមីក្រូ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោករៀបចំឯកសារនេះ ប្រហែលជា១មួយខែមុន តើត្រឹមត្រូវដែរទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ឯកសារនេះ ខ្ញុំជូនតុលាការ។ តុលាការទទួលនៅថ្ងៃ១២ ខែមីនា ដូច្នេះខ្ញុំដូចជាបញ្ចប់ឯកសារនេះនៅថ្ងៃ៩ ខែមីនា។

[១១:០៥:១៤]

**ស៖** សូមអរគុណ។ ប្រសិនបើលោកបើកមើលឯកសារនេះ ទៅទំព័រទីមួយ ហើយឯកសារជាភាសាអង់គ្លេសគឺ 00791977 ហើយភាសាខ្មែរ 00787937 ហើយភាសាបារាំង 00792666-- 696 សូមអភ័យទោស 696។ តើលោកបានបើកទំព័រនេះហើយឬនៅលោកសាក្សី?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំបើកហើយ។

**ស៖** ឥឡូវនេះ យើងឃើញថា គឺជាសេចក្តីផ្តើមពីអ្នកសិក្សាស្វែងយល់ម្នាក់។ ហើយអ្នកសិក្សាស្វែងយល់ហ្នឹង គឺសំដៅទៅលើលោក តើមែនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន អ្នកសិក្សាស្វែងយល់ម្នាក់នេះ គឺខ្ញុំ។

**ស៖** ប្រសិនបើលោកមើលទៅលើពាក្យពេចន៍ដំបូងគឺនិយាយថា អត្ថបទតទៅនេះ ចងក្រងឡើងអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលបានជួបប្រទះ បានដឹងឮ បានស្រាវជ្រាវ ហើយវិភាគ និងសរុប តើត្រឹមត្រូវដែរឬទេ?

[១១:០៥:៥៨]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ត្រឹមត្រូវ។

**ស៖** ហើយតើវាត្រឹមត្រូវដែរឬទេ ដែលថា អ្វីដែលលោកធ្វើឡើងហ្នឹងក្នុង-- គឺគេថា លោកបានធ្វើការវិភាគ ហើយនិងសរុបទៅលើ-- ដោយផ្អែកទៅលើឯកសារ ដែលលោកមាន ដូចជាសៀវភៅដែលលោកបានពិនិត្យ ដែលបានសិក្សាពីមុនមក។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះ ខ្ញុំចងក្រងឡើង មិនមែនតែតាមសៀវភៅទេ ដូចខ្ញុំបញ្ជាក់អ៊ីចឹង។ តាមព្រឹត្តិការណ៍ ដែលខ្ញុំបានជួបប្រទះ ដែលខ្ញុំបានដឹងឮ ហើយដែលខ្ញុំបានស្រាវជ្រាវ។

**ស៖** ដូច្នេះ ខ្ញុំចង់ផ្តោតទៅលើ-- អ្វីដែលខ្ញុំចង់ផ្តោតទៅលើគឺថា យើងយល់ទាំងអស់គ្នាថា អ្វីដែលលោកសរសេរហ្នឹង មួយផ្នែកគឺពឹងផ្អែកទៅលើអ្វីដែលលោកបានអាន អ្វីដែលលោកបានស្រាវជ្រាវ អ្វីដែលលោកបានវិភាគ ហើយនិងចុងក្រោយគឺលោកបានសរុប។ តើត្រឹមត្រូវដែរឬទេ?

[១១:០៧:២៤]

**ឆះ** ជម្រាបប្រសាសន៍លោកប្រធាន គឺត្រឹមត្រូវហើយ។

**សះ** សូមអរគុណ។ ឥឡូវនេះ យើងសូមប្ដូរទៅឯកសារថ្មីមួយទៀត គឺឯកសារ E1/51.1 ហើយឯកសារនេះ គឺជាប្រតិចារឹកថ្ងៃ២០ ខែមីនា ឆ្នាំ២០១២ ហើយយើងសូមបន្តទៅ ERN *ណាំបឺ* លេខ 00791941 ទៅដល់ 42 ហើយភាសាអង់គ្លេសគឺ 00793004 ហើយភាសាបារាំងគឺ 00793092 ដល់ 93។ ហើយនៅក្នុងឯកសារនេះ គឺជាប្រតិចារឹក ហើយខ្ញុំដឹងថា សំណួរនេះបានសួរទៅលោកម្ដងហើយ ហើយលោកនិយាយថា នៅជួរទី២០ "ទោះបីជាយ៉ាងណាក៏ដោយប្រសិនបើយើងចង់ឲ្យខ្ញុំនិយាយតែអ្វីដែលខ្ញុំដឹង នៅពេលនោះ ខ្ញុំខ្លាចថា ខ្ញុំគ្មានអ្វីនឹងឆ្លើយជូនជាតិប្រជាជន ថាពេលនុំងព្រោះថា ខ្ញុំស្ថិតក្នុងតែ-- ព្រោះៗការយល់ដឹងរបស់ខ្ញុំនៅត្រឹមតែស-២១ទេ"។

[១១:០៩:៣៧]

**ឆះ** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំដូចអត់ឮលោកមេធាវីសួរខ្ញុំថាម៉េចផង អត្ថបទនេះ គឺពិតជាអានអ៊ីចឹងមែន។ បើនិយាយតែពីហ្នឹង យកការយល់ដឹងពេលហ្នឹងមកនិយាយ ខ្ញុំគិតថា ដូចជាគ្មានស្អីហ្នឹងឆ្លើយជូនជាតិប្រជាជនទេ។ នេះខ្ញុំនិយាយអ៊ីចឹងមែន ហើយប៉ុន្តែដល់លោកមេធាវីដូចជាមិនឮសួរខ្ញុំថាម៉េចផង។

**សះ** ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា នេះគឺជាអ្វីដែលលោកបាននិយាយ គឺខ្ញុំគ្រាន់អានដើម្បីបញ្ជាក់។ តើលោកពិតជាគាំទ្រថានេះជាអ្វីដែលលោកបានអះអាង តើមែនដែរឬទេ? តើលោកនៅតែរក្សាសម្ដីបែបនេះដែរឬទេ?

**ឆះ** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំរក្សា សម្ដីនេះខ្ញុំរក្សា មិនមែនដោយសារចុះនឹងប្រតិចារឹកទេ តែពិតគឺវាអ៊ីចឹង។

**សះ** នៅពេលដែលលោកនិយាយថា លោកដឹងត្រឹមតែស-២១ នោះ ប្រសិនបើយើងផ្ទុះបញ្ចាំងត្រឡប់មកវិញ អំពីជីវិត និងការរស់នៅសមមិត្ត ឌុច។ ដូច្នេះអ្វីដែលលោកដឹងគឺត្រឹមតែទៅផ្ទះមកស-២១ ហើយទៅផ្ទះ តើត្រឹមត្រូវដែរឬទេ?

[១១:១១:១៥]

**ឆះ** ជម្រាបប្រសាសន៍លោកប្រធាន ការងារនៅស-២១ វាច្រើន វាមានកូនទាហានរបស់វា វាមានការរៀនសូត្រវគ្គ។ តាមពិតហើយ ខ្ញុំដើបឡើងអត់បានចេញពីផ្ទះទៅណាទេ គឺនៅនឹងផ្ទះខ្ញុំ ខ្ញុំអាន

ឯកសារ។ នេះការងារផ្ទាល់ខ្លួនរបស់ខ្ញុំ។ ពីម៉ោងប្រាំពីរព្រឹករហូតដល់ម៉ោងដប់ មួយដណ្តប់ ចូនអីពីរដណ្តប់ ម៉ោងមួយយប់។ ក៏ប៉ុន្តែស-២១ វាមានស្អីៗផ្សេងពីនុ៎ងទៀត។ បើអ្នកហ្នឹងនិយាយត្រឹមតែទៅផ្ទះធ្វើទៅការពីធ្វើការមកផ្ទះ មិនមែនទេ។ កន្លែងធ្វើការគឺ កន្លែងផ្ទះខ្ញុំហ្នឹងឯង។ ក៏ប៉ុន្តែស-១២ វាមានអង្គភាពរបស់វា វាមានការងាររបស់វា វាមានការយល់ដឹងរបស់វា វាមានការរៀនសូត្ររបស់វា។

**ស៖** ប៉ុន្តែខ្ញុំនិយាយអំពីសមមិត្ត ឌុច។ លោកនិយាយថា លោកមិនអាចជិះដើរលេងជុំវិញទីក្រុងភ្នំពេញទេ។ តើត្រឹមត្រូវដែរឬទេ?

[១១:១២:២៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយតបនឹងសំណួរ!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន នេះមិនមែនជាភស្តុតាងរបស់សាក្សីនោះទេ ហើយអ្វីដែលមេធាវីគាត់ឮ គឺថាគាត់បានចូលរួមកិច្ចប្រជុំជាមួយនិងថ្នាក់លើជាមួយមេដឹកនាំ គឺ នួន ជា ហើយគាត់បានចូលរួមកិច្ចប្រជុំប្រហែលជាពីរទៅបួនប្រាំថ្ងៃ ក៏ដូចជាជួបជាមួយនិងរដ្ឋមន្ត្រី សុន សេន ជាដើម។--

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** លោកប្រធាន ខ្ញុំសូមកែដូច្នេះ រួមបញ្ចូលទាំងកិច្ចប្រជុំដែលលោកបានចូលរួម ថាតើលោកអាចលោកអាចជិះកង់ ឬក៏ជិះម៉ូតូ ឬក៏ជិះស៊ីក្លូ ឬក៏តាក់ស៊ី ឬក៏បើកឡានដោយខ្លួនឯង ដើម្បីដើរលេងទៅតាមទីកន្លែងដែលលោកចង់ ដែលលោកប្រាថ្នាទៅនៅក្នុងក្រុងភ្នំពេញ ឬក៏នៅកន្លែងផ្សេង។ តើលោកអាចធ្វើបានដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ជាទូទៅកម្មាភិបាលទាំងអស់រួមទាំងខ្ញុំផង គ្មានសិទ្ធិដើរទេ។ ដើរគឺបំពេញភារកិច្ច បើក្រៅពីភារកិច្ចកុំដើរ។ នេះជាការពិត។

[១១:១៣:៥២]

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណ។ ឥឡូវនេះ យើងមើលឯកសារ D90។ ប្រសិនបើលោកចៅក្រមអនុញ្ញាតគឺថា

ព្រោះថាឯកសារទាំងអស់មិនមែនសុទ្ធតែមានលេខ E ទាំងអស់នោះទេ។ ដូច្នេះប្រហែលជាមានកំហុស ឬក៏មានការប្រែប្រួលណាមួយតាមដែលខ្ញុំដឹង។ នេះ គឺជាឯកសារមួយដែលមានបញ្ហាបែបនេះ គឺឯកសារ D90។ ប្រសិនបើលោកមើលទៅលើឯកសារនោះ។

**សួរដោយលោក ម៉ែខល កាណាវាស៖**

លោកសាក្សី លោកនឹងឃើញនៅទំព័រទី១ ហើយខ្ញុំសូមប្រគល់នូវកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៅថ្ងៃ២៥ ខែ៦ ឆ្នាំ២០០៨ ហើយលោកអាចយោងទៅលើឯកសារជាភាសាខ្មែរ ERN 00198873។ ភាសាអង់គ្លេស 00198882 ភាសាបារាំងគឺ 00198890។ ខ្ញុំចង់ឲ្យលោកផ្ដោតទៅលើផ្នែកទីមួយនៃចម្លើយរបស់លោក ដែលលោកបង្ហាញថាខ្ញុំជា១ដំបូងខ្ញុំត្រូវបញ្ជាក់ថាពេលនេះ នៅក្នុងពេលនេះ ខ្ញុំមានការយល់ដឹងច្រើនជាងនៅខែសីហា ឬខែធ្នូ កន្លងទៅ។ តាមពិតទៅនៅពេលដែលខ្ញុំបានដឹងបន្តិចម្ដង១ពីសំណុំរឿង ខ្ញុំយល់កាន់តែច្បាស់ពីរចនាសម្ព័ន្ធនៃរបបនោះ។ តើលោកចាំដែរឬទេ ថាលោកបានផ្ដល់នូវចម្លើយបែបនេះ? ហើយថាតើលោកនៅរក្សាពាក្យសម្ដីរបស់លោកដោយដូចជាចំណុចមួយនេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បើឲ្យចាំ១មិនច្បាស់ទេ ក៏ប៉ុន្តែបើនិយាយពីរក្សា ខ្ញុំពិតជារក្សា។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះយើងពិនិត្យមើលទៅលើឯកសារបន្ទាប់ប្រសិនបើលោកតុលាការអនុញ្ញាត គឺ D238 គឺជាកំណត់ហេតុស្ដាប់ចម្លើយ កំណត់ហេតុសួរចម្លើយមួយទៀតនៅថ្ងៃ១០ ខែវិច្ឆិកា ឆ្នាំ២០០៨។

[១១:១៦:៥៧]

លោកសាក្សី ខ្ញុំចង់ឲ្យលោកផ្ដោតទៅលើឯកសារ ERN 00403882 ជាភាសាខ្មែរ ភាសាអង់គ្លេសគឺ 00403893 និងភាសាបារាំងគឺ 00403903 គឺនៅទំព័រចុងក្រោយ។

ហើយខ្ញុំចង់ផ្ដោតទៅលើសំណួរ ហើយសំណួរនោះវាជាផ្នែកមួយនៃចម្លើយផងដែរ។ គឺមានសំណួរដែលចោទសួរថា តើលោកអាចបញ្ជាក់អំពីពេលវេលា និងមូលហេតុដែលភូមិភាគកណ្ដាល និងភូមិឧត្ដរថ្មីត្រូវបានបង្កើតទេ? ហើយចម្លើយរបស់លោក គឺនិយាយថា "ខ្ញុំ១ សូមអានអត្ថបទទាក់ទងនឹងកែ ពក សិនមុននឹងឆ្លើយ"។ តើលោកចាំថាលោកបានផ្ដល់ចម្លើយបែបនេះដែរឬទេ? ហើយថាតើលោកនៅរក្សាពាក្យសម្ដីរបស់លោកបែបនេះដែរឬទេ?

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន នៅចាំ ហើយខ្ញុំរក្សាចម្លើយនេះ។

[១១:១៨:៤៣]

**ស៖** ដូច្នេះដើម្បីឲ្យច្បាស់ គឺខ្ញុំចង់បញ្ជាក់ឡើងវិញ លោកចង់ពិនិត្យមើលទៅលើឯកសារមុននឹងលោកឆ្លើយទៅនឹងសំណួរដែលបានដាក់មកលោក។ បានន័យថា សំណួរដែលសហចៅក្រមស៊ើបអង្កេតបានសួរលោក តើមែនដែរឬទេ?

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន ថ្ងៃនុ៎ងមែន ខ្ញុំសុំបទសម្ភាសន៍របស់ បងពក មកអានសិន។

**ស៖** សូមអរគុណ។ ឥឡូវនេះប្រសិនបើលោកមើលទៅលើឯកសារ D86/27 ប្រសិនបើលោកតុលាការអនុញ្ញាត គឺជាកំណត់ហេតុសួរចម្លើយថ្ងៃ០៥ ខែ០៥ ឆ្នាំ២០០៨។

ហើយខ្ញុំសូមឲ្យលោកចាប់អារម្មណ៍ទៅលើពីរផ្នែកនៃចម្លើយរបស់លោក ដែលលោកបាននិយាយថា ខ្ញុំខ្លួនខ្ញុំផ្ទាល់មិនដឹង អំពីការងាររបស់អ្នកដទៃនោះឡើយ។ ហើយតាមគំនិតបែបនេះ គឺថាយើងមិនអាចទាញសេចក្ដីសន្និដ្ឋានថា របបនោះ គឺ-- មិនអាចសន្និដ្ឋានថារបបនោះជារបបឧក្រិដ្ឋ ដោយគ្រាន់តែដឹងថា ឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តនៅស-២១ នោះប៉ុណ្ណោះទេ។ ថាតើលោកចាំបានដែរឬទេថាលោកបានផ្ដល់ចម្លើយនេះ? ហើយលោកនៅតែរក្សាចម្លើយបែបនេះ? ថាតើលោកពិតជាមិនដឹងអំពីការងារអ្នកដទៃនោះ? តើមែនដែរឬទេ?

[១១:២១:០៣]

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះគឺឯកសារឆ្នាំ២០០៨ ខែឧសភា។ ការយល់ដឹងរបស់ខ្ញុំនៅក្នុងឆ្នាំមួយពាន់-- ២០០៨ ខែឧសភា គឺនៅអ៊ីចឹង ត្រឹមកម្រិតហ្នឹង។

**ស៖** ដូច្នេះលោកឆ្លើយសំណួរហ្នឹងផ្អែកទៅលើចំណេះដឹងនៅពេលនោះ។ បានន័យថា នៅពេលនោះលោកមិនទាន់មានលទ្ធភាពពិនិត្យទៅលើឯកសារដទៃទៀតនោះ។ តើត្រឹមត្រូវដែរឬទេ?

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន ពេលនុ៎ងខ្ញុំអត់មានបានពិនិត្យទៅលើឯកសារដទៃទៀតមែន ហើយក៏ការយល់ដឹងរបស់ខ្ញុំពីសភាពការណ៍រួម ក៏នៅមានកម្រិត។

**ស៖** ដូច្នេះយើងសូមបន្តទៅទំព័រមួយទៀត គឺខ្មែរ ERN មានលេខ 00187654 ដល់ 55 ភាសាអង់គ្លេស គឺ 00204343 ហើយភាសាបារាំង គឺ 00177616 ដល់ 00177617។ ហើយខ្ញុំចង់ឲ្យលោកចាប់អារម្មណ៍ទៅលើផ្នែកមួយនៃចម្លើយរបស់លោក ដែលលោកនិយាយថា "ដូច្នេះ រហូតមក

ដល់ចំណុចនៃការស៊ើបអង្កេតមួយនេះ ខ្ញុំព្យាយាមដោយមានវត្តមានរបស់មេធាវីរបស់ខ្ញុំ ឆ្លើយទៅនឹងគ្រប់សំណួររបស់លោកចៅក្រម។ ដូច្នេះខ្ញុំចាត់ទុកសេចក្ដីប្រកាសនៅ យូ.អ៊ិន.អេច.ស៊ី.អ័រ ខ្ញុំគិតថា វាគួរតែអានថា យូ.អ៊ិន.អេច.ស៊ី.អ័រ គឺជារឿងអតីតកាល និងមិនមានប្រយោជន៍អ្វីទេនាពេលនេះ”។ តើលោកឃើញផ្នែកនេះដែរឬទេ? តើលោកឃើញចម្លើយរបស់លោកនេះដែរឬទេ? ដែលថាដូច្នេះខ្ញុំចាត់ទុកសេចក្ដីប្រកាសនៅ យូ.អ៊ិន.អេច.ស៊ី.អេច.អ័រ ជារឿងអតីតកាល និងមិនមានប្រយោជន៍អ្វីទេនៅពេលនេះ។ តើលោកបានឃើញផ្នែកនេះដែរឬទេ?

[១១:២៣:៥១]

**ឆ៖** ជម្រាបប្រសាសន៍ ខ្ញុំឃើញ។

**ស៖** ថាតើវាអាចជារឿងអតីតកាលដែរឬទេ ដោយសារនៅពេលនោះ នៅពេលដែលលោកឆ្លើយសំណួរនៅពេលដែលលោកប្រកាសនៅអង្គការនោះ គឺលោកមិនទាន់បានចូលទៅក្នុង-- មិនទាន់បានពិនិត្យឯកសារដែលបានផ្ដល់នៅពេលក្រោយមកជូនលោក? គឺឯកសារដែលផ្ដល់ដោយមេធាវីរបស់លោកនៅក្នុងសំណុំរឿងរបស់លោក។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមបញ្ជាក់ នេះជាគោលគំនិតរបស់ខ្ញុំចំពោះកំណត់ហេតុដែលដកស្រង់ចេញពីខ្សែអាត់ ដែលខ្ញុំបដិសេធ។ កំណត់ហេតុដែល យូ.អ៊ិន.អេច.ស៊ី.អេច.អ័រ ចម្លងអំពីខ្សែអាត់របស់ខ្ញុំមកក្នុងក្រដាស ហើយឲ្យខ្ញុំអាន។ ដូច្នេះបញ្ហាហ្នឹង ដែលខ្ញុំនិយាយថា រឿងវាចាស់ទៅហើយ។ ឯរឿងថ្មី គឺយើងនិយាយគ្នាតទៅទៀតជាមួយនឹងចៅក្រមស៊ើបអង្កេត។

[១១:២៥:១១]

**ស៖** ដូច្នេះ យើងអាចនិយាយបានថា ចម្លើយរបស់លោកគឺចង់និយាយថា គឺចម្លើយដែលបង្ហាញ-- ដែលផ្ដល់នៅពេលនោះ គឺវាហួសសម័យ ព្រោះថាចំណេះដឹងរបស់លោកគឺនៅពេលនោះ វាមានដែនកំណត់ បើធៀបជាមួយនឹងចំណេះដឹងរបស់លោកដែលមានការរីកចម្រើន ក្រោយពេលដែលលោកបានអានឯកសារនានា ដែលមេធាវីរបស់លោកបានផ្ដល់ឲ្យ។ តើមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ពាក្យមួយឃ្លានេះគឺជាពាក្យដែលខ្ញុំវាយតម្លៃទៅលើកំណត់ដៃ ដែលគេដកស្រង់ចេញពីខ្សែអាត់។ វាយតម្លៃទៅលើកំណត់ដៃ ដែលគេដកស្រង់ចេញពីខ្សែអាត់ មិនមែនវាយតម្លៃអំពីសមត្ថភាពខ្លួនខ្ញុំទេ។

[១១:២៦:០៦]

**ស៖** សូមអរគុណ។ ឥឡូវនេះ សូមលោកពិនិត្យឯកសារ D427 ខ្ញុំសូមរំលងឯកសារមួយចំនួន ដើម្បីកុំឱ្យខាតពេល។ គឺឯកសារ D427 គឺជាឯកសាររបស់ដីកាដំណោះស្រាយ ហើយចំណុចពិសេស ដែលខ្ញុំចង់លើកឡើងនុ៎ង គឺខ្ញុំចង់ឱ្យលោកធ្វើការវាយតម្លៃ គឺឯកសារជាភាសាខ្មែរ 00605535 ភាសាអង់គ្លេស គឺ 00604723 ភាសាបារាំង គឺ 00674366។

[១១:២៧:០៨]

ខ្ញុំយោងទៅលើកថាខណ្ឌ៨៧៣ ខ្ញុំគិតថាដូចគ្នាទាំងភាសាបារាំង ខ្មែរ និងអង់គ្លេស ដែលវានិយាយថា ឌុច បានប្រាប់ថា នួន ជា ជាសមាជិករបស់គណៈកម្មការនេះ។ ប៉ុន្តែមិនច្បាស់លាស់ទេ ថាគាត់បានដឹងរឿងនេះ តាំងពីសម័យនោះមក ឬទើបតែដឹង នៅពេលដែលគាត់បានចូលមើលឯកសារនៅក្នុងសំណុំរឿង។ ដូច្នេះ ខ្ញុំសូមចោទសំណួរដ៏សាមញ្ញមួយទៅលោក ថាតើលោកយល់ស្រប ឬក៏មិនយល់ស្របជាមួយនឹងការវាយតម្លៃបែបនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ការវាយតម្លៃបែបនេះ ដូចជាមិនចំទេ ពីព្រោះខ្ញុំឆ្លើយជាមួយសហចៅក្រមស៊ើបអង្កេត។ នេះខ្ញុំ បើសុំអនុញ្ញាតរំឮកឡើងវិញ អំពីតួនាទីរបស់ បងនួន នៅក្នុងគណៈកម្មាធិការយោធាជាន់ខ្ពស់របស់បក្ស។ បងនួន គាត់ឆ្លើយថា គណៈកម្មាធិការយោធាជាន់ខ្ពស់របស់បក្សមានប្រាំរូប។ ទីមួយ គឺប៉ុល ពត, ទីពីរ គឺសោ ភឹម, ទីបី គឺតាម៉ុក, ទីបួន គឺសុន សេន, ទីប្រាំ គឺកែ ពក។ ខ្ញុំថាមិនមែនទេ គាត់និយាយនេះជិតត្រូវហើយ។ ក៏ប៉ុន្តែគាត់ផ្លាស់ គាត់មិននិយាយរូបគាត់ គាត់ទៅបែរដែរ-- បែរដាក់ សោ ភឹម។ ឯចំណែក បងភឹម អ្នកណាជឿទុកចិត្ត! ប៉ុល ពត ក៏មិនជឿទុកចិត្ត បងភឹម បងនួន ខ្លួនគាត់ហ្នឹង ក៏មិនជឿទុកចិត្ត បងភឹម។ នេះ ខ្ញុំនិយាយអ៊ីចឹង។ ហើយម្យ៉ាងទៀត--

[១១:២៨:១៥]

**ស៖** ខ្ញុំសូមកាត់លោកសាក្សី គឺថាយើងនៅមានសំណួរ។ ឥឡូវនេះ សូមលោកមើលទៅលើឃ្លាមួយទៀត នៅក្នុងកថាខណ្ឌ៨៧៧ គឺERN 00605537 ភាសាអង់គ្លេស គឺ00604725 និងបារាំង គឺ 00624368 ហើយនៅក្នុងនេះ គឺក្នុងដីកាដំណោះស្រាយ ដែលជាមតិរបស់-- ដែលគំនិត-- ដែលជាចម្លើយ-- មិនភាពច្បាស់លាស់ទេថា តើការដឹងឮ និងការយល់ដឹងរបស់ ឌុច អំពីរចនាសម្ព័ន្ធឋានានុក្រម ដែលនៅពីលើគាត់បានកើនដល់កម្រិតណា បន្ទាប់ពីគាត់បានចូលមើលឯកសារនៅក្នុងសំណុំរឿង។ នេះគឺជាការលើកឡើងរបស់សហចៅក្រមស៊ើបអង្កេត គឺជាអ្វីដែលលោកសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់។ តើលោកយល់ស្របដែរឬទេ ជាមួយនឹងការវាយតម្លៃបែបនេះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ! ឌុច កុំអាលឆ្លើយតបទៅនឹងសំណួរចុងក្រោយនេះដែលសួរឡើងដោយមេធាវី។

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន សំណួរបែបនេះ គឺស្នើឲ្យសាក្សីគាត់ផ្តល់នូវមតិយោបល់ទាក់ទងទៅនឹងថា តើគាត់យល់ឃើញថា សហចៅក្រមស៊ើបអង្កេតត្រូវ ឬក៏ខុស។ ដូច្នេះ ខ្ញុំគិតថា គួរតែចោទសួរជាជាងផ្តល់ឱកាសឲ្យសាក្សី ដើម្បីបញ្ចេញមតិ ទាក់ទងទៅនឹងសហចៅក្រមស៊ើបអង្កេត។ ដូច្នេះសូមលោកប្រធានមេត្តាសម្រេច។

[១១:៣១:០៩]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសូមស្នើ ហើយខ្ញុំសូមផ្តល់ចម្លើយដែលថាខ្ញុំចង់ឲ្យមានលក្ខណៈយុត្តិធម៌ចំពោះសាក្សី ដើម្បីខ្ញុំផ្តល់ឱកាសដល់សាក្សី ដើម្បីឲ្យគាត់ពន្យល់ថា តើគាត់យល់ស្រប ឬមិនយល់ស្រប? ហើយប្រសិនបើគាត់យល់ស្រប ឬមិនយល់ស្រប គាត់អាចផ្តល់ហេតុផល។ ដូច្នេះ អ្វីដែលខ្ញុំចង់និយាយគឺមិនមែនបានន័យថា ខ្ញុំដាក់ ឬក៏ចោទសំណួរទៅលោកទេ គ្រាន់តែខ្ញុំផ្តល់ឱកាសដល់លោកសាក្សីតែប៉ុណ្ណោះ។ ថាតើខ្ញុំអាចស្តាប់ចម្លើយពីសាក្សីបានដែរឬទេលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ ជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះការតាំងសំណួរបែបនេះចុងក្រោយរបស់មេធាវីការពារអៀង សារី ចំពោះសាក្សី ជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរដែលក្នុងបំណងឲ្យលោកបញ្ចេញមតិយោបល់ ជាអត្តនោម័តិ ឬក៏សេចក្តីសន្និដ្ឋានរបស់លោកចំពោះបញ្ហាអ្វីៗដែលមេធាវី ឬភាគីផ្សេងទៀតមានបំណងសួរទេ។

[១១:៣២:២៨]

មេធាវីអាចផ្លាស់ប្តូរនូវសំណួរ ក្នុងន័យចៀសឲ្យផុតនូវការណាដែលស្នើសុំឲ្យសាក្សីឆ្លើយជាសេចក្តីសន្និដ្ឋាន ឬក៏ជាការបញ្ចេញនូវមតិយោបល់អត្តនោម័តិរបស់ខ្លួន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** យើងមើលទៅលើឯកសារដដែលនេះ ខ្មែរគឺ00605556 ដល់57។ អង់គ្លេស 00604739

បារាំងគឺ 00674384។ កថាខណ្ឌ៩២៩ “ពាក់ព័ន្ធទៅនឹងការសម្លាត់ជុំវិញមជ្ឈិម ប.ក.ក ឌុច គ្រាន់តែបានដឹងច្បាស់អំពីឋានានុក្រមនៅពីលើគាត់ផ្ទាល់ប៉ុណ្ណោះ។ ប៉ុន្តែគាត់មិនបានដឹងព័ត៌មានលម្អិតអំពីដំណើរការធ្វើសេចក្ដីសម្រេចចំពោះការចាប់ខ្លួនទេ។ គាត់ទើបតែបានដឹងអំពីសេចក្ដីសម្រេចរបស់គណៈមជ្ឈិមដែលធ្វើឡើងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ នៅពេលដែលគាត់បានចូលរួមមើលសំណុំរឿងតែប៉ុណ្ណោះ”។ តើលោកឯកភាព ឬក៏មិនឯកភាពជាមួយនឹងចៅក្រមស៊ើបអង្កេតដែលថា លោកបានដឹងច្បាស់ថាឋានានុក្រមនៅពីលើលោក ហើយលោកមិនបានដឹងព័ត៌មានលម្អិតអំពីដំណើរការធ្វើសេចក្ដីសម្រេចនេះកាលពីលើកមុនដែរឬទេ? តើមែនដែរឬទេ? លោកឯកភាព ឬក៏មិនឯកភាព?

[១១:៣៤:២៥]

**ប្រធានអង្គជំនុំ៖**

សាក្សី កុំអាលឆ្លើយតបទៅនឹងសំណួរនេះ!

តំណាងសហព្រះរាជអាជ្ញាសូមអញ្ជើញ!

**លោក វីណ្ឌៀម ស្មីត៖**

ទាំងអស់នេះហើយ គឺយើងកំពុងតែចង់ឆ្លើយតបទៅនឹងមេធាវីការពារក្ដីដែលគាត់បានសួរ។ យើងគ្មានជំទាស់ទៅនឹងការលើកជាសំណើ យកមកសួរនោះទេ។ ក៏ប៉ុន្តែមេធាវីគាត់លើកឡើងសំណើពាក់កណ្ដាល ហើយកំណត់លក្ខណៈថា តាមរយៈបទពិសោធន៍នៅមន្ទីរស-២១ របស់គាត់ និងជាមួយនិងការដឹងឮដែលគាត់បានដឹងនៅពេលនោះ។ ឌុច មានលទ្ធភាពក្នុងការធ្វើការសន្និដ្ឋានផែនការដាក់ចុះនិងសេចក្ដីសម្រេចរបស់គណៈមជ្ឈិមពាក់ព័ន្ធនឹងសេចក្ដីសម្រេចក្នុងជួរ និងក្រៅជួរ។ ដូច្នេះចំណុចនេះមិនត្រូវបានលើកឡើងបន្ថែមឲ្យបានគ្រប់ពេញលេញនោះទេ។ ដូច្នេះប្រសិនបើយើងលើកដូច្នេះវាធ្វើឲ្យមានការយល់ច្រឡំទៅដល់សាក្សីហើយមិនបានជួយឲ្យសាក្សីនោះយល់ថាគេបាននិយាយពេញលេញយ៉ាងម៉េចក្នុងនេះនោះទេ។

[១១:៣៥:៣១]

ប្រសិនបើសំណួរដែលនាំមុខនោះ លើកជាសំណើហ្នឹងពេញតែម្ដង ដូច្នេះសាក្សីគាត់នឹងមិនច្រឡំនោះឡើយ។ ប្រសិនបើយើងមើលផ្នែក-- មួយផ្នែកនៅក្នុងកថាខណ្ឌនេះគឺវាពាក់ព័ន្ធទៅនឹងកថាខណ្ឌទី-- ផ្នែកនៃកថាខណ្ឌនេះ។ ប្រសិនបើយើងដកផ្នែកចុងក្រោយនៃកថាខណ្ឌនេះចេញ យើងមើលទៅហាក់ដូចជាសាក្សីគាត់មិនបានដឹងព័ត៌មាននេះឲ្យបានគ្រប់ជ្រុងជ្រោយ។ ហើយកថាខណ្ឌទាំងមូលនេះ និយាយ

ផ្ទុយទៅនឹងអ្វីដែលមេធាវីបានលើកឡើង។ ហេតុដូច្នេះយើងខ្ញុំមិនជំទាស់ទេ ការដែលលើកជាចំណុចណាមួយយកមកឲ្យសាក្សីឆ្លើយ ក៏ប៉ុន្តែយើងមិនត្រូវឲ្យលើកជា-- ផ្នែកតែមួយ ហើយឲ្យសាក្សីយល់ច្រឡំដូចដែលមេធាវីការពារក្តីគាត់តែងតែបញ្ជាក់ថា មិនចង់ឲ្យមានការយល់ច្រឡំ។

[១១:៣៦:២០]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមធ្វើការឆ្លើយតបទៅនឹងចំណុច ដោយសារតែសហព្រះរាជអាជ្ញា គាត់តែងតែធ្វើចំណុចនេះ។ យើងដឹងហើយ សហព្រះរាជអាជ្ញាមានរយៈពេលជាងប្រាំមួយថ្ងៃក្នុងការតាំងសំណួរ។ នៅពេលនេះខ្ញុំផ្តល់ឱកាសទៅដល់សាក្សីផ្តល់ជាយោបល់។ ខ្ញុំមិនមានការសួរនាំដឹកមុខនោះទេ។ សាក្សីអាចបញ្ជាក់ថា គឺគាត់បានដឹងយ៉ាងច្បាស់លម្អិតអំពីដំណើរការធ្វើសេចក្តីមសម្រេច។ ប្រសិនបើខ្ញុំមិនយុត្តិធម៌ចំពោះសាក្សី អង្គជំនុំជម្រះអាចទាញយកចម្លើយបញ្ជាក់ផ្សេងទៀតបានពីសាក្សីរូបនេះ។ នៅពេលនេះខ្ញុំគ្រាន់តែផ្តល់ឱកាសទៅដល់សាក្សីឲ្យបញ្ជាក់យោបល់របស់គាត់ទៅលើការវាយតម្លៃដូច្នេះ។ សហព្រះរាជអាជ្ញាមិនយល់អំពីសំណួរដែលខ្ញុំចង់សួរ ក៏ប៉ុន្តែបើសិនជាសហព្រះរាជអាជ្ញាដឹងនោះ យល់នោះ គឺឲ្យសហព្រះរាជអាជ្ញា គាត់មើលទៅលើអ្វីដែលខ្ញុំបានសួរ និងចម្លើយដែលបានផ្តល់។ ខ្ញុំបានផ្តល់ជាមូលដ្ឋានរួចមកហើយសម្រាប់សាក្សី ដើម្បីខ្ញុំសួរបន្ថែម។

[១១:៣៧:២៥]

ដូច្នេះខ្ញុំសូមៗសួរថា តើសាក្សីនោះទំនងជាអាចដឹងអំពីឋានានុក្រមនៅពីលើគាត់ផ្ទាល់ដែរឬទ? ហើយគាត់ដឹងលម្អិតអំពីដំណើរការធ្វើសេចក្តីសម្រេចដែរឬទេ? ខ្ញុំសួរដូច្នេះគឺយើងដឹងហើយថា សហព្រះរាជអាជ្ញា គាត់ក្រោកឈរ គាត់តែងតែលើកឡើងថា សាក្សីនេះគឺជាសាក្សីពិសេស គាត់បានដឹងច្រើន គាត់មានព័ត៌មានអាចអានគ្រប់ជ្រុងជ្រោយ គាត់មានមេធាវីគាត់ជួយការងារ ដូច្នេះយើងចង់សួរសំណួរគាត់។

[១១:៣៨:១៤]

**លោក វីណ្សៀម ស្មីត៖**

ខ្ញុំគិតថាមិនមែនជារឿងកំប្លែងទេ នៅពេលដែលយើងសួរសំណួរទៅកាន់សាក្សី។ សំណួរទាំងឡាយដែលបានសួរអម្បាញ់មិញនេះ គឺដកស្រង់ចេញមកពីកថាខណ្ឌមួយដែលយើងមើលឃើញនេះ។ ដូច្នេះសាក្សីគួរតែដកស្រង់សម្តីនេះទាំងស្រុងចេញពីកថាខណ្ឌនេះតែម្តងឲ្យសាក្សីបានយល់។

**លោក ម៉ៃខល កាណាវ៉ាស៖**

ខ្ញុំបានផ្តល់លេខកថាខណ្ឌហើយ។ ហើយសាក្សីអាចមើលកថាខណ្ឌហ្នឹងទាំងមូលបាន។ សាក្សីនេះឆ្លាតណាស់។ ហើយគាត់មានបញ្ញាវាងវៃ គាត់មានទទួលការអប់រំខ្ពស់។ ដូច្នេះហើយខ្ញុំមិនឃើញចំណុចណាមួយ-- អយុត្តិធម៌ចំពោះសាក្សីនោះទេ។ ប្រសិនបើសហព្រះរាជអាជ្ញាគាត់ជំទាស់អ៊ីចឹងហើយ គឺឲ្យអង្គជំនុំជម្រះធ្វើការសម្រេចទៅលើការជំទាស់ហ្នឹងទៅ ខ្ញុំមានសិទ្ធិតែចង់ស្តាប់ចម្លើយនេះ។

[១១:៣៩:១៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាង-- តំណាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**កញ្ញា លី ម៉ាញៀន៖**

លោក លោកស្រីចៅក្រម សូមអរគុណ។ ខ្ញុំយល់អំពីសំណួរដែលមេធាវីការពារក្តីបានដឹកមុខ និងបង្ហាញជូនសាក្សី។ គាត់ចង់បង្ហាញជូនសាក្សី ក៏ប៉ុន្តែគឺការតាំងសំណួរគឺមិនមែនផ្តោតតែទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ អង្គជំនុំជម្រះត្រូវតែពិចារណា ប្រសិនបើផ្អែកទៅលើការសួរសំណួរទាំងអស់នេះយើងឃើញថា សំណួរដែលបានសួរនេះ គឺដកចេញមកពីកថាខណ្ឌនិងបរិបទមួយជាក់លាក់។

[១១:៤០:០០]

ឧទាហរណ៍ ខ្ញុំសូមផ្តល់ជាឧទាហរណ៍មួយ កំណត់ហេតុស្តាប់ចម្លើយថ្ងៃទី២៥ ខែមិថុនាឆ្នាំ២០០៨ D90 ដែលក្នុងចម្លើយនោះ សាក្សីនៅក្នុងចម្លើយនោះ បានលើកឡើងថា គាត់ចង់មើលឯកសាររបស់ កែ ពក មុនពេលដែលឆ្លើយ។ ដូច្នេះសំណួរដែលបានសួរទៅដល់សាក្សី គឺពាក់ព័ន្ធទៅនឹងការបង្កើតភូមិភាគ ហើយហេតុអ្វីបានគេបង្កើតភូមិភាគ។ ប្រសិនបើយើងមិនបង្ហាញបរិបទ ស្ថានភាពឲ្យបានជាក់លាក់នោះទេ យើងមិនដឹងថាតើយើងកំពុងនិយាយអ្វីនោះឡើយ។ សាក្សីបានឆ្លើយហើយថា ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌ និងស្ថានភាពកាលបរិច្ឆេទបង្កើតភូមិភាគទាំងឡាយនោះ គឺគាត់ចង់មើលឯកសារមួយចំនួនជាមុន មុនពេលដែលឆ្លើយ។ ហេតុដូច្នេះអង្គជំនុំជម្រះ ត្រូវតែពិចារណា និងគិតគូរអំពីការដកស្រង់ ដូចជាការដកស្រង់ចេញមកពីកំណត់ហេតុ នៃការស្តាប់ចម្លើយនោះគឺ ការដកស្រង់ទាំងអស់នោះ ចេញមកពីបរិបទ និងកថាខណ្ឌជាក់លាក់។

[១១:៤១:០០]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមធ្វើការឆ្លើយតប ប្រសិនបើមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គាត់ចង់ជំទាស់នោះ គួរតែជំទាស់លើកឡើងពីពេលមុន។ ខ្ញុំមិនចង់កាត់សម្ដីនោះទេ នៅពេលអនាគត គឺថា ខ្ញុំនឹងធ្វើការកាត់សម្ដីហើយ បើសិនជាគាត់មិនលើកការឆ្លើយជំទាស់របស់គាត់នោះ ទៅតាមអ្វីដែលយើងបានកំណត់តាមវិធានច្បាប់។ ដូច្នេះពេលនេះ ខ្ញុំមិនកាត់សម្ដីគាត់ទេ។ ប្រសិនបើយើងដឹងហើយថា សាក្សីរូបនេះគាត់ជាសាក្សីពិសេសនោះ គឺគាត់គួរតែដឹងឲ្យបានលម្អិត។ យើងដឹងហើយថា សាក្សីនេះគាត់ជាសាក្សីពិសេស គាត់ឆ្លើយនៅមុខចៅក្រមស៊ើបអង្កេត គាត់ថា គាត់ត្រូវតែមើលឯកសារមុនពេលដែលគេឆ្លើយតប-- មុននឹងគាត់ឆ្លើយតប គឺគាត់ដឹងច្រើនណាស់នៅក្នុងខួរក្បាលរបស់គាត់ គឺគាត់ដឹងច្រើនណាស់ ដូចគាត់មិនចាំបាច់ផ្ទៀងផ្ទាត់ទៅលើឯកសារនោះទេ។

តាមរយៈពេលនោះ តាំង-- រយៈពេលកន្លងមកគឺគាត់អាចដឹង ហើយគាត់អាចមើលឯកសារដើម្បីយកមកបំពេញចន្លោះរបស់គាត់បាន ទៅលើការដែលគាត់ដឹងឮ។ ដូច្នេះហើយនៅពេលដែលគាត់សាក្សីលើកឡើងថា វាជាគុណប្រយោជន៍សម្រាប់គាត់ នៅពេលដែលគាត់មើលឯកសារជាមុននោះ សាក្សីនោះគាត់ហាក់ដូចជា មិនជាសាក្សីមួយដែលមានការវាងវៃនោះឡើយ។

**លោក វីល្លៀម ស្មីត៖**

*(គ្មានការបកប្រែ)*

[១១:៤២:២៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ! មិនចុចហើយសួរ ចុចហើយងើបដូចជារំឭកច្រើនលើកច្រើនសាហើយ។

សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

យើងខ្ញុំមិនជំទាស់ចំពោះការសួរសំណួរ ជាលក្ខណៈទូទៅនោះទេ វាជាការត្រឹមត្រូវ ការតាំងសំណួរបែបទាំងអស់នោះ។ តាមរយៈកំណត់ហេតុស្ដាប់ចម្លើយ វាបានបង្ហាញយ៉ាងច្បាស់ តាមរយៈសក្ខីកម្មក៏បានបង្ហាញយ៉ាងច្បាស់ដែរថា អង្គហេតុមួយចំនួននោះ សាក្សីនេះបានដឹងក្រោយមកតែប៉ុណ្ណោះ។ បញ្ហាជាក់លាក់នៅទីនេះ ដែលសំខាន់ អ្វីដែលគាត់មេធាវីបានសួរនោះគឺថា សាក្សីគាត់មិនបានដឹងពេលមុន តែក្រោយមកទើបគាត់បានដឹង។ អ្វីដែលយើងលើកឡើងពេលនេះគឺ បញ្ហាយុត្តិធម៌។

វេទិកានេះ មិនមែនជាការស្រាវជ្រាវចង់ទាញប្រយោជន៍នោះទេ គឺយើងចង់ឲ្យមានភាពយុត្តិធម៌។ សំណួរដែលចុងក្រោយនេះ គឺយើងហាក់ដូចជា មិនមានភាពយុត្តិធម៌ គឺដោយសារតែចំណុចដកស្រង់នេះ បានមិនលើកឡើងពាក់កណ្តាលរួចទៅហើយ។

[១១:៤៣:៤២]

**លោក ម៉ៃខល កាណាវាស៖**

មិនមែនជាចម្លើយរបស់សាក្សីនោះទេ វាជាការសន្និដ្ឋានរបស់តែសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

ឥឡូវអង្គជំនុំជម្រះផ្តល់វេទិកាចុងក្រោយលើការតប ទៅនឹងការជំទាស់របស់សហព្រះរាជអាជ្ញា ដើម្បីអង្គជំនុំជម្រះសម្រេច លោកមេធាវី។ អង្គជំនុំជម្រះសូមរំឭកឡើងវិញថា លោកមេធាវីគួរតែត្រូវបានបង្អង់បន្តិច ឲ្យមានការបកប្រែត្រឹមត្រូវមុននឹងលោកប្រតិកម្មតបទៅវិញ ហើយបញ្ជាក់ឲ្យច្បាស់លាស់ពីការតបរបស់លោក ដើម្បីឲ្យអ្នកបកប្រែហ្នឹងបកបាន។ ឥឡូវនេះ អង្គជំនុំជម្រះផ្តល់វេទិកាចុងក្រោយ ក្នុងការតបទៅនឹងសំណួរអម្បាញ់មិញនេះ ដែលមានការជំទាស់តវ៉ា តើលោកតបថាម៉េច?

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅជាបឋម។ ខ្ញុំមិនមែនយោងទៅលើអ្វីដែលសហព្រះរាជអាជ្ញាថា មិនឲ្យគាត់យល់ទៅលើបរិបទនោះទេ។ អ្វីដែលខ្ញុំដកស្រង់នោះគឺថា វាបង្កើតឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលគេបានសួរទៅលើសាក្សីរូបនេះ ហើយបាន សាក្សីរូបនេះត្រូវបានផ្តល់ឯកសារ និងកំណត់ហេតុលាយលក្ខណ៍អក្សរជាដើម។ ខ្ញុំសូមធ្វើការសន្និដ្ឋាន ខ្ញុំមិនចាំបាច់អានទេ ហើយយើងដឹង ឃើញទាំងអស់គ្នាហើយ ខ្ញុំគ្រាន់តែផ្តល់ឱកាសទៅដល់សាក្សីរូបនេះ ថាតើគាត់ឯកភាព ឬមិនឯកភាព។ ខ្ញុំសួរគាត់យ៉ាងជាក់លាក់ ថាតើចំណុចនេះ គឺត្រឹមត្រូវដែរឬទេ ដែលថាគាត់មិនបានដឹងលម្អិតអំពីដំណើរការធ្វើសេចក្តីសម្រេច ចំពោះការចាប់ខ្លួននាសម័យនោះ ដោយផ្អែកទៅលើកាលៈទេសៈទាំងអស់នេះ? ដូច្នេះហើយនេះគឺជាអ្វីដែលសាក្សីបានលើកឡើង។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៧:០៦]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី តំណាងឲ្យមេធាវីនាំមុខតំណាងដើមបណ្តឹង

រដ្ឋប្បវេណីគ្មានប្រសិទ្ធភាពទេ។ ដោយសារគាត់ធ្វើយឺតពេល ធ្វើលើកទឡ្ហីករណ៍មិនមានពាក់ព័ន្ធទៅនឹងបច្ចុប្បន្នភាពនៃបញ្ហាដែលកើតឡើងនៅចំពោះមុខអង្គជំនុំជម្រះ។ ចំណែកឯសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិមានប្រសិទ្ធភាព។

អង្គជំនុំជម្រះសូមរំឭកឡើងវិញថា មេធាវីមិនគប្បីតាំងសំណួរឯណាឲ្យសាក្សីផ្តល់នូវគំនិតយោបល់ វាយតម្លៃទៅលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតទេ។ ភារកិច្ចរបស់សាក្សីគឺឆ្លើយទៅនឹងបញ្ហាទាំងឡាយណាដែលខ្លួនបានដឹង បានឮ បានឃើញ មានបទពិសោធន៍ បានជួបប្រទះ ឬក៏ការធ្វើការអង្កេតដែលជាក់លាក់ទៅបញ្ហាព្រឹត្តិហេតុ ព្រឹត្តិការណ៍ដែលកើតមានឡើង ដែលគាត់បានជួបប៉ុណ្ណោះ។

[១១:៤៨:១៩]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ពេលនេះ យើងចូលឯកសារ D86/9 ជាពិសេសខ្មែរ ERN គឺ 00154230 អង់គ្លេសគឺ 00154202 បារាំងគឺ 00154218។ វាជាកំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទីខែ-- ថ្ងៃ២៩ ខែវិច្ឆិកា ឆ្នាំ២០០៧។ ២៩ ខែវិច្ឆិកា ឆ្នាំ២០០៧។ ខ្ញុំសូមចូលមើលទៅលើកំណត់ហេតុហ្នឹង ដែលក្នុងនោះជាពិសេសនៅក្នុងទំព័រជាក់លាក់ខាងលើ ដែលសរសេរថា "ចម្លើយសារភាព"។ "ខ្ញុំសូមសារភាពទាក់ទងទៅនឹងលិខិតមួយដែលបានបដិសេធ បន្ទាប់មកខ្ញុំបង្ខំចិត្តបដិសេធជាបណ្តោះអាសន្នទាំងភ័យតក់ស្លុត ទាំងខ្មាសអៀន។ មូលហេតុមកពីខ្ញុំរង់ចាំឲ្យសំណូមពររបស់យើងខ្ញុំ ធ្លាក់មកជាការអនុវត្តជាក់ស្តែង គឺសំណូមពរទាមទារសុំឲ្យបានច្បាប់ថតចម្លង នៃឯកសារជាភស្តុតាងមកអានពិចារណា និងរំឭកឡើងវិញ"។ បន្ទាប់មកចុះមកក្រោមទៀត លោកបានលើកឡើងថា៖ "ជាសរុបមក ខ្ញុំត្រូវការសន្តិភាពគ្រប់បែបយ៉ាង ដើម្បីរួមចំណែកបំភ្លឺជូនតុលាការនូវឧក្រិដ្ឋកម្ម ដែលកើតឡើងនៅមន្ទីរស-២១"។ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ តើលោកបានផ្តល់ឯកសារនេះដែរឬទេ? ឬក៏មិនមែនទេ? ហើយដោយសារឯកសារនេះមានចុះថាលោកចុះហត្ថលេខា ហើយជាអក្សររបស់លោក ឬក៏មិនមែន? សូមលោកបញ្ជាក់។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះជារបស់ខ្ញុំពិតប្រាកដ!

**ស៖** ដើម្បីឲ្យខ្ញុំយល់លោកឲ្យបានច្បាស់ លោកបានផ្ដល់ព័ត៌មានដែលមិនត្រឹមត្រូវមិនស្មោះត្រង់ ក្រោយមកលោកបែរជាសារភាពថា ហេតុផលដែលផ្ដល់ចម្លើយមិនត្រឹមត្រូវ គឺលោកត្រូវតែធ្វើការសុំផ្ដល់ សុំឯកសារអានជាមុនទើបលោកឆ្លើយបាន។ ដូច្នេះតើអ្វីចំណុចទាំងអស់នេះ ខ្ញុំសង្ខេបមកវិញត្រឹមត្រូវដែរឬទេ អ្វីដែលលោកសរសេរចង់បានន័យត្រង់ចំណុចទាំងអស់នេះ?

[១១:៥១:៣៥]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មុននឹងអធិប្បាយ មុននឹងឆ្លើយ ខ្ញុំត្រូវសុំឯកសារជាគោលមកសិន ដើម្បីច្បាស់លាស់។ ខ្ញុំពិតជាសុំឯកសារអ៊ីចឹងមែន។

**ស៖** យើងខ្ញុំបន្តទៅមុខទៀត យើងខ្ញុំចាត់ទុកថាអ្វីដែលលោកឆ្លើយនេះជាចម្លើយ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំគិតថា ខ្ញុំនៅសល់១០នាទីទៀត ដូច្នេះហើយខ្ញុំមិនចង់ឲ្យពេលវេលាខាតបង់ទេ។ ខ្ញុំចូលទៅដល់ឯកសារមួយទៀត ឯកសារមួយសំណុំជាបន្តបន្ទាប់ទៀត។ សង្ឃឹមថាយើងនឹងចូលដល់ឯកសារនេះបានលឿន។ D121/2 ឯកសារដែលយើងលើកឡើងនេះ គឺបញ្ជីសំណួរចម្លើយ។ យើងខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះ ដាក់បង្ហាញឯកសារនេះ គឺ D121/2។ ឯកសារនេះត្រូវការ-- ត្រូវបានបង្កើតឡើងដោយលោកសាក្សីរូបនេះផ្ទាល់។

[១១:៥៣:០៧]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការស្វែងរកឯកសារដាក់យកទៅជូនសាក្សីពិនិត្យ!

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ប្រសិនបើយើងមើលឯកសារនេះដោយខ្លីៗ ដោយសង្ខេប មុនពេលដែលយើងចូលទៅដល់ទំព័រចុងក្រោយនៃឯកសារនេះ។ ឯកសារ D121/6 ទាំងអស់នេះហើយគឺជាបញ្ជីសំណួរដែលលោកបានផ្ដល់ ដែលគេបានផ្ដល់ឲ្យ ឲ្យលោកឆ្លើយ តើត្រឹមត្រូវដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ត្រឹមត្រូវហើយ។

**ស៖** កាលបរិច្ឆេទ គឺថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៩ ហើយប្រសិនបើយើងចូលទៅដល់ឯកសារចុងក្រោយ ដែលភ្ជាប់ទៅនឹងឯកសារនេះ គឺ D121/6 ចម្លើយផ្ដល់នៅថ្ងៃទី១ ខែ១២ ឆ្នាំ២០០៩។ គឺ

ប្រហែលជាប្រាំបី ទៅប្រាំបីខែកន្លះក្រោយមក តើលោកឯកភាពទៅលើចំណុចហ្នឹងដែរឬទេ?

[១១:៥៥:២៦]

លោកសាក្សីលោកជួយជម្រាបមក ថាតើរយៈពេលដែលលោកផ្តល់ចម្លើយពីពេលដែលគេឲ្យសំណួរនោះ តើរយៈពេលប៉ុន្មាន ដែលលោកទើបអាចផ្តល់ចម្លើយបាននោះ? សូមលោកជួយបញ្ជាក់ឆ្លើយ។ ឯកសារទំព័រចុងក្រោយ D121/6 បានសរសេរថា “មេធាវីបានបញ្ជូនមក ប្រគល់ចម្លើយមកយើងនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩”។ តើលោកសាក្សីឃើញទេចំណុចហ្នឹង?

**ឆ៖** ត្រង់ណា១ ជម្រាបប្រសាសន៍។

**លោក ម៉ៃខល កាណាវាស៖**

*(និយាយមិនបើកមីក្រូហ្វូន)*

**អ្នកបកប្រែ៖**

សូមអនុញ្ញាតឲ្យមេធាវីបើកមីក្រូហ្វូន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឯកសារភ្ជាប់ទៅនឹងឯកសារមុន គឺយើងឃើញមានឯកសារលេខ D121/6 ហើយប្រសិនបើលោកសាក្សីមើលនៅចុងក្រោយនៃឯកសារនេះ គឺកថាខណ្ឌជិតចុងក្រោយ ដែលក្នុងសរសេរថា មេធាវីរបស់គាត់បានប្រគល់ចម្លើយនេះមកយើងនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩។ តើលោកអានមើលឃើញទេ ចំណុចហ្នឹង?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមើលឃើញហើយ។

**ស៖** ដូច្នេះតើត្រឹមត្រូវដែរឬទេ នៅពេលដែលយើងសន្និដ្ឋានថា តាំងពីថ្ងៃ៦ ខែមីនា ឆ្នាំ២០០៩ រហូតមកដល់ ២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ទើបលោកអាចផ្តល់ចម្លើយនេះបាន តើពិតជាត្រឹមត្រូវដែរឬទេ?

[១១:៥៨:០៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

ដើម្បីឲ្យប្រតិចារឹកឲ្យបានច្បាស់លាស់ ការជំនុំជម្រះលើជនជាប់ចោទនេះ គឺពីខែមេសា ដល់ធ្នូ

ឆ្នាំ២០០៩។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំគ្រាន់តែចង់បញ្ជាក់ទៅលើឯកសារតែប៉ុណ្ណោះ ដែលថាសាក្សីរូបនេះ គឺមានរយៈប្រហែលជាប្រាំបីខែ ឆ្លើយទៅនឹងសំណួរដែលបានដាក់ជូននេះ។ អ៊ីចឹង ខ្ញុំអត់មានឃើញទ្វេគ្រោះអ្វីទៅនឹងការជំទាស់ ដែលបានលើកឡើងដោយខាងភាគីម្ខាងទៀតនោះទេ។

[១១:៥៨:៤៤]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំសូមបន្តចូលទៅដល់ឯកសារមួយទៀត។ ឯកសារ D108 សូមអធ្យាស្រ័យ D90/IIៗ ដាក់ភ្ជាប់ទៅនឹងឯកសារខាងដើមនេះ គឺចម្លើយ ប្រសិន-- យើងមើលលើឯកសារឆ្លងចូលឯកសារ E3/15 ចុះថ្ងៃ២១ ខែតុលា ឆ្នាំ២០០៨ គឺកាលបរិច្ឆេទទៅលើឯកសារ។ សំណួរដែលបានដាក់ជូននេះ គឺចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨។ សំណួរទាំងនេះ ត្រូវបានភ្ជាប់ទៅនឹងកំណត់ហេតុចម្លើយចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨។ ដូច្នេះតើត្រឹមត្រូវ ដែលយើងសន្និដ្ឋានថា នៅពេលដែលលោកទទួលបានសំណួរទាំងឡាយនោះ គឺលោកមានរយៈពេលប្រហែលជាបួនខែឯណោះ ក្នុងការឆ្លើយសំណួរទាំងអស់នេះ។ តើពិតជាត្រឹមត្រូវដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមើលមិនទាន់ទេ ប៉ុន្តែខ្ញុំសូមសរុបថា កំណត់ត្រាអស់នេះអត់មានក្លែងក្លាយទេថ្ងៃខែ។ ដូច្នេះ ខ្ញុំជឿថាត្រឹមត្រូវរបស់គេ។

[១២:០០:៤៨]

**ស៖** សូមអរគុណ។ បើសិនយើងមើលឯកសារមួយទៀត D108/52 ខ្ញុំដឹងថាម៉ោងនេះម៉ោងបួនហើយ ហើយខ្ញុំ មេធាវីបានលើកឡើងដូច្នេះ ខ្ញុំនឹងព្យាយាមបញ្ចប់ ហើយឬក៏ខ្ញុំសូមអធ្យាស្រ័យសូមបញ្ចប់ឯកសារនេះមួយសិន។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត! សូមអញ្ជើញ! សូមបន្តឲ្យចប់ឯកសារនេះចុះ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណ។

**សួរដោយលោក ម៉ៃខល ការណាវាស៖**

**ស៖** យើងនៅទីនេះយើងឃើញថា មានបញ្ជីសំណើពីសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី គឺចុះថ្ងៃទី២-- ថ្ងៃ២ ខែមិថុនា ឆ្នាំ២០០៨។ ប្រសិនបើយើងមើល D108/52/3 ដែលភ្ជាប់ទៅនឹងឯកសារនេះ គឺបានបង្ហាញថា ចម្លើយដែលសាក្សីបានផ្ដល់ជូនគឺនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨។ ដូច្នេះប្រហែលជាប្រាំមួយសប្ដាហ៍ បានន័យថា គាត់មានរយៈពេលប្រាំមួយសប្ដាហ៍ក្នុងការឆ្លើយ។ តើត្រឹមត្រូវដែរឬទេលោកសាក្សី?

[១២:០២:១១]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ចម្លើយនៅតែដដែលទេ ខ្ញុំមើលអត់ទាន់ទេ ផ្ទៀងផ្ទាត់អត់ទាន់ទេ។ ក៏ប៉ុន្តែជឿថាការកត់ត្រានេះអត់ខុសរបស់គេទេ ត្រឹមកាលបរិច្ឆេទ។

**ស៖** សូមអរគុណ។ ប្រសិនជាយើងមើលឯកសារ D86/12 កំណត់ហេតុស្ដាប់ចម្លើយជនត្រូវចោទ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨។ សូមឲ្យលោកសាក្សីមើលឯកសារនេះ។ ខ្ញុំសូមអរគុណ ប្រសិនបើលោកមើល។

បន្ទាប់មកភ្ជាប់ទៅនឹងឯកសារមួយនេះ មានឯកសារ D86/12/I យើងឃើញកាលបរិច្ឆេទ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៨។ តើត្រឹមត្រូវដែរឬទេ យុត្តិធម៌ដែរឬទេ ដែលថានៅក្នុងកាលពីពេលនោះលោកបានផ្ដល់ចម្លើយ បីអាទិត្យក្រោយមកទើបលោកបានផ្ដល់ចម្លើយ។ តើត្រឹមត្រូវដែរឬទេ?

[១២:០៣:៤៧]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន អ្វីដែលមានចំណារកត់ត្រាច្បាស់លាស់បែបនេះ ខ្ញុំទទួលស្គាល់ថាត្រឹមត្រូវ ត្រឹមតែកាលបរិច្ឆេទ។

**ស៖** ជាការពិតនៅផ្នែកដំបូងនៃឯកសារនេះ D86/12 ខ្ញុំអត់មានលេខ ERN ទេ ដូច្នេះខ្ញុំសូមរំលងសំណួរនេះ កុំឲ្យយើងខាតបង់ពេលវេលា។ ក៏ប៉ុន្តែដើម្បីជាកំណត់ហេតុប្រតិចារឹក សាក្សីរូបនេះក៏ទទួលបាននូវទស្សនាវដ្ដីស្វែងរកការពិតផងដែរ។ តើលោកចាំទេថា គេធ្លាប់បានផ្ដល់ទស្សនាវដ្ដីស្វែងការពិត-- សហចៅក្រមស៊ើបអង្កេតធ្លាប់ផ្ដល់ទស្សនាវដ្ដីស្វែងរកការពិតជូនលោកផងដែរ។ តើលោកចាំដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំនៅចាំ។

**ស៖** សូមអរគុណ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំគិតថា វាជាពេលសមគួរ ដើម្បីយើងអាចសម្រាកពិសាអាហារថ្ងៃត្រង់បានហើយ។ សូមអរគុណ។

[១២:០៥:០៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណមេធាវី អរគុណសាក្សី។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយកន្លះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ អនុរក្សមន្ទីរឃុំឃាំងឲ្យអញ្ជើញសាក្សីទៅកាន់បន្ទប់សម្រាកសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់ផ្តល់សវនាការនេះ នៅរសៀលនេះ នៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី ម៉ៃខល ផេសមិន!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន កូនក្តីរបស់ខ្ញុំសូមធ្វើសំណើជាធម្មតា បានន័យថា សូមត្រឡប់ទៅបន្ទប់រង់ចាំខាងក្រោមតាមដានដំណើរការសវនាការ។ ដូច្នេះ យើងខ្ញុំនឹងដាក់ជូនលិខិតជាលាយលក្ខណ៍អក្សរ ស្តីអំពីការបោះបង់សិទ្ធិនេះជូនអង្គជំនុំជម្រះ។ សូមអរគុណ។

[១២:០៦:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គុយចុះ!

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ នៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះសម្រាប់រសៀលនេះ ដោយគាត់សម្រេចចិត្តលះបង់សិទ្ធិមិនចូលរួមនៅក្នុង-- តាមដានកិច្ចដំណើរការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅខាងក្រោមបន្ទប់សវនាការនេះ តាម

រយៈប្រព័ន្ធសោតទស្សន៍ សម្រាប់កិច្ចដំណើរការសវនាការពិភាក្សាដេញដោលនៅរសៀលនេះ ដោយគាត់សម្រេចចិត្តលះបង់សិទ្ធិមិនចូលរួម នៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

[១២:០៦:៥១]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិមិនចូលរួមផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការ ដោយចុះហត្ថលេខា ឬផ្តិតម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ។ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់កិច្ចដំណើរការសវនាការនៅរសៀលនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូបទៅកាន់បន្ទប់ខាងក្រោម និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទ ខៀវ សំផន មកកាន់បន្ទប់សវនាការនេះនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១២:០៨ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការពិភាក្សាដេញដោល និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់ទាំងនៅក្នុង និងនៅខាងក្រៅនៃសាលសវនាការ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** មុននឹងពេលយើងឈប់សម្រាក យើងបានពិនិត្យទៅលើឯកសារមួយចំនួន ដែលយើងបាន-- ដែលឯកសារនោះបង្ហាញពីការផ្ដល់សំណួរជាមុនដោយសហចៅក្រមស៊ើបអង្កេត ហើយក្រោយមកគឺហ្នឹង គឺប្រហែលជារាប់ខែ ឬរាប់អាទិត្យហ្នឹង លោកផ្ដល់ជាចម្លើយទៅវិញ។ ឥឡូវនេះខ្ញុំចង់សួរសំណួរខ្លះទៅលោក។ នៅក្នុងដំណាក់កាលស៊ើបអង្កេត តើតាមការផ្ដួចផ្ដើមរបស់លោកផ្ទាល់នោះ តើលោកមានផ្ដល់នូវកំណត់ហេតុ ឬក៏សេចក្ដីប្រកាសជាសាក្សីទៅសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំបានសរសេរអត្ថបទមួយពីរដែរ ជូនទៅសហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែអាហ្នឹងមិនដឹងគេហៅអីទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែបញ្ជាក់ពីសភាពការណ៍ខ្លះជូនចៅក្រមស៊ើបអង្កេត។

[១៣:៣៤:១៥]

**ស៖** បើតាមដែលខ្ញុំយល់ គឺថាលោកធ្វើដោយខ្លួនឯង បានន័យថាជាការផ្ដួចផ្ដើមដោយខ្លួនឯងផ្ទាល់។ តើមែនទេ?

**ឆ៖** មែន!

**ស៖** ដូច្នេះ យើងអាចនិយាយបានថា នៅក្នុងករណីខ្លះលោកផ្ដល់នូវការបំភ្លឺបន្ថែម ឬផ្ដល់នូវព័ត៌មានបន្ថែម ហើយធ្វើបែបនេះបន្ទាប់ពីបានផ្ទុះបញ្ជាំង ឬក៏បន្ទាប់ពីបានពិភាក្សាជាមួយនឹងការវិភាគ ឬក៏ក្រោយពីពិភាក្សាជាមួយឯកសារនានា ដែលបានសង្កត់ធ្ងន់ទៅលើចំណុចទាំងអស់នោះ។ តើមែនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំចាំមិនច្បាស់ទេ ក៏ប៉ុន្តែកំណត់ដែលខ្ញុំផ្ដល់ជូនសហចៅក្រមស៊ើបអង្កេត ដូចមិនមានឈរនៅលើឯកសារណាច្បាស់លាស់ក្រៅពីព្រឹត្តិការណ៍ដែលខ្ញុំចងចាំ ទេ។ នេះសូមបញ្ជាក់ប៉ុណ្ណេះ។

[១៣:៣៥:៣៥]

**ស៖** សូមអរគុណ។ ប្រសិនបើយើងមើលទៅលើឯកសារ D86/7 ហើយវាជាកំណត់ហេតុនៃការសួរចម្លើយលោកក្នុងនាមជាជនជាប់ចោទនៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៧។ សូមលោកពិនិត្យមើលទៅលើឯកសារនេះ។ យើងនឹងពិនិត្យមើលទៅលើឯកសារនេះ។

សូមលោកពិនិត្យមើលទៅលើឯកសារជាក្រដាសដែលលោកមាន។ ហើយខ្ញុំសូមឲ្យលោកចាប់អារម្មណ៍ទៅលើឯកសារដែលមានលេខ 00146669 ជាភាសាខ្មែរ, 00146669 ហើយឯកសារជាភាសាអង់គ្លេស 00149909, បារាំងគឺ 00149933។ ហើយយើងអាចពិនិត្យមើលទៅលើទំព័រដែលមានកំណត់សម្គាល់ ឬក៏និទ្ទេសរបស់សហចៅក្រមស៊ើបអង្កេត ដែលភ្ជាប់កំណត់ហេតុនេះនូវអត្ថបទសរសេរដៃ ដែលប្រគល់ជូនដោយជនត្រូវជាប់។ តើលោកបានឃើញចំណុចដែរឬទេ?

[១៣:៣៧:១១]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ ខ្ញុំបានឃើញចំណុចនេះ។

**អ្នកបកប្រែ៖**

លោកមេធាវីបើកមីក្រូហ្វូន!

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** នេះគឺជាឧទាហរណ៍មួយដែលខ្ញុំចង់លើកយកមកនិយាយ ហើយប្រសិនបើយើងអ្នកពិនិត្យសូមពិនិត្យមើល។ សូមពិនិត្យមើលទៅលើទំព័រ១ ប្រហែលជាទំព័រចុងក្រោយ គឺឯកសារជាភាសាខ្មែរមានលេខ 00146679 ភាសាអង់គ្លេសគឺ 00149918 និងភាសាបារាំង 00149944 ដែលមានបញ្ហាមួយចំនួន លោកបានបង្ហាញថា ឧទាហរណ៍នៅក្នុងទំព័រមួយនេះ គឺខ្ញុំខំៗ គេចពី គឺថាគេចពីការស្វែងរកការពិត ហើយដែលធ្វើឲ្យ តាម៉ុក គុំខ្ញុំរហូតអំពីករណីដែលកម្មាភិបាលឈ្មោះ-- កម្មាភិបាលហាណូយឈ្មោះ ត្រាច តុន-- ប្រាច សុន ហៅ ពត តើលោកបានឃើញចំណុចនេះដែរឬទេ? ប្រហែលជាខ្ញុំស្នើសុំឲ្យមានការជំនួយ។ តើលោកបានមើលឃើញដែរឬទេ គឺចំណុចទីបួន?

**ឆ៖** ឃើញ។

**ស៖** ហើយខ្ញុំគិតថា តាមរយៈពេលនោះ គឺលោកស្វែងរកការពិត ដូចដែលលោកបានសរសេរនៅទីនេះ ឬមួយក៏វាគ្រាន់តែជាករណីដាច់ដោយឡែកតែឯងមួយ ដែលលោកស្វែងរកការពិតតែមួយករណីនេះទេ? តើការពិតអ្វីដែរ?

[១៣:៣៩:៣៤]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បញ្ហាស្វែងរកការពិតនេះ ខ្ញុំមិនដឹងជាប៉ុន្មានករណីទេ ក៏ប៉ុន្តែនេះ វាលេចធ្លោជាងគេ។ ពីព្រោះ តាម៉ុក ចោទទៅលើកម្មាភិបាលហាណូយម្នាក់ ថាជាអ្នកបាញ់ទៅលើលេខាវរសេនាតូចរបស់ខ្លួន។ ខ្ញុំទៅវិភាគតាមដំណើរគ្រាប់រត់ ខ្ញុំថាមិនមែន គឺ មិត្តយ៉ាន់ បាញ់

ខ្លួនឯង។ ខ្ញុំមិនបានទៅរាយការណ៍ជូន តាម៉ុក ទេ ខ្ញុំឃើញបញ្ហានេះមិនស្រួលសោះ ព្រោះជាគោលការណ៍អ្នកដែលចាប់ហើយត្រូវតែកម្ទេច សួរចម្លើយហើយកម្ទេច។ ខ្ញុំរត់មករាយការណ៍តាមមិត្ត-- តាម វន វ៉េត វិញ។ រឿងនេះដឹងដល់ខាងលើ ដឹងដល់មជ្ឈិម ដឹងដល់ បងប៉ុល--

[១៣:៤០:៣៦]

**ស៖** សូមអរគុណ។។ ឥឡូវនេះបើសិនជាយើងមើលចុះទៅក្រោមបន្តិច គឺយើងរំលងចំណុចទីប្រាំ ហើយបន្តទៅកថាខណ្ឌខាងក្រោម នៅស-២១។ "ខ្ញុំខំគេចពីការងារជាអតិបរមា ទទួលតែការងារណាដែលចៀសមិនរួច ម្ល៉ោះខ្ញុំមិនដែលក្តាប់អីបានជាក់ស្តែងទេ។ តើលោកឃើញចំណុចនេះដែរឬទេ? សូមលោកមើលមួយជំហានម្តងៗទៅលើអ្វី ដែលលោកបានសរសេរ។ តើលោកបានឃើញទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំឃើញ។

**ស៖** ហើយតាមសក្ខីកម្មដែលលោកបានធ្វើថ្ងៃនេះ ដែលស្ថិតក្រោមសម្បថនោះនៅពេលដែលលោកនៅមន្ទីរស-២១ នោះ លោកខំគេចពីការងារជាអតិបរមា។ ថាតើលោកចង់បញ្ជាក់យ៉ាងម៉េចដែរទៅលើបញ្ហានេះ?

[១៣:៤១:៥១]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ដែលខ្ញុំគេចនេះនិយាយមួយម៉ាត់ គឺខ្ញុំខំគេចពីការងារនគរបាល។ តែគេចវាមិនរួច តាំងពីដំបូងអើយម្ល៉េះ ខ្ញុំខំគេចៗវាមិនរួច។

**ស៖** ឥឡូវខ្ញុំយល់ហើយ។ ប៉ុន្តែចំណុចដែលខ្ញុំចង់និយាយគឺថា បញ្ជាក់ច្បាស់ថាយើងយល់អំពីលោក។ គឺថានៅពេលដែលលោកនៅមន្ទីរស-២១ ហើយលោកគឺជាអ្នកគ្រប់គ្រងនៅមន្ទីរស-២១ នោះ លោកខំគេចពីការងារជាអតិបរមា តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ត្រឹមត្រូវ!

**ស៖** សូមអរគុណ។ ហើយនៅក្នុងប្រយោគជាមួយគ្នានេះលោកនិយាយផងដែរ ជាប្រយោគដែលលោកពង្រាង ហើយក្រោយមកលោកប្រគល់ទៅឲ្យសហចៅក្រមស៊ើបអង្កេត។ លោកបាននិយាយថា "ម្ល៉ោះខ្ញុំមិនដែលក្តាប់អ្វី ក្តាប់អីបានជាក់ស្តែងទេ"។ តើប្រយោគនេះជាប្រយោគដែលត្រឹមត្រូវដែរឬទេ?

[១៣:៤៣:១៣]

**ឆ៖** ជម្រាបលោកប្រធាន ប្រយោគនេះត្រឹមត្រូវ។

**ស៖** សូមអរគុណ។ ប្រសិនបើយើងបន្តទៅឯកសារថ្មីមួយទៀតគឺឯកសារ D86/20 ហើយនេះជាឯកសារកំណត់ហេតុនៃការសួរចម្លើយរបស់លោកមួយទៀតនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨។ សូមលោកពិនិត្យទៅលើឯកសារនេះ ហើយសូមធ្វើការចាប់អារម្មណ៍ទៅលើឯកសារ 00178020 ដែលជាភាសាខ្មែរ ហើយភាសាអង់គ្លេសគឺ 00194546 ភាសាបារាំង គឺ 0078032។ សូមលោកមើលទៅលើឯកសារនោះបន្តិចទៅហើយខ្ញុំចង់ឲ្យលោកបញ្ជាក់ថា នៅក្នុងឯកសារមួយនេះយើងឃើញថាលោកផ្តល់នូវការអត្ថាធិប្បាយនូវអំពីស្ថានភាពនៃការជួបជាមួយអ្នកកាសែត ហើយនិងសៀវភៅដែលមានចំណងជើងថា “ពេជ្ឈឃាដបាត់ខ្លួន”។ តើនេះជាចំណុចដែលត្រឹមត្រូវដែរឬទេ?

[១៣:៤៥:០៨]

**ឆ៖** ត្រឹមត្រូវ។

**ស៖** តើយើងអាចសន្និដ្ឋានបានដែរឬទេថា ការផ្តល់នូវ ការអត្ថាធិប្បាយនេះគឺ លោកបានអានគឺលោកបាន-- គឺលោកទំនងជាបានអានសៀវភៅរឿង “ពេជ្ឈឃាដបាត់ខ្លួន” នេះ តើយើងអាចសន្និដ្ឋានបែបនេះបានដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ ខ្ញុំបានអាន។

**ស៖** តើសៀវនេះជា-- លោកអានដោយសារតែវាស្ថិតនៅក្នុងសំណុំរឿងរបស់លោក ឬក៏មេធាវីរបស់លោកជាអ្នកប្រគល់ជូនលោក ប្រសិនជាលោកអាចចាំបាន?

**ឆ៖** ខ្ញុំចាំមិនបានទេ ក៏ប៉ុន្តែខ្ញុំអានវាជាខ្មែរ។

[១៣:៤៦:២០]

**ស៖** ចុះសៀវភៅរបស់ ហ្វីលីព ស្សូត និយាយអំពី ប៉ុល ពត ដែលជាភាសាបារាំង តើលោកមានបានធ្លាប់អានសៀវភៅនេះដែរទេ គឺសៀវភៅរបស់លោក ហ្វីលីព ស្សូត?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ ខ្ញុំអត់បានអានសៀវភៅ ហ្វីលីព ស្សូត ទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងសូមទៅឯកសារថ្មីមួយទៀត ដែលជាឯកសារចុងក្រោយនៅក្នុងក្រុមឯកសារដែលយើងចង់ពិភាក្សានេះ។ នេះគ្រាន់តែជាឧទាហរណ៍ គឺឯកសារ D86/27 ជាកំណត់ហេតុនៃការសួរចម្លើយ។ ចំពោះលោក គឺជាកំណត់ហេតុនៃការសួរចម្លើយលោក គឺនៅខែ៥ ឆ្នាំ២០០៨ ហើយយើងសូមពិនិត្យមើលទៅលើឯកសារនេះ ខ្មែរ ERN គឺ 00187654 ដល់ 55 ភាសាអង់គ្លេសគឺ 00204343 ហើយភាសាបារាំងគឺ 00177616 រហូតដល់ 17។ ប្រសិនបើលោកមើលទៅ

លើឯកសារនេះ គឺវាបង្ហាញថា លោកផ្តល់ជូននូវកំណត់ហេតុ ផ្តល់ជូនចៅក្រមនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីសៀវភៅរបស់លោក ដេវីដ ឆេនដ័ល័រ ដែលនិយាយអំពីសំឡេងពីមន្ទីរស-២១ ដែលនិយាយអំពីប្រវត្តិនៃពន្ធនាគារសម្ងាត់របស់ ប៉ុល ពត តើវាជាការត្រឹមត្រូវដែរឬទេ?

[១៣:៤៨:៣៤]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ពាក្យដែលសរសេរចំនួនពីរបន្ទាត់ នៅលើកំណត់ហេតុសួរចម្លើយនេះត្រឹមត្រូវ។

**ស៖** សូមអរគុណ។ ដូច្នេះ ខ្ញុំសម្គាល់ឃើញថា លោកពិត-- លោកប្រហែលជាបានអានសៀវភៅនេះតើត្រឹមត្រូវដែរឬទេ? ដោយសារ-- ប៉ុន្តែវាមិនមានអ្វីផ្សេងនៅក្នុងឯកសារនេះ ដែលលោកអាចយោងទៅមើលទេ។

**ឆ៖** ត្រូវហើយ សៀវភៅនេះខ្ញុំបានអានមួយគ្រួស ដូចជាមិនបានអស់ទេ ដែលពាក់កណ្តាល។

**ស៖** សូមអរគុណ។ តើមានហេតុផលអ្វីដែលលោកអានតែពាក់កណ្តាល។ ថាតើលោកមានចំណាប់អារម្មណ៍តែពាក់កណ្តាល ឬមួយក៏លោកមានពេលវេលាមិនគ្រប់គ្រាន់ ឬមួយក៏គ្រាន់តែថាវាជាផ្នែកសំខាន់សម្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេតទៅលើផ្នែកនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមួយចំនួនទៀត ដូចជាឃើញថា សៀវភៅហ្នឹងមិនមានសារៈសំខាន់អី។

[១៣:៥០:១៥]

**ស៖** ដូច្នេះផ្នែកដែលលោកផ្តល់មតិយោបល់ គឺជាផ្នែកដែលលោកគិតថាសំខាន់។ តើមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ផ្នែកនៅក្នុងសៀវភៅ ដេវីដ ឆេនដ័ល័រ ដែលខ្ញុំចាប់អារម្មណ៍យកមកអធិប្បាយជូនសហចៅក្រមស៊ើបអង្កេត ជាផ្នែកដែលខ្ញុំចាប់អារម្មណ៍ថាសំខាន់។

**ស៖** ដូច្នេះ ខ្ញុំអាចនិយាយបានថា សហចៅក្រមស៊ើបអង្កេតមិនបានស្នើឲ្យលោកផ្តល់នូវការកត់សម្គាល់ ទៅលើផ្នែកណាមួយនៃលើសៀវភៅនោះដែរមែនទេ? តើមែនឬទេ?

**ឆ៖** បើតាមខ្ញុំចាំ គឺមែន។

**ស៖** ដូច្នេះ ទាក់ទងទៅនឹងការកត់សម្គាល់នៅលើសៀវភៅនោះ តើលោកមានបានពិភាក្សាជាមួយឯកសារដទៃទៀតដែលមាននៅក្នុងសំណុំរឿង ហើយដែលលោកអាចចូលទៅពិនិត្យបានដែរឬទេ?

តើលោកអត់មានពិភាក្សាជាមួយឯកសារផ្សេងទៀតទេឬ? ប្រសិនបើលោកអាចឆ្លើយនូវសំណួរនេះបាន ខ្ញុំសូមអរគុណយ៉ាងខ្លាំង។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បញ្ហាមានពីរ។ ទីមួយចិត្តខ្ញុំដែលចង់បានយកមកដាក់ក្នុងដៃខ្ញុំ គឺឯកសារថ្ងៃ៣០ មីនា ១៩៧៦ នេះជាការពិត។ ឯបញ្ហាមួយទៀត ខ្ញុំចង់និយាយអំពី ដេវីដ ឆេនដ៍ល័រ ហាក់ដូចជាឲ្យតម្លៃថា ប៉ុល ពត ជាសិស្សរបស់ ម៉ៅ សេទុង ជាពិសេសសិស្សនៃឯកសារអំពីការដោះស្រាយត្រឹមត្រូវមានទំនាស់ក្នុងផ្ទៃប្រជាជន។ ខ្ញុំបដិសេធថា “មិនមែន” ព្រោះខ្ញុំបានអានឯកសារនេះច្បាស់លាស់ដែរ។ នេះ ខ្ញុំចាប់អារម្មណ៍តែពីរហ្នឹងទេ។ ឯកសារក្រៅអំពី ដេវីដ ឆេនដ៍ល័រ ខ្លួនឯង។

[១៣:៥២:៥៣]

**ស៖** ដូច្នេះ ខ្ញុំសូមធ្វើការបកស្រាយទៅលើចម្លើយនោះគឺថា “បាទ ខ្ញុំបានពិនិត្យមើលទៅលើឯកសារដែលមាននៅក្នុងសំណុំរឿងក្នុងការផ្តល់ចម្លើយ ក៏ដូចជាការផ្តល់មតិយោបល់ ទាក់ទងទៅនឹងសៀវភៅរបស់លោក ដេវីដ ឆេនដ៍ល័រ”។ តើនេះគឺជាការសង្ខេប ឬក៏ជាលក្ខណៈនៃអ្វីដែលលោកចង់ឆ្លើយ? តើមែនឬទេ?

**ឆ៖** មែន។

**ស៖** ហើយនៅពេលដែលលោកបាននិយាយក្នុងពេលឥឡូវនេះ ដែលយើងឃើញនៅក្នុងឯកសារនេះតើលោកផ្តល់ការកត់សម្គាល់ទៅលើ-- ទាក់ទងទៅនឹងថ្ងៃ៣០ មីនា ឆ្នាំ៧៦ គឺសេចក្តីសម្រេចថ្ងៃ៣០ មីនា ឆ្នាំ៧៦ តើមែនដែរឬទេ? តើលោកមានយោងទៅលើសេចក្តីសម្រេចនោះ នៅក្នុងការវិភាគរបស់លោកដែរឬទេ? គឺថា មុនពេលដែលលោកមកដល់អង្គជំនុំជម្រះ អ.វ.ត.ក នេះ ថាតើលោកមានបានពិនិត្យឯកសារនោះដែរឬទេ?

[១៣:៥៤:១៥]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ឯកសារហ្នឹងដូចជាបានក្រោយអត្ថបទខ្ញុំទេ ឬក៏មុនក៏មិនដឹង។ ខ្ញុំភ្លេចទៅហើយ ប៉ុន្តែមាន ប្រដំប្រសងគ្នាហ្នឹង ឯកសារថ្ងៃ៣០ មីនា ហើយនិងអត្ថបទខ្ញុំនេះ។

**ស៖** បើតាមខ្ញុំយល់ ខ្ញុំអាចបង្ហាញឯកសារនោះប្រសិនបើចាំបាច់។ ដូច្នេះខ្ញុំយល់ថាចន្លោះឆ្នាំ៧៥ ដល់៧៦ លោកមិនដែលឃើញឯកសារនេះ។ បានន័យថា មិនដែលឃើញសេចក្តីសម្រេចឆ្នាំ៧៦ នេះទេ តើមែនឬទេ?

[១៣:៥៥:០១]

**ឆ៖** ត្រឹមត្រូវ។ ឯកសារនោះត្រូវបានការិយាល័យសហចៅក្រមស៊ើបអង្កេតផ្ដល់មកឲ្យខ្ញុំ ដូច មានថ្ងៃខែកំណត់ច្បាស់លាស់។

**ស៖** អូខេ ខ្ញុំត្រូវតែត្រៀមខ្លួនកុំឲ្យនិយាយលឿនពេក។ ដូច្នេះតើ ដេវីដ ឆេនដ៏ល័រ មានបាន ពិភាក្សាអំពីសេចក្ដីសម្រេចមួយនោះដែរឬទេ នៅក្នុងសៀវភៅរបស់គាត់? តើគាត់មានលើកយកមក បង្ហាញទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បើតាមខ្ញុំចាំ ដេវីដ ឆេនដ៏ល័រ សរសេរខ្លីណាស់។ គាត់ សរសេរថា "ឯកសារថ្ងៃ៣០ មីនា ១៩៧០ នេះជាឯកសារជាលាយលក្ខណ៍អក្សរដំបូង ដែលរកឃើញ អំពីការកំណត់អ្នកដែលមានសិទ្ធិអំណាចកម្ទេច"។ នេះទីមួយ ខ្ញុំចាំ។ ហើយទីពីរទៀត ដេវីដ ឆេនដ៏ល័រ ចាប់អារម្មណ៍អំពីការដែល ប៉ុល ពត គាត់បញ្ជាឲ្យបំផ្លាញសាលវិហារកាតូលិក។ ដែលគាត់សរសេរ នៅក្នុងនុំងថា អ៊ុំងកូ។ នេះខ្ញុំចាំប៉ុណ្ណឹង។ ដាវីដ ឆេនដ៏ល័រ សរសេរប៉ុននុំងទេ។

[១៣:៥៦:២៥]

**ស៖** ដូច្នេះចម្លើយរបស់លោកចំពោះសំណួរខ្ញុំគឺថា "បាទ" គឺនៅក្នុងសៀវភៅនេះ បាននិយាយ ថាអំពីសេចក្ដីសម្រេចមួយនោះ មែនទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** ហើយលោកផ្អែកទៅលើខ្លួនឯង ដើម្បីផ្ដល់មតិយោបល់ទៅលើអ្វីដែលគាត់មិនបានផ្ដល់ មតិយោបល់ទាក់ទងទៅនឹងសេចក្ដីសម្រេចមួយនេះ មែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំៗបានផ្ដល់មតិយោបល់លើសពី ដេវីដ ឆេនដ៏ល័រ មែន។

**ស៖** ហើយនៅក្នុងការផ្ដល់មតិយោបល់បន្ថែមលើ ដេវីដ ឆេនដ៏ល័រ ជាពិសេសទាក់ទងនឹង សេចក្ដីសម្រេចមួយនេះ តើលោកមានបានពិគ្រោះជាមួយឯកសារ ឬក៏សៀវភៅដទៃទៀតដែលលោក បានទទួលដែរឬទេ? ប្រសិនបើលោកចាំ សូមលោកជម្រាបផង។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់មានពឹងផ្អែកលើឯកសារណាក្រៅពី ដេវីដ ឆេនដ៏ល័រ ទេ គឺខ្ញុំពឹងផ្អែកទៅលើសភាពការណ៍ជាក់ស្ដែង ដែលកើតឡើងជំនាន់នោះ។

[១៣:៥៧:៥២]

**សៈ** សូមអរគុណ។ ឥឡូវនេះយើងបន្តទៅផ្នែកផ្សេងមួយទៀត ហើយយើងអាចពិនិត្យមើលទៅលើឯកសារ D227 គឺ D227 ដែលជាកំណត់ហេតុនៃការសួរចម្លើយ គឺការសួរចម្លើយទៅលើលោកផ្ទាល់គឺនៅថ្ងៃ២១ ខែ១០ ឆ្នាំ២០០៩។ ខ្ញុំស្នើសុំឲ្យមានជំនួយ គឺ D227។

**ប្រធានអង្គជំនុំ៖**

មានទេលោក? ទៅយកពីគាត់មក!

[១៣:៥៨:៥៣]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមអភ័យទោស!

**សៈ** លោកសាក្សី សូមលោកពិនិត្យមើលទៅលើឯកសារមួយនេះ ហើយសូមលោកចាប់អារម្មណ៍ទៅលើ ERN ខ្មែរ 00398200 ភាសាអង់គ្លេស 00398208 និងភាសាបារាំង 00398216។ ខ្ញុំចង់ផ្តោតទៅលើចម្លើយតបដែលផ្តល់ដោយជនត្រូវចោទ គឺខ្លួនលោកផ្ទាល់នៅពេលនោះ ហើយខ្ញុំសូមដកស្រង់មួយចំនួនទៅលើផ្នែកនោះ ប្រសិនបើលោកនេះ សូមលោកតាម។ លោកត្រូវបែងចែក-- គេត្រូវបែងចែករវាងទ្រឹស្តី និងការអនុវត្ត។

[១៤:០០:០៨]

ក្នុងទ្រឹស្តី ការបែងចែកអំណាចត្រូវបានកំណត់ច្បាស់នៅក្នុងសេចក្តីសម្រេច ៣០ មីនា ១៩៧៦។ ការបែងចែកមុខងារនៅក្នុងការកម្ទេចខ្មាំងត្រូវបានរៀបចំឡើងរវាងលេខាភូមិភាគ ប្រធានគណៈកម្មាធិការមន្ទីរ៨៧០ តំបន់ឯករាជ្យ និងលេខាសេធិការ។ មានករណីដោយឡែកពីរ គឺក្រសួងការបរទេស និងក្រសួងសេដ្ឋកិច្ចដែលមិនមានការថែងទាក់ទងនឹងបញ្ហាសន្តិសុខនោះទេ។ នៅក្នុងអនុវត្តជាក់ស្តែងអំណាចទាំងអស់ គឺនៅក្នុងដៃរបស់ ប៉ុល ពត។ តើលោកឃើញកថាខណ្ឌមួយនេះដែរឬទេ? តើលោកឃើញកថាខណ្ឌដែលនិយាយអំពីចម្លើយរបស់លោកនេះដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំឃើញ។

[១៤:០១:២៥]

**សៈ** សូមអរគុណ។ ហើយខ្ញុំសង្កេតឃើញ ថានៅកន្លែងនេះ លោកនិយាយអំពីទ្រឹស្តី ធៀបជាមួយនឹងការអនុវត្ត គឺថា-- ទ្រឹស្តីធៀបជាមួយនឹងការអនុវត្ត។ នៅក្នុងទ្រឹស្តី លោកនិយាយអំពីចំណុចមួយ ប្រសិនបើខ្ញុំយល់មិនខុសទេ គឺនៅក្នុងការអនុវត្តគឺផ្សេង។ គឺអ្វីដែលអនុវត្តហ្នឹងគឺផ្សេង តើខ្ញុំយល់

បែបនេះ ត្រឹមត្រូវដែរឬទេ ទាក់ទងទៅនឹងចម្លើយរបស់លោក?

[១៤:០១:៥៩]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយបត។ សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ដើម្បីឲ្យយុត្តិធម៌ចំពោះសាក្សី គឺយើងត្រូវដកស្រង់នូវប្រយោគពីរទៀត ដែលទាក់ទងជាមួយនឹងអ្វីដែលមេធាវីការពារក្តីបានចោទសួរ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំទុកឲ្យចៅក្រម-- លោកចៅក្រមមេត្តាសម្រេចតាមឆន្ទានុសិទ្ធិ ដោយសារតែមានពេលវេលាកំណត់ ទើបខ្ញុំត្រូវជ្រើសរើសតែចំណុចនេះលើកមក។ វាផ្ទុយពីខាងព្រះរាជអាជ្ញា ដែលគាត់មានពេលដល់ទៅប្រាំមួយថ្ងៃឯណោះ។

[១៤:០៣:០៣]

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីរៀបចំនូវសំណួរឡើងវិញ ឲ្យបានខ្លី សាមញ្ញ ដើម្បីសាក្សីអាចងាយយល់នូវសំណួរ ហើយនិងអាចឆ្លើយតបចំទៅនឹងសំណួរដែលបានសួរគាត់។ ចៀសវាងការតាំងសំណួរដែលមានលក្ខណៈលំបាកស្មុគស្មាញ នាំឲ្យពិបាកយល់នៅក្នុងការឆ្លើយតប។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី លោកបានអានចម្លើយដែលលោកឆ្លើយរួចហើយ។ ដូច្នេះ តើលោកអាចប្រាប់ដែរទេ តើលោកមានន័យយ៉ាងម៉េច រវាងទ្រឹស្តីនិងការអនុវត្តនោះ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ជាទ្រឹស្តីជាគោលការណ៍គឺលេខាភាគមានសិទ្ធិសម្រេចនៅក្នុងក្របខ័ណ្ឌរបស់ខ្លួន។ នេះធ្លាប់គោរពតាំងពី៧១ មកម្ល៉េះ។ ក៏ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង មាន

បញ្ហាមិនច្បាស់លាស់ជាអ៊ីចឹងទេ ទ្រឹស្តី-- អំនែ! លក្ខខណ្ឌ កង ចាប ជាឧទាហរណ៍ស្រាប់។

[១៤:០៥:១៥]

**ស៖** សូមអរគុណ។ យើងសូមចូលទៅដល់ប្រធានបទមួយទៀត។ ប្រសិនបើយើងនិយាយព្រឹកមិញយើងនិយាយបន្តិចអំពីការភ័យខ្លាច។ ដូច្នេះសូម-- ប្រសិនបើយើងចូលទៅដល់ឯកសារលេខ E3/106 ហើយខ្ញុំសូមឱ្យលោកចាប់អារម្មណ៍ត្រង់ទំព័រ 00177626 ដែលលេខ-- ដែលជាលេខERN ជាភាសាខ្មែរ។ លេខ ERN ជាភាសាអង់គ្លេស គឺ 00-- (សូមអធ្យាស្រ័យ) ឯកសារខ្មែរអម្បាញ់មិញ 26 ដល់ 27។ អង់គ្លេសលេខ ERN គឺ 00177636 ដល់ 37 បានន័យថាឆ្លងទៅទំព័រមួយទៀតដែលលោកត្រូវមើល។ ហើយបារាំង គឺ 00177647 ដល់ 48។ នៅក្នុងនោះ គឺមានសំណួរមួយបានចោទសួរទៅកាន់លោក ហើយនៅចុងទំព័រជាភាសាអង់គ្លេស។ "ទំនាក់ទំនង ប្រសិនបើលោកធ្លាប់មានទំនាក់ទំនងល្អជាមួយគាត់ ហេតុអ្វីបានជាលោកទុកឱ្យគេធ្វើទារុណកម្មគាត់?" ហើយនៅក្នុងបរិបទនេះ គឺគេនិយាយអំពីករណី វន វ៉េត។ ហើយក្រោយមកគេហៅលោកថាជា "ឃាតករ"។ ដូច្នេះនេះជាបរិបទជុំវិញហ្នឹង។

[១៤:០៧:១២]

បន្ទាប់មកចៅក្រមបានសួរសំណួរមួយទៅកាន់លោក ដែលសំណួរនោះសរសេរថា "ប្រសិនបើលោកមានជជែកជាមួយនឹងលោក វន វ៉េត គឺ-- ប្រសិនបើលោកមានការពិភាក្សាបែបនេះជាមួយ វន វ៉េត ហើយតាមអ្វីដែលលោកបានពន្យល់ យើងកាលពី-- ពន្យល់យើងកាលពីព្រឹកមិញនេះ គឺតើគេមិនមែនដោយសារតែលោកសួរសំណួរទាក់ទងទៅនឹងការបដិវត្តន៍របស់នៃរបប និងឧក្រិដ្ឋកម្មដែលរបបនេះបានប្រព្រឹត្តទៅទេឬ? តើលោកមាននិយាយប្រាប់ វន វ៉េត អំពីការព្រួយបារម្ភរបស់លោកដែរឬទេ? ឆ្លើយ៖ មិនមែន ទិសដៅនៃការជួបសន្ទនានេះ គឺដើម្បីការពារខ្លួនពីកំហុសដែល ប៉ុល ពត អាចស្តីបន្ទោសខ្ញុំ។ វាគឺជាការធ្វើយ៉ាងណាកុំឱ្យ ប៉ុល ពត អាចយកលេសចាប់ខ្ញុំដោយងាយស្រួលពេក"។ តើលោកចាំថាបានឆ្លើយអ៊ីចឹងដែរឬទេ កាលពីលើកមុន?

[១៤:០៨:៣៨]

លោកសាក្សី ខ្ញុំចាប់អារម្មណ៍ចំណុចដែលខ្ញុំអានអម្បាញ់មិញនេះ គឺមិនមែនចាប់អារម្មណ៍ទៅលើអត្ថបទទាំងអស់នោះទេ។ តើលោកចាំថាបានឆ្លើយដូច្នេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ចម្លើយខ្ញុំដូចជាមានន័យទូលាយ រកកំណត់ទិសដៅ

មិនបានទេ ចម្លើយអង្កាល់នោះ។ ទិសដៅនៃការជួបសន្ទនានេះ គឺដើម្បីការពារខ្លួនខ្ញុំពីកំហុសដែល ប៉ុល ពត អាចស្តីបន្ទោសខ្ញុំ។ វាគឺជាការធ្វើយ៉ាងណា កុំឱ្យ ប៉ុល ពត អាចយកលេសចាប់ខ្ញុំដោយងាយស្រួលពេក។ ដូច្នេះវាដាច់សាច់រឿងហើយ។ ខ្ញុំមិនដឹងជាពេលនោះយ៉ាងម៉េចទេ បានជាខ្ញុំឆ្លើយអ៊ីចឹង។ វាដាច់សាច់រឿងអស់ទៅហើយ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ថា ទីមួយ ខ្ញុំអាចឆ្លើយអ៊ីចឹងមែន បានជាគេកត់អ៊ីចឹង។ ក៏ប៉ុន្តែតើជាក់ស្តែងវាយ៉ាងម៉េច? អានេះខ្ញុំវង្វេងហើយ ព្រោះវាដាច់ពីសាច់រឿងមួយកំណាត់តូចនេះ។

[១៤:១០:១៣]

**ស៖** សូមអរគុណ។ តើការពិតដែរឬទេ ដែលថាលោកព្យាយាមយកព័ត៌មានពី វន វ៉េត ដែលជាគ្រូរបស់លោក ធ្លាប់ជាគ្រូរបស់លោក ហើយដើម្បីយកធ្វើជាលេសចៀសវាងកុំឱ្យមានការចាប់ដោយងាយស្រួលពី ប៉ុល ពត។ តើមែនអ៊ីចឹងមែនដែរឬទេ?

**ឆ៖** អរគុណ។ ដូច្នេះខ្ញុំសូមរំឭករឿងនេះឡើងវិញ ខ្ញុំពិតជាមាននិយាយមែន មានបំណងអ៊ីចឹងមែន។ នៅពេលដែល វន វ៉េត គាត់មកដល់ ស-២១ មកពីល្ងាច ព្រឹកឡើងខ្ញុំទៅពីព្រលឹមមុនគេ។ ទៅហ្នឹង ក្នុងគោលបំណងសុំទោសគាត់ រួចហើយ ខ្ញុំសួរគាត់ ថារឿងអីបាន បងប៉ុល ចាប់បងឯង។ គាត់ឆ្លើយថា មិត្តអើយ បងប៉ុល ពិបាកណាស់--

[១៤:១១:១០]

**ស៖** ខ្ញុំសូមកាត់សម្តីលោកសាក្សី! ដោយសារតែយើងមានពេលវេលាកំណត់។ សូមឱ្យលោកឆ្លើយតែសំណួរបានហើយ។ លោកបានជម្រាបអំពីការសុំអធ្យាស្រ័យ ដោយសារតែ វន វ៉េត ត្រូវបានធ្វើទារុណកម្មសម្លាប់ចោល។ ខ្ញុំចាប់អារម្មណ៍តែចម្លើយដែលលោកឆ្លើយនៅក្នុងឯកសារនេះតែប៉ុណ្ណោះ បានន័យថា លោកព្យាយាមយកព័ត៌មានពី វន វ៉េត ជាប្រយោជន៍ជួយដល់លោក នៅពេលដែលលោកធ្វើអ្វីកុំឱ្យគេចាប់លោកបាន។ តើមែនអ៊ីចឹង មែនដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ ដែលខ្ញុំទៅសួរ វន វ៉េត ហ្នឹង គឺដើម្បីឱ្យ វន វ៉េត ពន្យល់ថា តើប៉ុល ពត ហ្នឹងជាមនុស្សយ៉ាងម៉េច? ដើម្បីខ្ញុំការពារខ្លួនខ្ញុំទៅថ្ងៃមុខ កុំឱ្យ វន វ៉េត-- កុំឱ្យប៉ុល ពត គាត់-- កុំឱ្យខ្ញុំធ្លាប់ទៅក្នុងពិសោធរបស់ វន វ៉េត ទៀត។ នេះគឺអ៊ីចឹង ដែលខ្ញុំទៅជួប វន វ៉េត។

[១៤:១២:១១]

**ស៖** ខ្ញុំអរគុណ។ ខ្ញុំសូមត្រឡប់ទៅសំណួរព្រឹកមិញដែលខ្ញុំសួរ ដែលលោក-- ខ្ញុំសួរអំពីករណីដែលលោកសួរ ប៉ង់ ថាតើមានអ្វីកើតឡើងនៅក្នុងគណៈអចិន្ត្រៃយ៍ ហើយខ្ញុំសួរ ប៉ង់ ថាតើ-- សួរទៅ

ករណី ប៉ង់ ដែលថា លោកសួរ ប៉ង់ ដើម្បីកុំឲ្យលោកជួបបញ្ហា។ ដូច្នេះ ថាតើនៅពេលដែលលោកទៅសួរព័ត៌មានពី ប៉ង់ ដើម្បីកុំឲ្យលោកធ្លាក់ចូលទៅក្នុងអន្ទាក់របស់ ប៉ុល ពត ឬក៏យ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ដែលខ្ញុំសួរ ប៉ង់ នេះករណីដោយឡែកមួយច្បាស់លាស់ករណីចំបញ្ហាមួយច្បាស់លាស់ គឺការសម្រេចចាប់ខ្លួន ជូ ជេត ហៅ ស៊ី។ តើមានអន្តរាគមន៍ជួយសម្រាលពី វន វ៉េត ដែរឬទេ? នេះបំណងខ្ញុំ ដែលខ្ញុំសួរ ប៉ង់។ តែប៉ុណ្ណឹងឯង។

**ស៖** សូមអរគុណ។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ ព័ត៌មានដែលលោកបានពិភាក្សាជាមួយ ប៉ង់ នោះ គឺវាជាព័ត៌មានពាក់ព័ន្ធទៅនឹងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍។ តើត្រឹមត្រូវដែរឬទេ គឺព័ត៌មានដែល ប៉ង់ ប្រាប់លោកនោះ?

**ឆ៖** ពិតណាស់ហើយ វាពាក់ព័ន្ធដល់ការប្រជុំអចិន្ត្រៃយ៍។

[១៤:១៣:៤៩]

**ស៖** សូមអរគុណ។ សំណួរដូចគ្នាដែលលោកបានសួរលោកកាលពីព្រឹកមិញ អំពី សុន សេន គ្មានសរសេរជាក់លាក់ដែលយើងអាចពិនិត្យមើល ដែលអាចកត់ត្រាការជជែកសន្ទនារបស់លោកនាពេលនោះជាមួយនឹងលោក សុន សេន។ ហើយកំណត់ត្រាទាំងអស់នោះ វាអាចផ្ទៀងផ្ទាត់ថាលោកពិតជាមានការធ្វើការសន្ទនាជាមួយនឹង ប៉ង់។ អ៊ីចឹងលោកជាមួយនឹង ប៉ង់ លោកក៏អត់មានកត់ត្រាទុកជាក់លាក់ដែរ មែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់មានកត់ត្រាទេ ការសន្ទនាជាមួយនឹង ប៉ង់ ក៏ដូចជាការណែនាំពន្យល់ប្រាប់របស់ សុន សេន អត់មានកត់ត្រាទេ។

**ស៖** សូមអរគុណ។ ប្រសិនបើយើងមើលឯកសារមួយទៀត គឺD86/21។ ឯកសារ D86/21 វាជាកំណត់ហេតុនៃការសួរចម្លើយ ដែលលោកបានឆ្លើយនៅថ្ងៃ២៨ ខែមីនា ឆ្នាំ២០០៨។ ប្រសិនបើខ្ញុំសូមឲ្យលោកពិនិត្យមើលខ្មែរ ERN ត្រង់លេខ 00177581 អង់គ្លេស 00177588 បារាំង 00177596។ ខ្ញុំនឹងអានចម្លើយរបស់លោកមួយ ដែលលោកបានឆ្លើយថា ខ្ញុំបញ្ជាក់ថា បក្សជាអ្នកសម្រេចក្នុងការគ្រប់គ្រងប្រទេសទៅតាម-- ដូចដែលមានចែងនៅក្នុងលក្ខន្តិកៈមាត្រា២ ឬមាត្រា៣។ ដូច្នេះចំណុចនេះមានន័យថា គ្រប់សេចក្តីសម្រេចរបស់លេខា ឬអនុលេខាបក្សត្រូវតែគោរពតាម ហើយអ្នកណាមិនគោរពតាមត្រូវតែកម្ទេច តាមគោលការណ៍ដែលកកំណត់ដោយ សុន សេន "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"។ លោកបានចាំថាលោកបានឆ្លើយថាអ៊ីចឹងមែនទេលោក?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំចាំថា ខ្ញុំបានឆ្លើយអ៊ីចឹងមែន។

[១៤:១៦:៤១]

**ស៖** សូមអរគុណ។ ដូច្នេះតាមចម្លើយរបស់លោក សូមឲ្យលោកកែខ្ញុំ ប្រសិនជាខ្ញុំយល់ខុស។ តាមចម្លើយរបស់លោកនោះគឺបង្ហាញថា "បុគ្គលទាំងឡាយត្រូវតែគេកម្ទេចចោល ក្រៅតែពី នួន ជា និង ប៉ុល ពត" តាមចម្លើយរបស់លោកបានន័យថាអ៊ីចឹង ក្រៅតែពី ប៉ុល ពត និង នួន ជា ក្រៅពីហ្នឹងគឺគេកម្ទេចចោលទាំងអស់។ តើមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ខ្ញុំមិនយល់ស្របជាមួយទេ។

**ស៖** សូមអរគុណ។ វន វ៉េត ត្រូវបានគេកម្ទេចចោល តើមែន ឬមិនមែន?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន វន វ៉េត ត្រូវបានគេចាប់មកឲ្យស-២១ សួរចម្លើយហើយកម្ទេច មែន។

[១៤:១៧:៥៥]

**ស៖** ខ្ញុំសួរថា តើគាត់ត្រូវបានគេកម្ទេច ឬក៏អត់?

**ឆ៖** ពិតជាត្រូវបានគេកម្ទេច។

**ស៖** តើអ្នកដែលនៅ-- អ្នកដែលមានឋានៈខ្ពស់ៗនោះថា តើត្រូវបានគេកម្ទេចចោលដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ត្រូវបានគេកម្ទេច។

**ស៖** សូមអរគុណ។ យើងចូលទៅដល់ឯកសារមួយទៀតផ្សេង ប្រសិនបើយើងមើលឯកសារ D119។ នេះគឺជាកំណត់ហេតុនៃការសួរចម្លើយរបស់លោកមួយច្បាប់ទៀត ហើយប្រសិនបើខ្ញុំសូមឲ្យលោកចាប់អារម្មណ៍ត្រង់ទំព័រ ដែលមានលេខ ERN ជាភាសាខ្មែរ 00242893 00242893 លេខ ERN ជាភាសាអង់គ្លេសគឺ 00242904 បារាំងគឺ 00242915។

[១៤:១៩:២៩]

នៅត្រង់ចំណុចនេះ លោកបានឆ្លើយតបទៅនឹងសំណួរមួយ ដែលសំណួរនោះពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន តែចម្លើយរបស់ដែលលោកនោះគួរឲ្យចាប់អារម្មណ៍ណាស់។ លោកបានឆ្លើយថានៅក្នុងរបបខ្មែរក្រហមមានមនុស្សនៅពីមុខ ដែលលាក់បាំងមនុស្សសំខាន់។ តើលោកបានឃើញចម្លើយហ្នឹងដែរឬទេ?

**ឆ៖** នេះជាចម្លើយរបស់ខ្ញុំ។

**ស៖** អ៊ីចឹងលោកនៅតែរក្សាទៅនឹងចម្លើយនេះដែរ-- រក្សាសម្ដីនេះដែរឬទេ?

**ឆ៖** នៅតែរក្សា។

**ស៖** ប្រសិនយើងចូលឯកសារមួយទៀតគឺ D90 ជាពិសេស ខ្ញុំចង់ឲ្យលោកផ្ដោតការយកចិត្តទុកដាក់របស់លោកត្រង់ខ្មែរលេខ ERN 00198874 អង់គ្លេស ERN គឺ 00198883 បារាំងគឺ 00197984។ ខ្ញុំចង់អានចំណុចមួយ ដែលលោកឆ្លើយថា ក្នុងចំណោមសមាជិកទាំង៧រូប នៃគណៈកម្មាធិការអចិន្ត្រៃយ៍មានបីនាក់ទទួលបន្ទុកផ្នែកសន្តិសុខ ប៉ុល ពត, នួន ជា និង សុន សេន។ តើលោករក្សាសម្ដីនេះដដែលដែរឬទេលោក?

[១៤:២១:៣៦]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ ខ្ញុំរក្សាសម្ដីនេះរហូត។

**ស៖** ដូច្នេះលោកបានន័យថា បុគ្គលទាំងបីរូបនេះ តាមអ្វីដែលលោកយល់ និងដឹង មានអំណាចក្នុងការចាប់ខ្លួនបុគ្គលទាំងឡាយ មែនដែរឬទេ?

**ឆ៖** ក្នុងចំណោមបុគ្គលទាំងបីរូបនេះ អ្នកដែលមានអំណាចធំក្នុងគ្រប់ករណីសម្រេចគឺ ប៉ុល ពត។

**ស៖** ខ្ញុំធ្វើយ៉ាងណាឲ្យខ្ញុំឲ្យបានច្បាស់ទៅលើចម្លើយរបស់លោក។ មានន័យថា ប៉ុល ពត អាចចាប់លោក ខៀវ សំផន ឬក៏ អៀង សារី បានន័យអ៊ីចឹងដែរឬទេលោក?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ប៉ុល ពត អាចចាប់ទាំង ខៀវ សំផន អាចចាប់ទាំង អៀង សារី អាចចាប់ទាំង នួន ជា ទៀតផង។ នេះបើនិយាយពីអំណាចពិតប្រាកដ។ ក៏ប៉ុន្តែបញ្ហានៅនិយាយមួយទៀត តើមូលដ្ឋានអី ដែលនាំឲ្យគាត់សម្រេចចាប់អ្នកណាមួយ?

**ស៖** បាទ សូមអរគុណ។ ដូច្នេះវា ដូចទៅនឹងករណី កុយ ធួន, ហ៊ូ យន់ និង វន វ៉េត ដូចគ្នាទាល់តែមានហេតុផលគ្រប់គ្រាន់ ទើបអាចចាប់ខ្លួនបាន ធ្វើទារុណកម្ម ហើយសម្លាប់ចោល មែនដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបនឹងសំណួរ!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៤:២៣:៥០]

**លោក វីល្លៀម ស្មីត៖**

សំណួរនេះហាក់ដូចជាមិនច្បាស់សោះ។ មេធាវីគឺអាចសួរថា តើមានហេតុផលអ្វី ដែលគេចាប់ខ្លួនអ្នកទាំងបីនាក់នោះ? ឬក៏មានហេតុផលដូចគ្នាដែលត្រូវបាន-- ដែលគេចាប់អ្នកទាំងបីនោះ?

**លោក ម៉ៃខល កាណាវាស៖**

លោក លោកស្រីចៅក្រម លោកសាក្សីនេះគឺបានផ្តល់ចម្លើយយ៉ាងច្រើន ក្នុងរយៈពេល៦ថ្ងៃជាងនេះទៅលើបញ្ហាហ្នឹង។ ដូច្នេះ ខ្ញុំមិនចាំបាច់ផ្តល់ជាមូលដ្ឋានណា ដែលគេចាប់អ្នកទាំងបីនាក់នោះទេ។ បានន័យថា អ្នកទាំងអស់នោះគឺត្រូវបានគេចាប់ខ្លួន និងកម្ទេចចោលរួចទៅហើយ ហើយមានមូលដ្ឋានដូចដែលគាត់បានរៀបរាប់។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ដូច្នេះលោកសាក្សីតើលោកអាចឆ្លើយនឹងសំណួរហ្នឹងដែរឬទេលោក បើសិនជាអត់បានទេ ខ្ញុំអាចបន្តទៅមុខទៀត?

[១៤:២៤:៣៩]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន សូមលោកមេធាវីសួរមួយម៉ាត់ទៀតមក ម្តងទៀតមក ខ្ញុំភ្លេចបាត់ហើយ។

**ស៖** សូមអរគុណលោកសាក្សី។ លោកបានបញ្ជាក់ថា ទាល់តែមានមូលដ្ឋានត្រឹមត្រូវទើបលោក អៀង សារី, ខៀវ សំផន ត្រូវបានគេអាចចាប់ខ្លួនបាន។ ដូច្នេះ ចំពោះ វន វ៉េន និងអ្នកដទៃទៀតទាល់តែមានមូលដ្ឋានគ្រប់គ្រាន់ទើបអាចចាប់ខ្លួនបាន។ អ៊ីចឹង បានន័យថា មានហេតុផលគ្រប់គ្រាន់ដែរឬទេ ដែលទាមទារឲ្យចាប់អ្នកទាំងអស់នោះ នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន លេខាបក្សសម្រេចចាប់ គឺវាមានហេតុផលគ្រប់គ្រាន់សម្រាប់ដែលរបស់គាត់ ដែលគាត់យល់ថាគ្រប់គ្រាន់។ សូមបញ្ជាក់មួយម៉ាត់ទៀត ដែលគាត់យល់ថាគ្រប់គ្រាន់។

**ស៖** ជាការពិតនៅពេលនោះ គឺលោកបានដឹង ហើយសូមលោកកែខ្ញុំ ប្រសិនបើខ្ញុំលើកឡើងខុស។ ថាតើមានលេសណាមួយដែលគេបានប្រើប្រាស់ដើម្បីចាប់ខ្លួន? ឧទាហរណ៍ថា ចោទប្រកាន់

បុគ្គលណាមួយម្នាក់ដោយបង្ខំថា ជាភ្នាក់ងារ សេ.អ៊ី.អា, ភ្នាក់ងារ កា.ហ្សេ.ប ឬក៏ជាការខ្លួនជាខ្មែរក្បាលយួន។ តើមានលេសអ្វីចឹងកើតទេ?

[១៤:២៦:២៤]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនយល់សំណួរនេះទេ។ សូមលោកមេធាវីសួរម្តងទៀតមក។

**ស៖** ខ្ញុំនឹងសួររបៀបផ្សេងវិញ។ វន វ៉េត តើតាមគំនិតរបស់លោក វន វ៉េត នោះ តើគាត់សមនឹងត្រូវបានគេកម្ទេចដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នេះជាសេចក្តីសន្និដ្ឋានរបស់ខ្ញុំហើយ។ ដែលខ្ញុំសូមគេចវាងមិនឆ្លើយ នៅស្ងៀម។

**ស៖** ខ្ញុំនឹងសួរវិធីផ្សេងវិញ តើគេមានធ្វើទារុណកម្ម វន វ៉េត ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន គេធ្វើ។

[១៤:២៧:៤៥]

**ស៖** គោលបំណង-- បាទ ខ្ញុំសូមកែសំណួរ តើគេមានគោលបំណងអ្វីដែលគេចាប់ វន វ៉េត ធ្វើទារុណកម្មនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បើនិយាយពីគោលបំណង ខ្ញុំមិនឆ្លើយទេ ព្រោះវាចូលក្នុងសេចក្តីសន្និដ្ឋាន។

**ស៖** ខ្ញុំបញ្ជាក់លោកសិន ដើម្បីឲ្យខ្ញុំយល់។ លោកចង់លើកឡើងថា ជាប្រធានស-២១ មិនដឹងថាហេតុអ្វីគ្រូរបស់លោកត្រូវបានគេធ្វើទារុណកម្មដែលគាត់ធ្លាប់ជាគ្រូរបស់លោក ហើយចោទលោកថាជាឃាតកនោះ។ នេះជាចម្លើយលោកឆ្លើយអ៊ីចឹង មែនដែរឬទេ?

**ឆ៖** ឥឡូវនេះ ខ្ញុំសូមនិយាយថា នៅពេលដែលខ្ញុំចូលទៅសូមទោសគាត់ បងវន ចង្អុលមុខខ្ញុំ “អាឃាតករ!” ខ្ញុំជឿថា សម្តីនេះមិនមែនគាត់សំដៅខ្ញុំទេ។ គាត់សំដៅទៅដល់អីលើណោះ។ ខ្ញុំនៅតែខិនលំទោនទៅរកគាត់--

**ស៖** លោកសាក្សី តើលោកដឹងហេតុអ្វីបានជាគេធ្វើទារុណកម្មគាត់ដែរឬទេ ឬក៏លោកមិនដឹងទេលោក? ឬក៏លោកមិនចង់ប្រាប់យើងខ្ញុំ។

**ឆ៖** ហេតុអ្វីបានគេធ្វើទារុណកម្ម វន វ៉េត? អ្នកដែលចាប់មកស-២១, ស-២១ មានភារកិច្ច

ស្តួរចម្លើយ។ ដូច្នេះគេស្ទាបស្ទង់មើលសព្វគ្រប់ បើដល់ពេលថាល្មមគេសួរហើយ គេវ៉ៃហើយៗ។ នេះវាជារឿងរ៉ាវរបស់ស-២១ និងមន្ទីរនគរបាលផ្សេងទៀត។

[១៤:៣០:០២]

**ស៖** សូមអរគុណ។ ការពិតទៅ វន វ៉េន សមនឹងទទួលទារុណកម្ម ដែលគាត់ទទួលក្រោមការត្រួតពិនិត្យ និងការកាន់កាប់របស់លោក តើមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន សំណួរនេះមានលក្ខណៈ ទូទៅពេកៗ។ បើនិយាយពីក្នុងចលនាសួរចម្លើយ គេរិះរកវិធីស្លូតមិនបានយូរពេលវេលាហើយ ខាងលើតឿនគេ--

**ស៖** ខ្ញុំកាត់សម្តីលោកត្រង់នេះ តើ វន វ៉េត នោះសមនឹងទទួលទារុណកម្មដែរឬទេ? សម ឬមិនសម? ឬក៏គាត់ទទួលទារុណកម្ម គ្រាន់តែធ្វើទារុណកម្មគាត់ដោយសារតែស-២១ ជាកន្លែងធ្វើទារុណកម្ម។ តើលោកៗ វន វ៉េន សមនឹងទទួលទារុណកម្មដែរឬទេ? សម ឬមិនសម? ឬក៏គេគ្រាន់តែធ្វើទារុណកម្មតែប៉ុណ្ណោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៤:៣១:១៣]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន សាក្សីបានឆ្លើយហើយ ខ្ញុំមិនចង់កាត់សម្តីទេ។ ខ្ញុំគិតថាវាមិនសមដែលសុំឲ្យសាក្សីឆ្លើយសំណួរថា សម ឬក៏មិនសម ដោយសារសំណួរនោះមានលក្ខណៈស្មុគស្មាញ។ មេធាវីបានធ្វើអ៊ីចឹង សាក្សីឆ្លើយ ហើយមេធាវីបានកាត់សម្តី ហើយមេធាវីបានសួរសំណួរដឹកមុខមួយចំនួនដើម្បីទាមទារយកចម្លើយ។ ហេតុដូច្នេះហើយ គឺខ្ញុំសូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យសាក្សីនោះផ្តល់ចម្លើយតាមឆន្ទៈសេរីភាពរបស់គាត់ ជាជាងការបង្ខំឲ្យគាត់និយាយ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំរៀបចំសំណួររបស់ខ្ញុំឡើងវិញ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តើ វន វ៉េត ជាប់នៅស-២១ នោះរយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំភ្លេចអស់ហើយ។

**ស៖** តើគាត់ជាប់នៅទីនោះមួយសប្តាហ៍ មួយខែ បីបួនខែ ពីរបីខែ ឬប៉ុន្មាន?

**ឆ៖** បើតាមខ្ញុំចាំ វន វ៉ន មកដល់ស-២១ នៅថ្ងៃ២ ខែវិច្ឆិកា ១៩៧៨។

**ស៖** តើនៅពេលណាដែលលោកឲ្យគេកម្ទេចគាត់ចោល?

**ឆ៖** ខ្ញុំភ្លេចហើយ។

**ស៖** តើលោក វន វ៉េត នោះសរសេរចម្លើយសារភាពប៉ុន្មានដងដែរ មុនពេលដែលលោកគិតថា គាត់បានសរសេរចម្លើយសារភាពនោះត្រឹមត្រូវដែលលោករំពឹងទុកនោះ?

[១៤:៣៣:១៦]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់មានរំពឹងទុកថា ឲ្យ វន វ៉េត សរសេរល្បិចទេ។ ដូច្នេះ ខ្ញុំសូមលប់ពាក្យ “តាមការដែលលោករំពឹងទុក” ហ្នឹងចោល។

**ស៖** តើលោកបានពិនិត្យចម្លើយសារភាពរបស់គាត់នោះ វិញដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមុននឹងជូនទៅបង នួន ខ្ញុំបានពិនិត្យ ខ្ញុំបានមើល ខ្ញុំបានអាន។

**ស៖** ហើយគេមានសុំឲ្យលោកៗទៅ សុំឲ្យ វន វ៉េត នោះឆ្លើយបញ្ជាក់ ហើយ ឬក៏ឆ្លើយសារភាពឡើងវិញដែរឬទេ?

**ឆ៖** បើតាមខ្ញុំចាំ ដូចជាមានឆ្លើយម្តងទៀត ឬក៏តែម្តងគត់ក៏មិនដឹង ខ្ញុំភ្លេច។

**ស៖** តាមអ្វីដែលលោកចាំ ថាតើលោក វន វ៉េត នោះសារភាពថាគាត់ធ្វើអ្វីខុសដែរ?

**ឆ៖** តាមខ្ញុំចាំ បងវន គាត់ថា គាត់ សេ.អ៊ី.អា។

[១៤:៣៥:០៥]

**ស៖** គាត់ជាគ្រូរបស់លោក លោកបានចំណាយពេលជាច្រើនដែលជាមួយនឹងគាត់ ហើយ លោកបានសុំឲ្យមានការអត់ទោសដល់គាត់ តាមដែលលោកចាំ។ តើលោក វន វ៉េត ជាសមាជិក សេ.អ៊ី.អា ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនឆ្លើយថា គាត់ជា សេ.អ៊ី.អា ឬមិន សេ.អ៊ី.អា ទេ ក៏ប៉ុន្តែ វន វ៉េត មិនដែលបង្រៀនខ្ញុំអំពីវិជ្ជា សេ.អ៊ី.អា ទេ។

**ស៖** ដូច្នេះ លោក-- បាទ ខ្ញុំសូមរៀបចំសំណួរឡើងវិញ។ លោកកំពុងតែប្រាប់យើងខ្ញុំថា នៅពេលនោះ ពេលដែលលោកឲ្យគេសម្លាប់គាត់ចោល លោកជឿលើចម្លើយសារភាពរបស់គាត់ ថាគាត់ជាសមាជិក សេ.អ៊ី.អា តើមែនដែរឬទេ?

**ឆ៖** ខ្ញុំបានជម្រាបរួចមកហើយថា វន វ៉េត សេ.អ៊ី.អា ឬសេ.អ៊ី.អា មិនដឹងទេ។ ក៏ប៉ុន្តែ ខ្ញុំមិនដែលត្រូវបាន វន វ៉េត បង្រៀនអំពីវិជ្ជា សេ.អ៊ី.អា។

**ស៖** ប្រសិនបើអ៊ីចឹង ខ្ញុំសូមចោទជាសំណួរទូទៅ។ បុគ្គលនានាដែលចូលមក ស-២១ ហើយដែលឆ្លើយថា ភ្នាក់ងារ សេ.អ៊ី.អា, កា.ហ្សេ.បេ និងជាភ្នាក់ងារយួន តើលោកជឿជាក់ថា ពួកគេទាំងអស់នោះ ជាភ្នាក់ងារ សេ.អ៊ី.អា, កា.ហ្សេ.បេ ឬក៏ភ្នាក់ងារយួន តើមែនឬទេ?

[១៤:៣៦:៥៦]

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយទេ។ សំណួរនេះ សួររួចហើយ។

**លោក ម៉ែខល កាណាវាស៖**

លោកប្រធាន សំណួរហ្នឹង កាលពីមុន យើងទាក់ទងទៅនឹង វន វ៉េត ប៉ុន្តែឥឡូវនេះ យើងសួរជាទូទៅ។ ដូច្នេះ យើងខ្ញុំគ្រាន់តែចង់ដឹង ថាតើសាក្សីគាត់ជឿជាក់ទៅលើចម្លើយសារភាពនោះ ឬក៏អត់? ដូច្នេះហើយ យើងចង់ដឹងថា តើអ្នកដែលគេសម្លាប់ហ្នឹង សម្លាប់ដោយសារតែមានលេស ឬក៏ដោយសារតែមានអ្វីប៉ុណ្ណោះ។ ការពិត នេះគឺជាសំណួរដែលយើងចង់បាន។ ប៉ុន្តែបើសិនលោកប្រធានថាចង់ឲ្យខ្ញុំបន្តទៅមុខ ខ្ញុំនឹងបន្តទៅមុខទៀត។

**ប្រធានអង្គជំនុំ៖**

អញ្ជើញទៅមុខ សំណួរនេះសួររួចហើយ ថាសំណួរច្រំដែល។

[១៤:៣៧:៥២]

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន ខ្ញុំគិតថា ឥឡូវនេះ ដល់ពេលយើងឈប់សម្រាកហើយ ហើយក៏វាដល់ពេលដែលខ្ញុំត្រូវបានបញ្ចប់ផ្នែកនេះ។ ដោយខ្ញុំគិតថាយើងគួរតែសម្រាកនៅពេលនេះ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ អរគុណលោកមេធាវី អរគុណសាក្សី។ ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះទៅ រហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំឃាំងអញ្ជើញសាក្សីទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី ហើយឲ្យអញ្ជើញគាត់

មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៨ នាទី ដល់ម៉ោង ១៤:៥៨ នាទី)*

[១៤:៥៨:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះបន្ត។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណ លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព និងសួស្តីលោកសាក្សី។

យើងអាចមើលឯកសារ D-- គឺឯកសារមួយដែលនិយាយ អំពីកំណត់ហេតុនៃការសួរចម្លើយរបស់លោក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨។ ហើយលោកប្រហែលជាអាចពិនិត្យមើលឯកសារនេះបន្តិចទៅ។

ជាបឋម ខ្ញុំសូមឲ្យលោកចាប់អារម្មណ៍ ខ្មែរ ERN002490 --

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន! សូមឲ្យមេធាវីលោក អៀង សារី ជួយបញ្ជាក់លេខ ERN ឡើងវិញ។

[១៥:០០:២៥]

**ប្រធានអង្គជំនុំ៖**

លោកៗ មេធាវីបញ្ជាក់លេខ ERN ឡើងវិញ ទាំងឯកសារជាភាសាខ្មែរ អ្នកបកប្រែបកអត់ទាន់ទេ។ ចាប់ផ្តើមពី ERN ជាភាសាខ្មែរមក។

**សួរដោយលោក ម៉ៃខល ការណាវ៉ាស៖**

**ស៖** ឯកសារលេខ 00242920, ឯកសារ 00242920 អង់គ្លេសគឺ00242931, បារាំងគឺ00242942, ឯកសារលេខ D120។ ប្រសិនបើលោកសាក្សីមើលឯកសារហ្នឹង តើរកឃើញនៅលោក? ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ប្រសិនបើលោករកតែទំព័រដែលយើងខ្ញុំគ្រោងនឹងអានទៅបានហើយ។

[១៥:០១:២៤]

នៅក្នុងចម្លើយមួយដែលលោកបានឆ្លើយ លោកបាននិយាយថា "ខ្ញុំមិនមានព័ត៌មានទាក់ទងទៅនឹងអង្គការចាត់តាំងរបស់ក្រសួងនេះទេ។ ខ្ញុំបានភ្លេចចំណុចលម្អិតរបស់វា ហើយខ្ញុំមិនបានចាប់អារម្មណ៍នឹងអង្គការចាត់តាំងរបស់ក្រសួងនេះ ឬក្រសួងផ្សេងទៀតនោះទេ។ ខ្ញុំចាំថានៅឆ្នាំ១៩៧៨ ខ្ញុំបានជួយក្មួយរបស់ ប៉ុល ពត ឈ្មោះ សួរ ហុង ដែលជាអ្នកគ្រប់គ្រងបុគ្គលិកនៅក្រសួងការបរទេស ហើយប្រហែលជាអនុរបស់ អៀង សារី"។ តើលោករកឃើញកន្លែងខ្ញុំអាននេះហើយឬនៅលោក?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំរកឃើញហើយ។

**ស៖** នៅខាងដើមហ្នឹងបន្តិច លោកបាននិយាយអំពីគោលការណ៍នៃទម្លាប់ការងារ។ លោកបាននិយាយថា ប៉ុន្តែខ្ញុំអាចអះអាងថា តាមគោលការណ៍នៃទម្លាប់ការងារ មុនមានការចាប់ខ្លួននៅក្រសួងការបរទេស សេចក្តីសម្រេចពី អៀង សារី ជាការចាំបាច់។

[១៥:០២:៥១]

"មានករណីលើកលែងតែមួយគត់ ដែលខ្ញុំបាននិយាយរួចហើយ គឺករណីរបស់ ចៅ សេង ដែលត្រូវបានចាប់ខ្លួនក្រោមឈ្មោះមួយទៀត ដោយ អៀង សារី មិនដឹងទេ"។ តើលោកឃើញចំណុចហ្នឹងហើយឬនៅ បាទ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំឃើញហើយ។

[១៥:០៣:២១]

**ស៖** ខ្ញុំគិតថា ខ្ញុំយល់ នៅពេលដែលលោកនិយាយថា តាមគោលការណ៍នៃទម្លាប់អនុវត្តនោះខ្ញុំយល់ តែអ្វីដែលខ្ញុំចង់ដឹងនោះ គឺតាមអង្គហេតុ តាមហេតុការណ៍ជាក់ស្តែង តើលោកដឹងថាតើការចាប់ខ្លួនបានធ្វើឡើងនៅក្រសួងការបរទេសដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន តើលោកសួរការជាប់ខ្លួនជាទូទៅ ឬក៏ការចាប់ខ្លួន ចៅ សេង?

**ស៖** គឺការចាប់ខ្លួនទូទៅ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បុគ្គលិកនៅក្រសួងការបរទេសចាប់ខ្លួនចូល ស-២១ ច្រើនដែរ។

[១៥:០៥:២៣]

**ស៖** មានច្រើន ហើយលោកមិនធ្លាប់បាននិយាយជាមួយនឹងនីវសារទាំងឡាយដែលមកពីក្រសួងការបរទេសនោះទេ? មែនដែរឬទេ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ។

**ស៖** សូមអរគុណ។ ហើយតើលោកបានដឹងដែរឬទេនៅក្នុងសារនោះថា តើមានសរសេរអ្វីខ្លះដែលគេផ្ញើជូនមកលោកហ្នឹង?

**ឆ៖** ខ្ញុំមិនចាំទេ ក៏ប៉ុន្តែការសម្រេចចាប់ខ្លួននៅក្រសួងការបរទេស មិនមែនសាររបស់ក្រសួងការបរទេសទេ គឺសារចេញពី សុន សេន ហើយបន្ទាប់ក្រោយមកពី នួន ជា។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសនោះទេ មានបុគ្គលដែលសម្រេចថា តើត្រូវចាប់នរណា។ តើមែនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នេះជាគោលការណ៍ បើយើងឆ្លើយគឺឆ្លើយជាគោល-ការណ៍ បើមិនសួរជាគោលការណ៍ សួរជាក់ស្តែង ខ្ញុំអត់ឆ្លើយរួចទេ។ ដូច្នេះ សូមលោកមេធាវីបញ្ជាក់មក សួរខ្ញុំជាគោលការណ៍ ឬក៏សួរជាជាក់ស្តែង?

[១៥:០៦:៣៦]

**ស៖** សូមអរគុណដែលលោកលើកចំណុចហ្នឹង។ អ្វីដែលខ្ញុំចាប់អារម្មណ៍នោះគឺតាមការអនុវត្ត។ តាមដែលខ្ញុំយល់ពីលោកមិនខុសនោះទេ នៅពេលដែលពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងនៅក្រសួងការបរទេសតាមការងារជាក់ស្តែង គឺលោកមិនអាចផ្តល់ជាព័ត៌មានជាក់លាក់ចំពោះបញ្ហាដែលកើតមាននៅក្នុងក្រសួងនោះទេ។ តើមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ការងារទាំងអស់របស់ក្រសួងការបរទេស មានរាប់រយ រាប់ពាន់ រាប់ម៉ឺន រាប់សែន។ សូម្បីតែការនាំមនុស្សមកដល់ស-២១ នេះក៏ខ្ញុំនៅចាំមិនបាន តើអ្នកណានាំ

មក។ នេះជាការអនុវត្តជាក់ស្តែង។

**ស៖** សូមអរគុណ។ នៅពេលដែលលោកនិយាយគោលការណ៍ តើលោកមានបានធ្វើការសន្និដ្ឋានសន្មត នៅក្នុងការទាញការសន្និដ្ឋានដែរឬទេ នៅពេលដែលលោកនិយាយអំពីគោលការណ៍តើលោកមានសន្មតទាញជាការសន្និដ្ឋានដែរឬទេ?

**ឆ៖** ជាទូទៅបញ្ហាជាគោលការណ៍ ខ្ញុំមិនសន្និដ្ឋានទេ គឺឈរនៅលើមាត៌ាសេចក្តីសម្រេចមួយចំនួន ហើយនិងឈរនៅលើការដែលឃើញជាក់ស្តែង។

[១៥:០៨:១៨]

**ស៖** ខ្ញុំសូមសួរលោកអំពីការអនុវត្ត។ លោកបាននិយាយថា តាមទម្លាប់អនុវត្តលោកមិនដឹងថាមានអ្វីកើតឡើងនៅក្រសួងការបរទេសនោះទេ។ នៅពេលដែលលោកមកអង្គុយនៅទីនេះ ថ្ងៃនេះ លោកមិនអាចនិយាយក្នុងកម្រិតជាក់លាក់ណាមួយនោះទេ អំពីទម្លាប់អនុវត្តពាក់ព័ន្ធនឹងការចាប់ខ្លួន។ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** ជាទូទៅការចាប់ខ្លួន ខ្ញុំឃើញជាក់ស្តែងនៅក្នុងសេនាធិការ។ ការសម្រេច គណៈកម្មាធិការសេនាធិការ អ្នកសម្រេច ក៏ប៉ុន្តែឯកសារដែលសម្រេចជាគោលការណ៍ហើយនេះ គឺលេខាសេនាធិការរុញមកឲ្យកងពលគេមកឲ្យរួមចំណែកសម្រេច គេទុកអ្នកណា អីអ្នកណា។ នេះជាបញ្ហាមួយ។ បញ្ហាមួយទៀត ជាគោលការណ៍ដែលឯកសារនៅសល់នេះ ស៊្តីក៏ដោយក៏ សុន សេន គាត់សុំយោបល់ ប៉ុល ពត ផងដែរ។ យ៉ាងអន់ក៏សុំសេចក្តីសម្រេចជាគោលការណ៍ពី ប៉ុល ពត។ នេះជារឿងពិតដែលយើងខ្ញុំសង្កេតឃើញថា ការអនុវត្តគោលការណ៍វាទៅអ៊ីចឹង ជារលូន។

[១៥:០៩:៤៤]

**ស៖** សូមអរគុណ។ ខ្ញុំត្រូវតែសួរឲ្យជាក់លាក់ជាងនេះបន្តិច។ លោកមិនមានភស្តុតាងដែលបង្ហាញថាលោក អៀង សារី បានពិគ្រោះយោបល់លើបញ្ហានៃការចាប់ខ្លួននោះទេ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំគ្មានភស្តុតាងទេ។

**ស៖** តើមានអ្វីមួយដែលលោកអាចចង្អុលបញ្ជាក់ឲ្យបានជាក់លាក់ ហើយបង្ហាញថា លោក អៀង សារី នោះបានទទួលដំណឹងថា អ្នកដែលមកពីស-២១ មុនពេលដែលអ្នកមកពីស-២១ នោះ ទៅដល់ដែរឬទេ?

**ធ៖** បានទទួលដំណឹងអ្វីមួយ មុនពេលដែលអ្នកស-២១ ទៅដល់។ ខ្ញុំមិនចាំ-- អ៎! មិនយល់។ ដំណឹងអី?

**ស៖** ព័ត៌មានដែលបង្ហាញថា គេលើកជាយោបល់ ពិគ្រោះយោបល់ជាមួយនឹងលោក អៀង សារី អំពីការចាប់ខ្លួនជាក់លាក់ណាមួយ?

**ធ៖** ភស្តុតាងគ្មានទេ។

[១៥:១១:៤៩]

**ស៖** នៅពេលដែលលោកបង្ហាញក្នុងចម្លើយរបស់លោក មួយចំនួនថា "មាន" ថាលោក អៀង សារី នោះ ត្រូវបានគេពិគ្រោះយោបល់ ឬក៏គេជូនដំណឹងជាមុន មុនពេលដែលគេចាប់ខ្លួន មុនពេលដែលមនុស្សពីស-២១ ត្រូវចាប់ខ្លួន មានតែករណីលើកលែងមួយតែប៉ុណ្ណោះ។ ដូច្នេះនេះគឺជាការសន្និតរបស់លោក ធ្វើឡើងដោយលោកមែនដែរឬទេ?

**ធ៖** អ្ហឺ! អារឿងបកប្រែតតិបតតុបមែន។

**ស៖** បាទ អញ្ចឹងស្រ័យប្រហែលជាខ្ញុំទេដែលធ្វើឲ្យអ្នកបកប្រែតតិបតតុប។

ខ្ញុំសួររបៀបមួយផ្សេងវិញ។ លោកបានបញ្ជាក់នៅក្នុងចម្លើយរបស់លោកថាលោក អៀង សារី អាចទំនងជាដឹង ឬទំនងគេពិគ្រោះយោបល់ អំពីការចាប់ខ្លួនបុគ្គលចេញពីក្រសួងការបរទេសយកទៅស-២១។ តើនេះជាការសន្និតរបស់លោក ឬក៏យ៉ាងម៉េច?

[១៥:១៣:០៥]

**ធ៖** ជម្រាបប្រសាសន៍លោកប្រធាន នេះជាគោលការណ៍ៗ បើរឿងហ្នឹង អៀង សារី មិនចូលទៅប្រជុំអចិន្ត្រៃយ៍ហ្នឹងទេ គេសម្រេចក្នុងអចិន្ត្រៃយ៍ហ្នឹងទេ ប៉ុល ពត គាត់សម្រេច ក៏គង់តែគាត់ឲ្យយោបល់មក អៀង សារី ដែរ ប្រសិនបើ អៀង សារី នៅក្នុងស្រុក នៅក្នុងមន្ទីរមជ្ឈិម។ សូម្បីតែប្រធានកងពលម៉េច លេខាសេនាធិការត្រូវសុំយោបល់ឲ្យខាងកងពលគេរួមចំណែកសម្រេច។ នេះជាគោលការណ៍ ហើយភស្តុតាង គឺវាអ៊ីចឹង ហើយភស្តុតាងមួយទៀត ដែលផ្ទុយ ខ្ញុំមានតែភស្តុតាងផ្ទុយទេ គឺរឿងសម្រេចចាប់ ចៅ សេង ពេលនោះ អៀង សារី គាត់អត់នៅ។

[១៥:១៣:៤៨]

**ស៖** តើលោកអាចបង្ហាញឯកសារជាក់លាក់ណាមួយឲ្យខ្ញុំឃើញដែរឬទេ? ដែលឯកសារនោះជាមូលដ្ឋានសំអាងលើអ្វីដែលលោកនិយាយប្រាប់យើង នៅពេលនេះថាវាជាគោលការណ៍ និងវាជា

ទម្លាប់អនុវត្តអ៊ីចឹង?

**ឆ៖** ឯកសារដែលនៅសល់ ដំបូងយើងមើលឯកសារ ឡុង ម៉ុយ ហៅ ជួន ដែលខ្ញុំសរសេរទៅហើយ សុន សេន គាត់សរសេរទៅសុំយោបល់ ប៉ុល ពត។ ឯកសារ ឡុង ម៉ុយ ហៅ ជួន នេះ លេខ D93/III មានចំណារខ្ញុំ មានចំណារ សុន សេន មានចំណារ ប៉ុល ពត នៅក្នុងនុ៎ង។ ដូច្នេះ រឿងអីក៏ដោយគឺ សុន សេន គាត់សរសេរទៅសុំសេចក្តីសម្រេចអំពី ប៉ុល ពត។ ឯកសារ E3/20 ឯកសារ ហេង ពេជ។ នេះ សុទ្ធតែ សុន សេន សរសេរទៅសុំសេចក្តីសម្រេចពី ប៉ុល ពត រាយការណ៍ផ្ទាល់ទៅប៉ុល ពត ទៀត ឯកសារ E3/20 នេះ។ ឯកសារ E3/86 សុន សេន គាត់សរសេរទៅសុំសេចក្តីសម្រេចរបស់ នួន ជា ផ្ទាល់ទៀត។

[១៥:១៥:២០]

**ស៖** យើងខ្ញុំកុំអាលទាន់គិតពីឯកសារហ្នឹង គឺលោកលើកឯកសារមួយៗម្តង បើសិនជាគាត់លើកឧទាហរណ៍ សូមឲ្យលោកសាក្សីលើកមួយៗម្តង។

**លោក វីល្លៀម ស្មីត៖**

ខ្ញុំមិនមានការជំទាស់នោះទេ ក៏ប៉ុន្តែមេធាវីការពារក្តីបានឲ្យសាក្សីបញ្ជាក់ភស្តុតាងឯកសារណាមួយដែលបង្ហាញអំពីទម្លាប់ការងារ និងទម្លាប់ជាក់ស្តែង។ ហើយមេធាវីបានចាប់ផ្តើមអ៊ីចឹង ហើយបន្ទាប់មកបញ្ឈប់ទៅលើការរៀបរាប់ឯកសារដែលបង្ហាញអំពីទម្លាប់ការងារជាក់ស្តែង និងទម្លាប់អនុវត្ត។

ខ្ញុំមិនជំទាស់ទេ បើសិនជាមេធាវីការពារក្តីបញ្ជាក់ឲ្យបានច្បាស់លាស់។

**លោក ម៉ៃខល កាណាវាស៖**

វាឃើញថា សហព្រះរាជអាជ្ញាហាក់ដូចជាមានការមិនអត់ធ្មត់ទៅលើអ្វីដែលគេបានលើកឡើង។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំនឹងលើកមួយៗ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំសូមបញ្ជាក់ថា អ្វីដែលលោករៀបរាប់នោះ គឺបង្ហាញថា សុន សេន បានបញ្ជូនឯកសារនេះទៅ ប៉ុល ពត។ ដូច្នេះ តើលោកបញ្ជាក់ទេ ឯកសារហ្នឹង? សូមបញ្ជាក់ឲ្យយើងឃើញមើល ថាតើចំណុចណាដែលបញ្ជាក់ថា សុន សេន បញ្ជូនទៅ ប៉ុល ពត បន្ទាប់មកមានការបញ្ជូនទៅលោក អៀង សារ ហើយបញ្ជូនត្រឡប់មកវិញដើម្បីបញ្ជូនចូលទៅលោក ឲ្យលោកមានការសម្លាប់ចោលអ្នកទាំងអស់នោះ។ តើលោកមានចំណុចណាមួយដែលសរសេរបញ្ជាក់អ៊ីចឹងដែរឬទេ នៅក្នុងឯកសារ?

[១៥:១៦:៥៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ ដោយសារមានការជំទាស់តវ៉ាពីភាគីម្ខាងទៀត គឺតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សំណួរនេះហាក់ដូចជាមានការភ័ន្តច្រឡំ។ សាក្សីបានបង្ហាញអំពីទម្លាប់អនុវត្ត និងទម្លាប់ការងារនៅតាមក្រសួងនានា មិនមែនជាក់លាក់ទៅលើតែក្រសួងការបរទេសនោះទេ។ ដូច្នេះ សំណួររបស់មេធាវីការពារក្តីហាក់ដូចជាធ្វើឲ្យយើងយល់ច្រឡំ។

[១៥:១៧:២៥]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំមិនដឹងថាតើខ្ញុំត្រូវធ្វើយ៉ាងម៉េចជាមួយនឹងសហព្រះរាជអាជ្ញានោះទេ។ សំណួររបស់ខ្ញុំសួរមុននោះ គឺពាក់ព័ន្ធទៅនឹងលោក អៀង សារី។ ខ្ញុំបានលើកឡើងយ៉ាងជាក់លាក់ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាស្កាត់សម្តីដោយចេតនា គ្មានហេតុផល។ ដូច្នេះនៅពេលនេះកាត់សម្តីខ្ញុំម្តងទៀតថា ខ្ញុំសួរធ្វើឲ្យមានការយល់ច្រឡំ។ យើងដឹងហើយថា ខ្ញុំសួរ ថាតើមានឯកសារណាមួយបង្ហាញថាគេពិគ្រោះយោបល់ជាមួយនឹង អៀង សារី ដែរឬទេ? ហើយប្រសិនបើគាត់អាច មិនអាចរកឃើញឯកសារណាមួយបង្ហាញអ៊ីចឹងទេ គឺគាត់អាចបង្ហាញថា ឯកសារណាមួយផ្សេងទៀតអាចបង្ហាញថា គេបានពិគ្រោះយោបល់ជាមួយនឹងលោក អៀង សារី ហើយឯកសារនោះបង្ហាញអំពីទម្លាប់ការងារ និងទម្លាប់ការអនុវត្តជាក់ស្តែងផងដែរ។

[១៥:១៨:១៤]

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់តំណាងសហព្រះរាជអាជ្ញាត្រឹមត្រូវ។ មេធាវីកែសម្រួលនូវពាក្យសំណួរ សួរដេញដោលសាក្សីឲ្យជាក់ច្បាស់ចៀសវាងសាក្សីមានការភ័ន្តច្រឡំរវាងឯកសារទូទៅ ហើយនិងឯកសារជាក់លាក់ ដែលមានកាចង្អុលបង្ហាញទៅលោក អៀង សារី។ អង្គជំនុំជម្រះទំនង ស្តាប់យល់គឺថានៅតែមានបញ្ហា ក្រែងលោកវាឆ្លងកាត់ការបកប្រែ គឺនាំឲ្យសំណួរដែលមិនជាក់ច្បាស់ទេនាំឲ្យការឆ្លើយតបជាការ

លំបាក ហើយមានទាំងការជំទាស់ផង។ អ៊ីចឹងសូមឲ្យរៀបចំនូវសំណួរឡើងវិញឲ្យជាក់ច្បាស់ ចៀសវាងមានការភ័ន្តច្រឡំរវាងឯកសារទូទៅ ហើយនិងឯកសារជាក់ច្បាស់ដែលមានចំណារ អៀង សារី។

[១៥:១៩:០៥]

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ឯកសារដែលលោកលើកឡើងយកមកជាឧទាហរណ៍ ថាតើឯកសារនោះមានចំណាររចេញពីលោក អៀង សារី ដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ឯកសារដែលខ្ញុំលើកអម្បាញ់មិញបីនេះ ចង់បញ្ជាក់ថា សេចក្តីសម្រេច សុន សេន ស្នើសុំយោបល់ទៅដល់ ប៉ុល ពត នោះ ស្របតាមសំណួរពេលនោះ របស់មេធាវីដែលខ្ញុំស្តាប់បាន។ ឥឡូវនេះនិយាយដោយឡែកតែ អៀង សារី។ ឯកសារដែលទាក់ទងនឹង អៀង សារី គឺទាក់ទងមនុស្សនៅក្នុងអង្គភាពគាត់។ តែឲ្យរកចំណារ អៀង សារី គ្មានទេ។ ឯកសារដែលទាក់ទងនឹងមនុស្សនៅក្នុងអង្គភាពគាត់ គឺឯកសារ ហេង ពេជ ហៅ ឆន។ គឺឯកសារលេខ E3/20។

[១៥:២០:២០]

**ស៖** លោកសាក្សី ខ្ញុំសូមត្រឡប់ទៅសំណួររបស់ខ្ញុំវិញ។ លោកនិយាយអំពីគោលការណ៍។ ខ្ញុំសួរអំពីទម្លាប់ការងារអនុវត្តជាក់ស្តែង។ តើមានឯកសារជាក់លាក់ណាមួយបង្ហាញថា នៅក្រសួងការបរទេសគេមានអនុវត្តតាមគោលការណ៍នោះ ហើយគេយកគោលការណ៍មកអនុវត្តជាក់ស្តែងដែរឬទេ? តើលោកមានឯកសារបង្ហាញអ៊ីចឹងដែរឬទេ? ប្រសិនជាអត់ទេ ខ្ញុំបន្តសួរទៅមុខទៀត។

**ឆ៖** ឯកសារវាមាន ប៉ុន្តែវាមាននៅតាមរូបភាពផ្សេងទៅវិញ។ ការដែលសម្រេចចាប់ ថៅ សេង, អៀង សារី អត់ដឹងទេ។ សុន សេន តេមកខ្ញុំ ឲ្យប្រែឈ្មោះ ថៅ សេង ទៅជា ចិន សួន។ បើអ្នកណាមកសួរកុំប្រាប់។ ហើយឯកសារភស្តុតាង គឺនៅក្នុងបញ្ជីចំណូលមនុស្សដែលចូលមកហ្នឹង ទៅមើលចុះ។ ឈ្មោះ ថៅ សេង គ្មានទេ មានតែឈ្មោះ ចិន សួន។

**ស៖** តើលោកអាចចង្អុលបញ្ជាក់នៅក្នុងឯកសារណាមួយដែលក្នុងនោះបង្ហាញថា សុន សេន ពី សុន សេន ឬក៏ពីបុគ្គលណាមួយបញ្ជូនទៅដល់លោក អៀង សារី សុំការអនុញ្ញាតចាប់បុគ្គលិកពីក្រសួងការបរទេសមកស-២១ ដែរឬទេ?

[១៥:២១:៥៨]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បើសិនជាយើងមានសុទិដ្ឋិនិយមទាំងអស់គ្នាក្នុងការស្វែងរកការពិត យើងអត់និយាយដើម្បីសង្កត់គ្នាណ៎ា និយាយដើម្បីសុទិដ្ឋិនិយម ដើម្បីស្វែងរកការពិត សូមយើងទាំងអស់គ្នាទៅមើលឯកសារ ហេង ពេជ ហៅ ឆន។ ឯកសារនេះ សុន សេន រាយការណ៍ទៅ ប៉ុល ពត អំពីបុគ្គលម្នាក់។ ខ្ញុំសូមមិនបញ្ចេញឈ្មោះទេ ពេលនេះ។ ច្បាស់លាស់ហើយ ដើម្បីឲ្យ--

**ស៖** ខ្ញុំចង់កាត់សម្ដីសាក្សីត្រង់ចំណុចនេះ។ ខ្ញុំសួរសំណួរជាក់លាក់ ដូចដែលខ្ញុំកត់សម្គាល់មុនអ៊ីចឹង។ យើងមិនមែននិយាយអំពីស-២១ ដែលសាក្សីត្រូវតែកំណត់ការណែនាំការជាក់លាក់នោះទេ។ ខ្ញុំសូមឲ្យលោកបង្ហាញឯកសារជាក់លាក់ណាមួយដែលផ្ញើចេញពី សុន សេន, ប៉ុល ពត, ឬក៏ នួន ជា ផ្ញើជូនទៅលោក អៀង សារី ជូនដំណឹង និងសុំការអនុញ្ញាតចាប់បុគ្គលិកពីទីនោះ។ តើមានដែរឬទេ?

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំតាំងសំណួរទៅដល់សាក្សី។ ដូច្នេះ គួរតែបង្គាប់ឲ្យសាក្សីឆ្លើយសំណួរ។

[១៥:២៣:១៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយ ពីព្រោះមានសេចក្ដីជំទាស់ពីតំណាងសហព្រះរាជអាជ្ញា។ ចាំឲ្យច្បាស់ថា បើមានការជំទាស់សាក្សីមិនត្រូវឆ្លើយទេ។ សាក្សីមិនត្រូវស្ដាប់បញ្ជារបស់ភាគីទេ គឺស្ដាប់បញ្ជារបស់ប្រធានអង្គជំនុំជម្រះ។

**លោក វីល្លៀម ស្មីត៖**

ខ្ញុំយល់អំពីការតាំងសំណួររបស់គាត់។ ក៏ប៉ុន្តែគាត់ក៏កាត់សម្ដីរបស់សាក្សីផងដែរ។ ការបកប្រែទៅជាភាសាអង់គ្លេសនោះ គឺវាមានការពាក់ព័ន្ធទៅនឹងសំណួរ ហើយក៏បានលើកឡើងអំពីចម្លើយរបស់ ហុង ហើយខ្ញុំដឹងថា សាក្សីគាត់រៀបនឹងឆ្លើយសំណួរពាក់ព័ន្ធទៅនឹងករណី ហុង ក៏ប៉ុន្តែមេធាវីនោះ គាត់កាត់សម្ដីសាក្សី។ ដូច្នេះ ទើបខ្ញុំចង់ឲ្យមេធាវីសួរសំណួរទីពីរ ដើម្បីឲ្យសាក្សីឆ្លើយ។

**លោក ម៉ៃខល កាណាវាស៖**

សំណួររបស់ខ្ញុំអត់មានពាក់ព័ន្ធទៅនឹងឯកសារមួយអម្បាញ់មិញនេះទេ។ ដូច្នេះទើបខ្ញុំប្រតិកម្ម។ ខ្ញុំអាចឲ្យសាក្សីនិយាយអ្វីដែលគាត់ចង់និយាយទៅ។ យើងឃើញហើយថា ចំណុចនេះមានផ្ទុះបញ្ចាំងនៅក្នុងរបាយការណ៍អ្នកចិត្តសាស្ត្រ អ្វីដែលគាត់ឆ្លើយ។ គាត់-- ខ្ញុំៗមានសិទ្ធិក្នុងស្ដាប់ចម្លើយរបស់

សាក្សី។ ដូច្នេះ បើសិនគាត់ឆ្លើយមិនចំ ខ្ញុំមានសិទ្ធិកាត់សម្តីរបស់គាត់។

[១៥:២៤:២៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

សំណួរពីរចុងក្រោយមេធាវីការពារក្តីបានលើកឡើងយ៉ាងស៊ីសង្វាក់ សួរយ៉ាងស៊ីសង្វាក់ ថាតើមានឯកសារណាបង្ហាញដែរឬទេ? ដូច្នេះសំណួរទាំងអស់នោះ គឺសាក្សីបានផ្តល់ចម្លើយ ផ្តល់សក្ខីកម្ម។ យើងដឹងហើយថា មេធាវីសួរសំណួរបើកចំហ ថាតើមានឯកសារណាដែរឬទេ? ហើយពេលនោះ គឺយើងឃើញថាសាក្សីគាត់លើកឱកាសព្យាយាមពន្យល់ទៅលើសំណួរ។

**លោក ម៉ៃខល កាណាវាស៖**

អ្វីដែលខ្ញុំសួរនោះ គឺពាក់ព័ន្ធទៅនឹងការអនុវត្តជាក់ស្តែង និងគោលការណ៍។ ចំណុចហ្នឹងហើយដែលខ្ញុំសួរអម្បាញ់មិញ។ ដូច្នេះ ខ្ញុំសូមបន្តចូលទៅមុខទៀត។

[១៥:២៥:១៩]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** នៅក្នុងឯកសារដដែល គឺឯកសារ 00242925 អង់គ្លេស 00242936, បារាំង 00242946។ សូមឲ្យលោកមើលឯកសារហ្នឹងលោកសាក្សី ត្រង់ទំព័រដែលលោកនិយាយថា៖ “ក្នុងករណីណាក៏ដោយ ខ្ញុំមិនដែលទទួលការណែនាំបង្គាប់បញ្ជាពី អៀង សារី នោះទេ។ ខ្ញុំមិនដែលទាក់ទងៗជាមួយ អៀង សារី នោះទេ”។ តើពាក្យហ្នឹងជាពាក្យរបស់លោក ឬក៏មិនមែន?

[១៥:២៦:០០]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ពាក្យនេះ ជាពាក្យរបស់ខ្ញុំ។

**ស៖** លោកក៏មិនដែលទទួលចំណារណាមួយពីលោក អៀង សារី តាមរយៈ សុន សេន ឬក៏តាមរយៈ ប៉ុល ពត ឬក៏តាមរយៈ នួន ជា ដែលបញ្ជូនត្រឡប់ទៅលោកឲ្យទាញចម្លើយបន្ថែមទៅលើបុគ្គលដែលជារងគ្រោះទទួលរងទារុណកម្មនោះ។ តើមែនដែរឬទេ?

[១៥:២៦:២៦]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំគ្មានការទាក់ទងជាពាក្យសម្ដី ឬក៏ជាលាយលក្ខណ៍អក្សរអី អំពី អៀង សារី ទេ។ ទោះក្នុងករណីណាក៏ដោយ អ្វីក៏ដោយ គឺអត់។

**ស៖** តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ? តើការសន្ទនាជជែកវែកញែករវាង សុន សេន និង អៀង សារី រវាង នួន ជា និង អៀង សារី អំពីការចាប់ខ្លួនបុគ្គលដែរឬទេ? តើលោកមានធ្លាប់ដឹងដែរឬទេ?

**ឆ៖** ខ្ញុំមិនដឹងទេ ជាក់ស្ដែងគឺអត់មានដឹង។

**ស៖** ចំណុចហ្នឹងហើយ ដែលខ្ញុំចង់សួរបញ្ជាក់ចុងក្រោយ តើក្នុងការអនុវត្តជាក់ស្ដែង តើលោកដឹងអ្វី? ដូច្នេះ តើដឹងថាយ៉ាងម៉េចដែរឬទេ ចំពោះបញ្ហា ប៉ុល ពត ដែលគាត់ជួបជាមួយអ្នកណានោះ? ដូច្នេះ បានន័យថា អង្គការហ្នឹងគឺជា ប៉ុល ពត មែនដែរឬទេ?

**ឆ៖** អង្គការ គឺ ប៉ុល ពត។

**ស៖** តាមអ្វីដែលខ្ញុំយល់ ឬក៏តាមអ្វីដែលលោកឆ្លើយ សុន សេន នោះ ក៏ជាអង្គការដែរមែនដែរឬទេ?

[១៥:២៨:៣៤]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន សុន សេន ពីក្រោយខ្នង ខ្ញុំហៅគាត់អង្គការមែន។ ក៏ប៉ុន្តែគាត់មិនដែលតាំងខ្លួនគាត់ជាអង្គការទេ។ ចំពោះមុខ ខ្ញុំមិនដែលហៅគាត់អង្គការទេ គឺហៅបង។ សរសេរក៏ខ្ញុំមិនដែលហៅគាត់អង្គការដែរ ខ្ញុំហៅបង។

**ស៖** លោកសាក្សី នៅក្នុងបន្ទប់សវនាការនេះ ឬនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត លោកចង់បានន័យថា សុន សេន នោះ តំណាងឲ្យអង្គការ ដែលគាត់បានជួបជាមួយលោក ណែនាំដល់លោក។ ដូច្នេះ តើលោកតំណាងគាត់អ៊ីចឹងដែរឬទេបាទ?

**ឆ៖** គាត់ប្រាប់ខ្ញុំ គាត់ថាគាត់ចុះមកដឹកនាំ ស-២១ នេះ ក្នុងឋានៈតំណាងអង្គការ។ តំណាងមិនមែនគាត់ជាអង្គការទេ គឺតំណាងអង្គការ។

**ស៖** សូមអរគុណ ដែលលោកបានបញ្ជាក់បំភ្លឺត្រង់ចំណុចនេះ។ ចំណុចហ្នឹងហើយ ដែលខ្ញុំចង់ទាញយកសក្ខីកម្មពីលោកនោះ។

ពាក់ព័ន្ធចំណារដែលធ្វើឡើងសរសេរនៅលើចម្លើយសារភាព លោកមិនអាចនិយាយដោយជាក់លាក់នោះទេ ថាចម្លើយសារភាពនោះនឹងបញ្ជូនទៅណា មិនថាមានចំណារនៅលើនោះ ឬក៏គ្មាននោះទេ

គឺលោកមិនដឹងទេ មិនអាចនិយាយអ៊ីចឹងទេ បានន័យថាអ៊ីចឹងទេលោក?

**ឆ៖** ពិបាកយល់ ពិបាកឆ្លើយណាស់។ សូមសួរឲ្យចំបញ្ហាមក។

[១៥:៣០:៤១]

**ស៖** ខ្ញុំនឹងសម្រួលសំណួររបស់ខ្ញុំ។ នៅពេលដែលលោករៀបចំចម្លើយសារភាព លោកបានបញ្ជូនទៅសុន សេន។ តើត្រឹមត្រូវដែរឬទេចំណុចហ្នឹង?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មុនថ្ងៃ១៥ សីហា ១៩៧៧ ខ្ញុំបញ្ជូនចម្លើយសារភាពទាំងអស់ទៅ សុន សេន។ ក្រោយ១៥ សីហា ១៩៧៧ ខ្ញុំបញ្ជូនចម្លើយទាំងអស់ទៅ នួន ជា។

**ស៖** ក្រោយពីចម្លើយសារភាពនោះផ្ញើចេញពីលោកទៅ លោកមិនដឹងថា គេផ្ញើទៅណា ទៅណើនោះទេ ក្រៅពីតែដឹងថាបញ្ជូនទៅ សុន សេន ឬក៏ នួន ជា នោះ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** ហើយលោកក៏មិនដឹងថាគេបានពិភាក្សាគ្នាអ្វីខ្លះដែរផ្អែកទៅតាមចម្លើយសារភាពទាំងអស់នោះ ហើយលោកក៏មិនដឹងថាធ្លាប់មាន ឬក៏មិនធ្លាប់មានការពិភាក្សាគ្នាទៅលើចម្លើយសារភាពនោះទៀត។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ច្បាស់លាស់ ខ្ញុំដឹងម្តងគត់ គឺករណី ឈូក សម្រេចចាប់ ឈូក ហើយបានបន្ទាប់មកទៀតខ្ញុំវិភាគទៅ សន្និដ្ឋានក្នុងការវិភាគចាប់ ដូ ជេត ហៅ ស៊ី គឺគេពិភាក្សាគ្នាទៀត។

[១៥:៣២:៣៤]

**ស៖** ចំណុចនេះ ចំណុចដែលលោកដឹងម្តងនេះ តាមរយៈព័ត៌មានដែលលោកដឹងពី សុន សេន តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន វាពិតជាមេប្រើខ្ញុំឲ្យរៀបចំឯកសារ ដល់គេប្រជុំគ្នាហើយពិតជាមេដំណាលរឿងប្រាប់ខ្ញុំ ពីវិការដ្ឋានដែលប្រព្រឹត្តទៅនៅពេលប្រជុំគ្នានោះ។

**ស៖** មេរបស់លោកហ្នឹង គឺ សុន សេន មែនដែរឬទេ?

**ឆ៖** ត្រូវ។

[១៥:៣៣:១២]

**ស៖** អរគុណ។ ដូច្នេះ ដើម្បីបញ្ជាក់ច្បាស់ទៅលើព័ត៌មាននេះ គឺយើងចាំបាច់ត្រូវឲ្យ សុន សេន មកទីនេះ តើមែនដែរឬទេ?

**ឆ៖** បើសិនជាយើងស្វែងរកការពិតរបៀបនេះណាស់ ខ្ញុំជឿថាវាមានលក្ខណៈអរូបិយ។

**ស៖** ប៉ុន្តែជាចៃដន្យ យើងកំពុងស្វែងរក-- តើលោកមានស្វែងរកយុត្តិធម៌ទេនៅពេលដែលលោកនៅមន្ទីរស-២១ ហើយទៅតាមទ្រឹស្តី តើស-២១ ហ្នឹង គឺមានគោលដៅដើម្បីស្វែងរកការពិតដែរឬអត់?

**ឆ៖** បញ្ហាអស់នេះ វាជាបញ្ហាដែលមនុស្សជំនាន់នេះ ហើយនិងជំនាន់ក្រោយគេវិភាគទៅ។ យើងមិនវាយតម្លៃខ្លួនឯងទេ។ ហើយតុលាការនេះទាំងមូលវិភាគ និងសម្រេច។

[១៥:៣៤:៤២]

**ស៖** ខ្ញុំមិនមែនស្នើឲ្យតុលាការធ្វើការសម្រេចទេ។ ប៉ុន្តែ ខ្ញុំស្នើសុំឲ្យលោកក្នុងនាមជាមេមន្ទីរស-២១ ដែលទទួលការៗ ធ្វើទារុណកម្មតាមរយៈវិធីក្តៅ ត្រជាក់ ឬក៏វិធីអង្កៀមហ្នឹង គឺធ្វើការវាយតម្លៃថាតើទាំងអស់នេះ គឺធ្វើឡើងដើម្បីគោលដៅក្នុងការស្វែងរកការពិត ឬក៏អត់? ថាតើនេះគឺជាដំណើរការឬក៏ជាវិធីសាស្ត្រ ដែលលោកប្រើដើម្បីស្វែងរកការពិតដែរឬអត់?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំតែងតែនិយាយថា ប៉ុន្មានថ្ងៃមុនក៏ខ្ញុំនៅតែនិយាយទៀត។ ខ្ញុំថា ស-២១ ជាអង្គភាពបំពេញភារកិច្ចប្រតិចារកម្ម។

**ស៖** ឥឡូវនេះ ដូចដែលក្នុងនាម-- ដូចដែលលោកបានអង្គុយនៅទីនេះ ហើយបានពិចារណាហើយបាននិយាយថា លោកមិនដឹង ឬក៏លោកមិនមានព័ត៌មានលម្អិតអំពីថាតើមេជាន់ខ្ពស់ ឬក៏ថ្នាក់ដឹកនាំរបស់លោកហ្នឹងធ្វើការយ៉ាងដូចម្តេចហ្នឹង។ តើលោកចង់និយាយបែបនេះឬ?

[១៥:៣៦:២៣]

**ឆ៖** មិនដឹងថាមេធ្វើការយ៉ាងដូចម្តេច? សំណួរនេះទូលាយណាស់ ខ្ញុំសូមមិនឆ្លើយទេ។ មិនដឹងជាឆ្លើយយ៉ាងម៉េចកើត។

**ស៖** សូមលោកពិនិត្យមើលឯកសារ D120 គឺហើយឯកសារខ្មែរគឺ 00242971, 002479-- អង់គ្លេស 00247922 និងភាសាបារាំង 00247943។ សូមលោកពិនិត្យមើលទៅលើឯកសារនេះ នៅក្នុងឯកសារនេះលោកបានបញ្ជាក់ថា៖ "មានការចង្អុលបង្ហាញថា សមមិត្ត-- មានលើកឡើងពីឈ្មោះសមមិត្ត វ៉ាន់ យ៉ាងច្បាស់ ប៉ុន្តែខ្លះទៀតអត់មានទេ ប្រហែលជាចម្លើយសារភាពទាំងអស់របស់មនុស្សមកពីក្រសួងការបរទេសមិនត្រូវបានផ្ញើទាំងអស់ទៅ អៀង សារី នោះទេ"។ បន្ទាប់មកលោកបានបន្តទៀតថា៖ "តាមពិតខ្ញុំមិនដឹងពីការងារលម្អិតទេ ដោយសារខ្ញុំមិនដឹងច្បាស់ពីរបៀបធ្វើការងារ

របស់ថ្នាក់លើ រវាងពួកគាត់នោះទេ។ វាអាចថានៅពេល អៀង សារី អវត្តមាន គេផ្ញើចម្លើយសារភាពទៅ ប៉ង់ ប៉ុន្តែនេះគ្រាន់តែជាការស្មានរបស់ខ្ញុំតែប៉ុណ្ណោះ”។ តើលោកមើលឃើញដែរឬទេ នូវពាក្យដែលថា “មិនអាច”, “អាច” ហើយនិងថា ពាក្យថា “ជាការស្មាន” ហើយនិងពាក្យថា “អាច”, “អាចថា” តើលោកឃើញពាក្យនេះដែរឬទេ?

[១៥:៣៨:២០]

**ឆ៖** ខ្ញុំឃើញ ត្រឹមត្រូវហើយ គឺខ្ញុំឃើញ។

**ស៖** នៅពេលដែលលោកនិយាយអំពីការពិត តើពាក្យទាំងអស់នេះមានលក្ខណៈបែបណាដែរ? នៅពេលដែលលោកនិយាយពាក្យបែបនេះ តើលោកនិយាយពីការពិតដែរឬអត់?

**ឆ៖** “អាច” ពាក្យ “អាច” មួយម៉ាត់ វាអាចពិត ហើយក៏វាអាចមិនពិត គឺជាសេចក្តីសន្និដ្ឋាន។

**ស៖** តើពាក្យថា“ការស្មាន” ហ្នឹងវាមានន័យយ៉ាងដូចម្តេច? ព្រោះលោកប្រើពាក្យនេះញឹកញាប់គួរសម។ ព្រោះពាក្យនេះវាហាក់ដូចជាមិនចាំបាច់ ឬក៏មិនសំខាន់ ដើម្បីឲ្យលោក-- តើលោកយល់ថាពាក្យ “ការស្មាន” ហ្នឹងវាមានន័យដូចម្តេចដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបនឹងសំណួរនេះ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៥:៣៩:២៤]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំជំទាស់ទៅលើសំណួរបែបនេះ ព្រោះសំណួរនេះវាមានផ្ទុកបន្ថែមនូវការសន្មតដែលថា សាក្សីព្យាយាមមិនឆ្លើយចៀសវាងមិនឆ្លើយសំណួរដោយផ្ទាល់។ ហើយការសន្មតបែបនេះមិនអាចធ្វើឡើងបានឡើយ។ ដូច្នេះ ខ្ញុំគិតថាគាត់គួរតែរៀបចំនូវសំណួរ ហើយនិងសួរសំណួរឲ្យសាមញ្ញ ដើម្បីឲ្យបង្ហាញថា តើហេតុអ្វីបានជាសាក្សីគាត់និយាយបែបនេះ? ដូច្នេះ វាមិនមានមូលដ្ឋានអ្វីឡើយក្នុងការធ្វើបែបនេះ។

**លោក ម៉ៃខល កាណាវាស៖**

នេះជាអ្វីដែលលោកសាក្សីបាននិយាយ លោក លោកចៅក្រម។ ខ្ញុំមិនដឹងថាតើវាបកប្រែទៅជាភាសាខ្មែរយ៉ាងដូចម្តេចទេ? ប៉ុន្តែខ្ញុំសន្មតថាការបកប្រែជាភាសាបារាំងគឺ ដូចគ្នានឹងភាសាអង់គ្លេស។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** វាអាចថានៅពេល អៀង សារី អវត្តមានគេធ្វើចម្លើយសារភាពទៅ ប៉ង់ ប៉ុន្តែនេះគ្រាន់តែជាការស្មានរបស់ខ្ញុំតែប៉ុណ្ណោះ។ តើលោកមិនធ្វើការសន្និដ្ឋានទេឬនៅក្នុងករណីនេះ? តើលោកមិនស្មានទេឬ នៅក្នុងករណីនេះ?

[១៥:៤០:៤៧]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ធម្មតាការស្មាន វាជារឿងស្មាន។ ក៏ប៉ុន្តែបើនិយាយពីងងឹតងងុល វាមិនងងឹតងងុលពេកទេ វាមានមូលដ្ឋានខ្លះ ដែលនាំឲ្យគេស្មានអ៊ីចឹង។

**ស៖** ឥឡូវយើងមើលឯកសារ D121។ ខ្ញុំស្នើសុំឲ្យលោកពិនិត្យមើល ERN ខ្មែរដែលមានលេខ 00244235 ភាសាអង់គ្លេសគឺ 00244242 និងភាសាបារាំងគឺ 00244248។ ហើយសម្រាប់ប្រតិចារឹក នេះគឺជាកិច្ចសម្ភាសន៍ស្តាប់ចម្លើយនៅថ្ងៃ២៨ ខែធ្នូ ឆ្នាំ២០០៨ ហើយនិយាយអំពី ណាត ហើយលោកបាននិយាយថា៖ “ហើយនៅក្នុងករណីនេះ ណាត ត្រូវបានគេផ្ទេរទៅក្រសួងការបរទេស។ ខ្ញុំសន្និដ្ឋានថា ការចាប់នេះត្រូវបានសម្រេចបន្ទាប់ពីការពិភាក្សាជាមួយ អៀង សារី”។ តើលោកឃើញផ្នែកនេះដែរឬទេ ដែលនិយាយថា “ខ្ញុំសន្និដ្ឋានថា”?

[១៥:៤៣:២៩]

តើលោកឃើញដែរឬទេ ដែលលោកនិយាយថា ខ្ញុំគិត សន្និដ្ឋានថា “ខ្ញុំគិតថា ការចាប់ខ្លួនរបស់គាត់គឺចាំបាច់ត្រូវសម្រេច ដែលមានការពិភាក្សាជាមួយ អៀង សារី” គឺឯកសារដែលមានលេខ 00244235 ដែលនិយាយថា៖ “ខ្ញុំគិតថា ការចាប់ខ្លួនរបស់គាត់ គឺចាំបាច់ត្រូវសម្រេចដោយមានការពិភាក្សាជាមួយ អៀង សារី”។ តើលោកឃើញដែរឬទេ?

**ឆ៖** ខ្ញុំឃើញ!

**ស៖** តើលោករក្សាចម្លើយនេះដដែល ឬមួយក៏យ៉ាងណា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំរក្សាចម្លើយនេះ។

**ស៖** ដូច្នេះនៅពេលដែលលោកសន្និដ្ឋាន ឬក៏លោកគិត និយាយថា លោកគិតថា ហ្នឹងតើជាការសន្និដ្ឋាន ឬមួយក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំបានបញ្ជាក់ហើយថា ការសន្និដ្ឋាន វាមិនដែលចេះតែថា ទាំងងងឹតងងុលនោះទេ វាមាន

មូលដ្ឋានរបស់គេសម្រាប់វិភាគ ហើយនិងសន្និដ្ឋាន។

**ស៖** តើវាអាចដែរឬទេ ដែលថាការសន្និតរបស់លោកវាខុស ការស្មានរបស់លោកហ្នឹងវាខុស?

[១៥:៤៤:៥២]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន វាខុសក្នុងករណីមួយពីរ។ តែវាត្រូវជាគោលការណ៍ជារួម។

**ស៖** ដូច្នេះខ្ញុំបញ្ជាក់ឲ្យច្បាស់ នៅពេលដែលលោកធ្វើការសន្និតសមមិត្ត ឌុច ជាទូទៅគឺថាលើកលែងករណីមួយពីរ គឺថាការសន្និត ឬក៏ការស្មានរបស់លោកហ្នឹងគឺត្រឹមត្រូវ។ តើមែនឬទេ?

**ឆ៖** ចម្លើយនេះវិលវល់ចុះឡើងៗនៅតែប៉ុនន៉ុង។ ខ្ញុំសូមមិនឆ្លើយទេ មិនដឹងចេះឆ្លើយយ៉ាងម៉េចកើតទេ។

**ស៖** ខ្ញុំចង់និយាយពីបញ្ហាផ្សេងមួយទៀតដោយសង្ខេប ហើយបញ្ហានេះគឺពាក់ព័ន្ធទៅនឹងកូនក្មេងដែលលោកបានជួប ហើយដែលលោក អៀង សារី បាននិយាយ។ តើលោកចាំដែរឬទេ ដែលនិយាយអំពីព្រឹត្តិការណ៍មួយនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នេះជាបញ្ហាមួយថ្មីទៀត ដែលមិនមែននិយាយអំពីការសារភាព ចម្លើយសារភាព ហើយក៏មិនមែននិយាយអំពីតួអង្គបុគ្គលដែលសិទ្ធិសម្រេចចាប់ដោយមជ្ឈិមបក្សទេ។ និយាយពីកូនក្មេង ខ្ញុំនៅចាំរឿងនេះ។ វាជាបញ្ហាមួយទៀត។ បញ្ចូលបញ្ហានេះទៅនឹងបញ្ហាមុន ខ្ញុំសូមបដិសេធមិនបញ្ចូល មិនបានទេ។

[១៥:៤៦:៥៩]

**ស៖** ខ្ញុំសូមទោសដែលខ្ញុំមិនបានបញ្ជាក់ឲ្យច្បាស់លាស់នៅពេលដែលខ្ញុំផ្លាស់ប្តូរទៅប្រធានបទថ្មីមួយ។ ដូច្នេះ ឥឡូវនេះយើងកំពុងពិភាក្សាពីប្រធានបទថ្មី។ ដូច្នេះតើលោកចង់ពិភាក្សាអំពីបញ្ហានេះឬទេ ឬមួយក៏លោកចង់បដិសេធមិនផ្តល់ភស្តុតាងទៅលើបញ្ហានេះ?

**ឆ៖** ខ្ញុំអត់ចង់បដិសេធទេ កុំហារឡើងខ្ញុំចង់បដិសេធ ខ្ញុំអត់ចង់បដិសេធទេ។ ប៉ុន្តែខ្ញុំគ្រាន់តែចង់និយាយអំពីមូលដ្ឋាននៃបញ្ហា។ ឥឡូវយើងឯកភាពគ្នាហើយលើមូលដ្ឋាននៃបញ្ហា។ ឥឡូវពីរឿងកូនក្មេងខ្ញុំនៅតែរក្សាការពិត--

**ស៖** លោកសាក្សី ដូច្នេះយើងពិភាក្សាអំពីបញ្ហាកូនក្មេងនេះ។ បើតាមខ្ញុំដឹង លោកដឹងអំពីរឿងនេះនៅឆ្នាំ១៩៩០ តើត្រឹមត្រូវដែរទេ?

**ផ៖** ត្រឹមត្រូវ!

**ស៖** ឬក៏យើងនិយាយម្យ៉ាងទៀតបានថា នៅពេលនោះ នៅពេលដែលមានរឿងនោះកើតឡើង លោកអត់ដឹងអំពីបញ្ហានោះទេ?

[១៥:៤៨:២៣]

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន មុននឹងរឿងនេះកើតឡើង ខ្ញុំអត់ដឹងបញ្ហានេះទេ។

**ស៖** ហើយច្បាស់លាស់ តើសុន សេន, នួន ជា, ប៉ង់ ឬក៏បុគ្គលដទៃទៀតនោះ មានជម្រាបលោក ឬក៏ប្រាប់លោកអំពីហេតុការណ៍នេះដែរឬទេ?

**ផ៖** បើអ្នកទាំងអស់នេះប្រាប់ខ្ញុំ ខ្ញុំដឹងបាត់ទៅហើយ មិនមែនចាំដល់ឆ្នាំ១៩៩០។ ខ្ញុំអត់ដឹងទេ គ្មាននរណាប្រាប់ខ្ញុំទេ។

**ស៖** ដូច្នេះ ខ្ញុំគិតថា តើលោក អៀង សារី ជួយកុមារនោះយ៉ាងដូចម្ដេច? ដូច្នេះ លោកអត់មានព័ត៌មានលម្អិតទេ? បានន័យថា លោកមិនដឹងអំពីព័ត៌មានទាំងអស់នេះទេ តើមែនឬទេ?

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់មានដឹងទេ។

**ស៖** លោកក៏អត់ដឹងផងដែរថាតើលោក អៀង សារី ហ្នឹងបានជំទាស់ទៅលើបញ្ហាដែលចេញដោយ ប៉ុល ពត ឬក៏អ្នកដទៃទៀត តើលោកមានដឹងឬទេ?

**ផ៖** ខ្ញុំមិនដឹងទេ។

[១៥:៥០:០០]

**ស៖** ហើយអ្វីដែលលោក តើលោកមានអ្វីផ្ដល់មតិយោបល់ទាក់ទងទៅនឹងកូនក្មេងទាំងអស់នោះ? ដូច្នេះអ្វីដែលលោកផ្ដល់មតិយោបល់ គឺជាការសន្មត ឬក៏ជាការសន្និដ្ឋានរបស់លោក តើមែនឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! អញ្ជើញលោកស្រីមេធាវីតំណាងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**កញ្ញា លី ម៉ាញឿន៖**

លោកប្រធាន ខ្ញុំដឹងថាអ្វីបានលើកឡើងនេះ លោក ខ្ញុំដឹងថាលោកមេធាវី កាណាវាស ប្រហែលជាអស់-- ជិតអស់ពេលហើយ ប៉ុន្តែចៅក្រម ខាតវ៉ាយថ៍ បានបញ្ជាក់នៅព្រឹកនេះថាមិនត្រូវឲ្យមានសំណួរនាំមុខនោះឡើយ។ ដូច្នេះហេតុផលដ៏ល្អគឺកុំឲ្យមានសំណួរបែបនេះ ហើយឥឡូវនេះយើងកំពុងតែ

ស្តាប់លោក កាណាវាស ចោទនូវសំណួរនាំមុខយ៉ាងច្រើន។ ដូច្នេះយើងគួរតែជម្រាបលោក កាណាវាស កុំឱ្យចោទនូវសំណួរនាំមុខ ហើយសុំឱ្យគាត់ហ្នឹងមេត្តាកែសំណួររបស់គាត់ ហើយគួរតែឱ្យសាក្សីជាអ្នកផ្តល់ចម្លើយ កុំឱ្យមេធាវី កាណាវាស ជាអ្នកផ្តល់ព័ត៌មានបែបនេះ។

[១៥:៥១:១០]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោក លោកស្រី លោកសាក្សី ប្រសិនបើលោកមិនដឹងអំពីហេតុការណ៍ ឬក៏អំពីព្រឹត្តិការណ៍នៃកូនក្មេងនេះទេ តើលោកមានតួនាទីអ្វីក្នុងការផ្តល់ព័ត៌មានលម្អិតអំពីការចូលរួមរបស់លោក អៀង សារី? ហើយថាតើលោកមានតួនាទីអ្វីដែលផ្តល់មតិទាក់ទងនឹងការជួយសង្គ្រោះក្មេងរូបនោះ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** នេះជាអារម្មណ៍របស់ខ្ញុំ ថាជាអារម្មណ៍ក៏បាន ថាជាការខ្មាសខ្លួនក៏ថាបានដែរ។ អៀង សារី គាត់ប៉ានទុកក្មេងៗ។ ទុកកូន តូច ខាំឿន ទុកកូនមិត្ត ទាញ ទុកកូនមិត្ត ណាត ឱ្យនៅរស់។ ឯចំណែកខ្ញុំ ខ្ញុំអត់ប៉ានសុំអង្គការបង្កើតមូលដ្ឋានកុមារកំព្រារអីទេ។ ខ្ញុំអាងពិសោធនៅម-១៣។ ដូច្នេះខ្ញុំខ្មាសខ្លួនឯងចំពោះមុខវីរភាពរបស់ អៀង សារី។ នេះខ្ញុំពិតជាមានការខ្មាសអៀនមែន។ ក៏ប៉ុន្តែដល់ក្រោយមក ខ្ញុំឃើញថាក្នុងការប្រតិបត្តិគោលការណ៍មានចន្លោះ។ កូនរបស់ ចេង អន ក៏នៅរស់ បីនាក់បងប្អូន នង ចាន់ផល ក៏នៅរស់ ហើយកូនរបស់ កែ គឹមហួត ក៏នៅរស់។

ដូច្នេះការអនុវត្តគោលការណ៍ចាប់ម៉ែឪ កូនត្រូវតែកម្ទេច ប្រហែលជាអនុវត្តបានរាប់ម៉ឺន រាប់ពាន់ៗ រាប់រយរាប់ពាន់។ ក៏ប៉ន្តែនៅចន្លោះប៉ុណ្ណឹង។ កូន ចេង អន, កូន តូច ខាំឿន, កូន ណាត, កូនទាញ, កូន កែ គឹមហួត ហើយនិងកូន នង ចិន ក្មេងបីនាក់ដែលគេជ្រើសរើសយកទៅចិញ្ចឹម។ ដូច្នេះវាមានការភ្លាត់អីចឹង មិនមែនចន្លោះទេ គឺការភ្លាត់អីចឹង។ អនុវត្តទៅវាភ្លាត់។ វាមិនបានសព្វគ្រប់ទេ គោលការណ៍ដែលអនុវត្តវានៅអីចឹង។ ប៉ុន្តែដោយឡែកកូនក្មេងបីនាក់ដែល អៀង សារី គាត់ថែរក្សា ខ្ញុំខ្មាសខ្លួនឯងចំពោះមុខគាត់ ចំពោះឧត្តមភាពរបស់គាត់ចំពោះខ្ញុំ។ អានេះខ្ញុំពិតជាមានអារម្មណ៍ហ្នឹងមែន។ ហើយខ្ញុំអត់ស្មានទេ ខ្ញុំខ្មាសអីចឹងតែម្តង។

[១៥:៥៤:០០]

**ស៖** លោកមិនមានព័ត៌មានឱ្យជាក់លាក់នោះទេ តើមែនទេ? គឺពាក់ព័ន្ធទៅនឹងលោក អៀង សារី ហើយលោកមិនដឹងថាគាត់ពាក់ព័ន្ធនឹងការចាប់ខ្លួនឪពុកម្តាយរបស់ក្មេងនោះ តើមែនដែរឬទេ?

**ឆ៖** ខ្ញុំលំបាកនិយាយណាស់ ដល់ច្រំដែលៗតែពីរឿងអាចាប់ដឹង ឬមិនដឹងនោះ។ ជាគោលការណ៍គឺគាត់ត្រូវតែដឹង។ មកច្រំដែលៗរឿងហ្នឹង ខ្ញុំសូមមិនឆ្លើយទេ។ ដោយឡែករឿងកូនក្មេងនេះ ខ្ញុំនៅតែរក្សាដដែលថា ខ្ញុំខ្មាស អៀង សារី។

**ស៖** លោកនិយាយថា ជាគោលការណ៍ ឥឡូវនេះខ្ញុំសូមសួរអំពីការអនុវត្តជាក់ស្តែង ពីព្រោះៗលោកត្រូវបានគេចាត់ទុកថាជាមានតួនាទីជាក់លាក់ពិសេសមួយ ព្រោះលោកមានទំនាក់ទំនងជាមួយ នួន ជា, សុន សេន ហើយគេជាអ្នកស្នើសុំឲ្យលោកផ្តល់ ឬក៏ទទួលនូវព័ត៌មានបន្ថែមនៅក្នុងការពិភាក្សាជាមួយនឹង សុន សេន ឬក៏ជាមួយ នួន ជា ជាដើម។ តើពួកគាត់ធ្លាប់និយាយថា អៀង សារី មានចូលរួមនៅក្នុងការចាប់ខ្លួនរបស់-- ចាប់ខ្លួនឪពុកម្តាយរបស់ក្មេងនោះដែរឬទេ?

[១៥:៥៥:៣៧]

**ឆ៖** ខ្ញុំបានបញ្ជាក់ហើយ ជាគោលការណ៍ គឺត្រូវតែមានគាត់ចូលរួម ដោយផ្ទាល់នៅក្នុងពេលប្រជុំហ្នឹង ឬក៏គេប្រាប់ក្រោយ។ លើកលែងតែរឿងមួយ ដែលខ្ញុំដឹងច្បាស់ថា មិនបានគាត់នៅ គឺរឿងចៅ សេង។ ដូច្នេះ រកអាភស្តុតាងសម្រាប់បញ្ជាក់ថា គាត់នៅ ឬមិននៅ អត់មានទេ។ ជាគោលការណ៍វាមាន។ រួចដេញដោល ត្រង់ថាអារឿងគាត់នៅ មិននៅៗ ខ្ញុំអត់ចេះឆ្លើយទេ។ ខ្ញុំឆ្លើយរួចម្តងរួចហើយ។ សុំបដិសេធមិនឆ្លើយសំណួរបែបនេះតទៅទៀតទេ។

**លោក ម៉ៃខល កាណាវាស៖**

*(និយាយមិនបើកមីក្រូហ្វូន)*

**អ្នកបកប្រែ៖**

សូមលោកមេធាវីបើកមីក្រូ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវនេះ យើងបន្តទៅមុខទៀត គឺទៅប្រធានបទថ្មីមួយទៀត គឺថាយើងទុកចោលប្រធានការអនុវត្តទល់នឹងការទ្រឹស្តី គឺឯកសារ E74 ខ្ញុំៗនិយាយអំពីព័ត៌មានលម្អិតដែលថា លោកមិន មាននូវគុណសម្បត្តិគ្រប់គ្រាន់។ លោកមិនមានគុណសម្បត្តិដែលគួរឲ្យជឿជាក់ គឺថាលោកមិនមានគុណសម្បត្តិគ្រប់គ្រាន់ ហើយក្នុងឯកសារនេះ គឺបញ្ជាក់យ៉ាងច្បាស់។ នៅក្នុងកិច្ចពិភាក្សាចុងក្រោយ គឺថ្ងៃ១១ ខែវិច្ឆិកា ឆ្នាំ២០០៩ គឺព្រះរាជអាជ្ញាខ្លួនផ្ទាល់ទាំង បានបញ្ជាក់ថា ខ្ញុំសូមអាននូវចំណុចទាំងអស់នេះ។

[១៥:៥៧:២៤]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំសូមជំទាស់។

**លោក ម៉ៃខល កាណាវាស៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញា ជំទាស់ឲ្យជាក់ច្បាស់ទៅ យ៉ាងម៉េចទៅ? ហើយមេធាវីសុំមេធាវីចងចាំការស្តាប់ការជំទាស់ចប់សព្វគ្រប់ ហើយទុកពេលវេលាឲ្យអ្នកបកប្រែបកប្រែភាសា រួចហើយសឹមលោកនិយាយ។ បើសិនជាលោកនិយាយម្តងពីរនាក់អ៊ីចឹង អ្នកបកប្រែវាមិនដឹងបកប្រែយ៉ាងម៉េចទេ។

[១៥:៥៨:០១]

**លោក វីល្លៀម ស្មីត៖**

ការជំទាស់របស់ខ្ញុំ គឺផ្អែកទៅលើមូលដ្ឋាន ដែលថាវាមិនពាក់ព័ន្ធ ដែលថាលើកយកមតិរបស់សហព្រះរាជអាជ្ញាទៅលើសក្ខីកម្មរបស់សាក្សីនៅក្នុងការជំនុំជម្រះខ្លួនគាត់។ ពីព្រោះថា អ្វីដែលលើកឡើងហ្នឹង គឺថាបានលើកហើយ។ ហើយនៅពេលដែលយើងចោទសួរសាក្សីទៅលើមតិយោបល់ ឲ្យនិយាយអំពីគំនិត ឬក៏មតិរបស់ ក.ស.ព ហ្នឹង គឺវាមិនពាក់ព័ន្ធនឹងមូលដ្ឋានទាំងអស់នេះទេ។ ហើយក្នុងន័យជាមួយគ្នាហ្នឹង ក៏យើងមិនអាចឲ្យសាក្សីគាត់ផ្តល់មតិយោបល់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះ ឬក៏ទៅលើអ្វីនោះឡើយ។ ដូច្នេះហើយ យើងគួរតែលើកយកអំពីហេតុ ដោយមិនតម្រូវឲ្យសាក្សីគាត់ឆ្លើយ ថាតើគាត់យល់យ៉ាងម៉េចដែរ ចំពោះទស្សនៈ ឬក៏គំនិតរបស់អ្នកដទៃ?

[១៥:៥៨:៥៤]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមជម្រាប សូមរំឭកដល់លោកសហព្រះរាជអាជ្ញាថា កាលសប្តាហ៍មុន គាត់លើកយកនូវឧទាហរណ៍មួយ ហើយខ្ញុំសូមដកស្រង់នូវឧទាហរណ៍នេះ គឺកថាខណ្ឌ៨២ កថាខណ្ឌ១៧២ កថាខណ្ឌ១១៩ និងកថាខណ្ឌ--

**អ្នកបកប្រែ៖**

លោកប្រធាន ស្នើសុំឲ្យលោកមេធាវីគាត់អានដោយយឺតៗបន្តិច។

**ប្រធានអង្គជំនុំ៖**

មេធាវីអានកថាខណ្ឌឡើងវិញ ព្រោះកថាខណ្ឌទាំងអស់ហ្នឹង អ្នកបកប្រែស្ដាប់អត់បានទេ។ លោកនិយាយ ៗតែម្នាក់ឯងទេ អ្នកស្ដាប់ខ្មែរ ស្ដាប់អត់បានទេ ពីព្រោះអត់មានការបកប្រែភាសាទេ។ ហើយទំនងអាចភាសាបារាំង ក៏មានបញ្ហាដែរ។

[១៥:៥៩:៣៨]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមអភ័យទោស។ ព្រះរាជអាជ្ញានៅក្នុងសេចក្ដីសន្និដ្ឋានចុងក្រោយ បាននិយាយថា ខ្លួនជឿជាក់ថា ឌុច មិនគួរឲ្យទុកចិត្តបាននោះឡើយ។ នៅក្នុងកថាខណ្ឌ១៨២, ១៧៦, ១៩៩, ២២០, ៤២៥, ៤២៦, ៤៣៣, ៤៤០ ព្រមទាំងកថាខណ្ឌ៤៨២។ នេះគឺជាកថាខណ្ឌជាក់លាក់ដែលព្រះរាជអាជ្ញាបានឮដូច្នេះ។ ក្នុងនាមជាមន្ត្រីរបស់តុលាការ ដូច្នេះខ្ញុំគិតថា ពួកគាត់យល់ឃើញថានៅពេលដែល ឌុច ផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿងរបស់គាត់ គឺ ឌុច គ្មានភាពស្មោះត្រង់ គឺមិនអាចជឿជាក់បាន។ ដូច្នេះហើយ យើងត្រូវឲ្យមានការបង្ហាញជាក់លាក់។ ឥឡូវនេះ ខ្ញុំសូមលើកនូវចំណុចជាក់លាក់--

[១៦:០១:០១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

ខ្ញុំគិតថា មេធាវីគួរតែលើកអំពីអង្គហេតុតែប៉ុណ្ណោះ ដោយមិនត្រូវលើកយកមតិ ឬក៏យោបល់របស់អ្នកដទៃមកពិភាក្សានោះឡើយ។ ខ្ញុំសូមស្នើប៉ុណ្ណោះ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំគិតថា ឥឡូវម៉ោងបួនហើយ។ ដូច្នេះ ខ្ញុំស្នើសុំត្រឹមតែប្រាំ ឬក៏ដប់នាទីបន្ថែមទៀតទេ ហើយខ្ញុំអាចនឹងចោទសួរនូវសំណួរចុងក្រោយ ឬមួយក៏ខ្ញុំអាចបន្តទៅស្អែកព្រឹក។ ប្រសិនបើមិនដូច្នេះទេ ខ្ញុំសូមតែមួយ ឬក៏ពីរសំណួរ។

[១៦:០១:៤៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០២:២៥]

**ប្រធានអង្គជំនុំ៖**

សូមប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ដើម្បីឆ្លើយតបទៅនឹងសេចក្តីជំទាស់រវាងភាគីអម្បាញ់មិញនេះលើការតាំងសំណួរ ហើយនិងណែនាំរបៀបសួរតាំងសំណួរចុងក្រោយ ដោយសារអង្គជំនុំជម្រះអនុញ្ញាតពេលវេលាបន្ថែមឲ្យការសួរដេញដោលរបស់ក្រុមមេធាវីការពារក្តី អៀង សារី ហ្នឹងធ្វើបានចប់នៅរសៀលនេះ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សម្រេចថាការជំទាស់របស់ខាងសហព្រះរាជអាជ្ញាមានសុពលភាព។ មេធាវីការពារក្តី អៀង សារី គួរតែយល់អំពីមូលដ្ឋានត្រង់ចំណុចដែលថា សុំឲ្យផ្តល់យោបល់ទៅលើទស្សនៈ ឬក៏សេចក្តីសន្និដ្ឋានរបស់ចៅក្រមស៊ើបអង្កេតនិងរបស់អង្គជំនុំជម្រះសាលាដំបូង។

លោកអាចលើកការចោទប្រកាន់ទាំងអស់នេះ នៅចំពោះមុខតែម្តង ហើយយើងមានកថាខណ្ឌដែលបានរៀបរាប់ទៅលើចំណុចហ្នឹងហើយ។ លោកអាចលើកជាឧទាហរណ៍មួយ ឬក៏ពីរដោយសង្ខេប។

[១៦:០៣:៣៩]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកស្រីចៅក្រម។ ខ្ញុំដឹងថា ពេញមួយថ្ងៃហើយ យើងប្រាកដជាហត់ទាំងអស់គ្នា។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ប្រសិនបើយើងចូលមើលកថាខណ្ឌ៤២៥ គឺឯកសារ E78។ ខ្ញុំសូមសួរដូច្នេះ លោក ឌុច តើត្រឹមត្រូវដែរឬទេ បើសិនជាយើងនិយាយថានៅក្នុងឱកាសជាច្រើនក្នុងពេលសវនាការជំនុំជម្រះលើរូបលោក នៅពេលដែលគេលើកឡើងអំពីអំណាចផ្ទាល់របស់លោក ដែលលោកបានលើកឡើងផ្តល់សក្ខីកម្មគេចវេះ ឬក៏មិនជាក់លាក់ មិនច្បាស់លាស់។ ហើយចម្លើយរបស់លោកនិយាយនោះ គឺបង្កឲ្យមានការភ័ន្តច្រឡំ តើមែនដែរឬទេ? សូមលោកជួយឆ្លើយទៅលើសំណួរនេះ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ចម្លើយរបស់ខ្ញុំ ១ពុះពារជាអតិបរមា ដើម្បីស្មោះត្រង់នឹងសភាពការណ៍ពិត ដើម្បីស្មោះត្រង់នឹងសតិអារម្មណ៍របស់ខ្ញុំ។ ឯចំណែកការវិនិច្ឆ័យរបស់អ្នកផ្សេងទៀត

មកលើខ្ញុំ អាហ្នឹងជាសិទ្ធិរបស់គេ។ ចុងបញ្ចប់ អង្គជំនុំជម្រះជាអ្នកជម្រះសេចក្តី។ នេះវាជារឿងធម្មតា។ ហើយព្រឹត្តិការណ៍ដែលកើតឡើងនៅពេលនេះ មនុស្សជាតិទាំងមូលគេវាយតម្លៃយើងទាំងអស់ ទាំងខ្ញុំ ទាំងលោកមេធាវី ទាំងអីទាំងអស់។ មនុស្សជាតិជំនាន់នេះ និងមនុស្សជាតិជំនាន់ក្រោយ គេវិនិច្ឆ័យយើងណាកុំភ្លេច។ នេះខ្ញុំសូមទុកប៉ុណ្ណឹង។

[១៦:០៦:០៩]

**ស៖** តើលោកមានបដិសេធមិនឆ្លើយការពិតទាំងស្រុងដែរឬទេ?

**ឆ៖** ខ្ញុំជឿថាខ្ញុំគ្មានដែលបដិសេធមិនឆ្លើយការពិតទាំងស្រុងទេ។ ក៏ប៉ុន្តែអ្នកសួរនុ៎ង ដែលសន្មតថាជាការពិតនុ៎ង វាជាការពិតហើយឬនៅ? នេះជាបញ្ហាមួយដែលយើងមិនគួរលើកយកមកនិយាយទេ។ ឧត្តមគតិរបស់ខ្ញុំ គឺឆ្លើយការពិតទាំងស្រុង។

**ស៖** ខ្ញុំសូមសួរលើកឡើងសំណួរដែលចៅក្រមស៊ើបអង្កេតសួរទៅកាន់លោក ហើយសំណួរដែលសហព្រះរាជអាជ្ញាសួរទៅកាន់លោក។ តើលោកឆ្លើយការពិតដែរឬទេ ទៅនឹងសំណួរទាំងអស់នោះ?

**ឆ៖** សំណួរទាំងអស់ បើបូកទៅមិនដឹងជាប៉ុន្មានរយ? ហើយដល់លោកសួរអ៊ីចឹង ឲ្យខ្ញុំឆ្លើយមួយម៉ាត់យ៉ាងម៉េច? ខ្ញុំមិនឆ្លើយទេ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន លោក លោកស្រីចៅក្រម ចំណុចនេះគឺបញ្ចប់ការដេញដោលរបស់ខ្ញុំហើយ។ ខ្ញុំព្យាយាមបង្រួមសំណួររបស់ខ្ញុំ ហើយខ្ញុំសង្ឃឹមថាពេលក្រោយទៀត ខ្ញុំមិនស្ថិតនៅក្នុងស្ថានភាពដូច្នេះនោះទេ ដែលខ្ញុំត្រូវសួរសំណួរច្របាច់ចូលគ្នាយ៉ាងច្រើន ដោយសារតែពេលវេលានៅពេលអនាគតយើងខ្ញុំគួរតែផ្តល់ឱកាសឲ្យបានច្រើនជាងនេះ។ នៅក្នុងករណីនេះ គឺយើងបានឆ្លងកាត់ និងជួបប្រទះនឹងដំណាក់កាលដែលយើងត្រូវធ្វើការឈប់សម្រាកសម្រាប់តុលាការ ដូច្នេះហើយគឺខ្ញុំសូមអធ្យាស្រ័យនៅពេលដែលខ្ញុំសួរសំណួរច្របាច់ចូលគ្នាយ៉ាងច្រើន។ ហើយខ្ញុំសូមអរគុណលោកសាក្សី ចំពោះការដែលខ្ញុំសួរសំណួរមួយចំនួនទៅកាន់លោក។ សូមអរគុណ ។

[១៦:០៨:២០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ នូវការកត់សម្គាល់នេះ ប៉ុន្តែអង្គជំនុំជម្រះសូមរំឭកភាគីថា ការប្រមើលមើល៍ និង

ការប៉ាន់ស្មានពេលវេលាអង្គជំនុំជម្រះបានស្តាប់នូវសំណូមពរ និងសំណើសុំការប៉ាន់ស្មានពេលវេលាពីភាគីនានា តាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងដែលបានតែងតែជួបប្រជុំពិភាក្សាគ្នាជាមួយនឹងភាគីនូវរាល់ថ្ងៃសុក្រ។ ដូច្នេះការប៉ាន់ស្មាន ការបែងចែកពេលវេលា គឺអង្គជំនុំជម្រះប្រឹងប្រែងគឺគោរព និងអនុវត្តទៅតាមសំណើសុំរបស់ភាគី។ ដូចអម្បាញ់មិញអ៊ីចឹងគឺថាមានការបន្ថែម គឺយើងបានព្យាយាមខ្លះនៅក្នុងការបន្ថែមដើម្បីពិនិត្យមូលហេតុ គឺចាំបាច់នៃការតាំងសំណួរឲ្យអស់ពីលទ្ធភាព។ អ៊ីចឹងថ្ងៃក្រោយបើសិនជាមានបញ្ហាអី គឺសូមគណនាពេលវេលាឲ្យបានត្រឹមត្រូវ។

ទន្ទឹមនឹងនេះផងដែរ អង្គជំនុំជម្រះក៏សូមរំឭកដែរ គួរតែត្រូវបានចៀសវាងផងដែរនូវការស្នើសុំពេលវេលាវែង។ ស្រាប់តែដល់ពេលតាំងសំណួរអត់មានសំណួរសួរ។ វាមិនត្រឹមតែទៅជាការរំខានដល់ការរៀបចំកម្មវិធីសវនាការរបស់តុលាការទេ វាទៅដល់នាំឲ្យបាត់បង់ពេលវេលានៅក្នុងកិច្ចប្រឹងប្រែងដើម្បីបង្រួញនៅក្នុងកិច្ចដំណើរការសវនាការដេញដោល ដែលកំណត់ឡើងដោយអង្គជំនុំជម្រះហ្នឹងផងដែរ។ អង្គជំនុំជម្រះរំឭកហើយថា គោលការណ៍នៃការយុត្តិធម៌ គឺដំណើរការក្តីឆាប់រហ័សមួយផងដែរដែលគាំទ្រជាធាតុផ្សំនៃដំណើរការយុត្តិធម៌នោះ។

[១៦:០៩:៥៨]

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

វាជាបញ្ហាខ្លីទេ ពាក់ព័ន្ធទៅនឹងចំណុច ដែលភាគីធ្វើការលើកបង្ហាញរឿងក្តីរបស់ខ្លួនជូនទៅកាន់សាក្សី។ យើងដឹងហើយអង្គជំនុំជម្រះបង្គាប់ថា យើងមិនអនុវត្តតាមការអនុវត្តរបស់តុលាការយូហ្គោស្លាវី រួមទាំងតុលាការអន្តរជាតិនានាផងនោះទេ។ អ្វីដែលមេធាវីការពារក្តី អៀង សារី បានលើកឡើងនោះគឺ ថាខ្លឹមសារ ដែលបានលើកឡើងយកមកសួរវាផ្ទុយទៅនឹងការផ្តល់សក្ខីកម្មរបស់សាក្សី។ ចំណុចទាំងអស់នោះ គួរតែលើកឡើងសួរទៅកាន់សាក្សី ថាតើសាក្សីឯកភាព ឬក៏មិនឯកភាព ចំពោះភស្តុតាងដែលសាក្សីរូបនេះ លើកឡើងផ្តល់ជូននោះ។ បញ្ហាចោទ ដែលខ្ញុំសុំឲ្យមេធាវីការពារក្តី អៀង សារី នៅថ្ងៃស្អែក ឬក៏ថ្ងៃណានោះ គឺលើបញ្ហាទាំងអស់នេះ។

[១៦:១១:០៦]

ប្រសិនបើមេធាវីការពារក្តី មិនជឿថា វាជាគោលការណ៍អនុវត្ត វិធានអង្គភាព ដើម្បីចាប់ខ្លួនក្នុងរយៈកាល-- រយៈពេលវេលានោះទេ គឺការធ្វើដូច្នោះនៅសម័យនោះ ដើម្បីឲ្យប្រធាននៃអង្គភាពទាំងអស់

នោះ ដឹងអំពីការចាប់ខ្លួន។ ប្រសិនបើមេធាវីមិនជឿទៅលើចំណុចនេះ ខ្ញុំនឹងអាចសុំឲ្យមេធាវីការពារក្តីនោះសួរសំណួរនេះទៅកាន់សាក្សី ហើយសាក្សីប្រាកដជាឆ្លើយអំពីអង្គហេតុពាក់ព័ន្ធទៅនឹងការចាប់ខ្លួននៅក្នុងអង្គភាព ដែលការចាប់ខ្លួនទាំងអស់នោះ បានជូនដំណឹងទៅដល់លោក អៀង សារី។ នេះហើយជាគោលការណ៍អនុវត្ត ដែលគេធ្លាប់ធ្វើការនៅក្នុងអំឡុងពេលនោះ។ ដូច្នេះប្រសិនបើមិនជឿនោះទេ យើងខ្ញុំសូមឲ្យមេធាវីការពារក្តី សួរសំណួរបែបនេះទៅកាន់សាក្សីនៅថ្ងៃស្អែក ឬក៏ខានស្អែក។

អង្គជំនុំជម្រះបានណែនាំរួចទៅហើយ ដែលថា សហព្រះរាជអាជ្ញាជាអ្នកធ្វើការបង្ហាញរឿងក្តីឲ្យបានជឿជាក់នៅដំណាក់កាលចុងក្រោយនៃរឿងក្តី។

[១៦:១២:១៥]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមផ្តល់ការឆ្លើយតប គឺចំណុចទីមួយ គឺថា យើងខ្ញុំជំទាស់ចំពោះការដែលបង្គាប់ឲ្យយើងសួរសាក្សីបែបនេះ គឺខ្ញុំជំទាស់។ ការដែលលើកឡើងដូច្នេះ គឺជាការសន្និដ្ឋានបិទការចោទប្រកាន់ ដែលមិនត្រូវធ្វើឡើងនៅក្នុងនេះទេ។ នៅពេលនេះ សហព្រះរាជអាជ្ញា សុំឲ្យខ្ញុំនេះទៅគិតមួយយប់ឡើងវិញ ឲ្យសាក្សីរូបនេះ ទៅផ្ទះគិតទៅ-- ត្រឡប់ទៅវិញគិតឡើងវិញ ដើម្បីមកឆ្លើយ។ ដូច្នេះការសុំឲ្យយើងធ្វើដូច្នេះមិនត្រឹមត្រូវនោះទេ។ យើងមេធាវី យើងខ្ញុំមានសិទ្ធិសម្រេចទៅលើនីតិវិធី ដែលវាសមស្របសម្រាប់យើងខ្ញុំថា តើបើសិនជាខ្ញុំមិនពេញចិត្តទៅលើ អាយ.ស៊ី.ធី.វ៉ាយ ខ្ញុំយករបស់តុលាការបារាំង ប្រសិនបើមិនប្រើតាមតុលាការបារាំង ខ្ញុំទៅយកតុលាការមួយទៀត ដែលជាយុត្តិសាស្ត្រយកមកអនុវត្ត។

ដូច្នេះ វាក៏ដូចនឹងសហព្រះរាជអាជ្ញាដែរ ដែលសហព្រះរាជអាជ្ញាអាចធ្វើដូច្នេះដែរ។ គាត់អាចជ្រើសរើសអនុវត្តដូច្នេះបាន។ ខ្ញុំសូមជំទាស់ទៅលើការលើកឡើងរបស់សហព្រះរាជអាជ្ញាបែបនេះ នៅចំពោះមុខសាក្សី។ មុខនៅ-- មុនពេលភាគីដែលនៅសល់ដេញដោលទៅលើសាក្សីរូបនេះ ការលើកដូច្នេះមិនសមរម្យនោះទេ។ ខ្ញុំមិនចាំបាច់មានការណែនាំពីសហព្រះរាជអាជ្ញា ឬក៏អង្គជំនុំជម្រះនោះទេ។ ជាការពិត ខ្ញុំសុំរយៈពេលពីរថ្ងៃឯណោះ ហើយខ្ញុំសុំរយៈពេលដប់នាទីបន្ថែមទៀត ខ្ញុំព្យាយាមសម្រួលទៅដល់ក្រុមផ្សេងរួចហើយ។ ដូច្នេះហើយ ប្រសិនបើខ្ញុំទទួលទណ្ឌកម្មចំពោះការជួយសម្រួលទៅដល់ក្រុមភាគីផ្សេងនោះ ខ្ញុំនឹង-- ថ្ងៃក្រោយខ្ញុំមិនចែកពេលវេលាទៅឲ្យភាគីផ្សេងនោះទេ គឺខ្ញុំនឹងយកពេលវេលាហ្នឹងទាំងអស់តែម្តង។ ហើយការលើកឡើងរបស់សហព្រះរាជអាជ្ញា គឺមិនត្រឹមត្រូវនោះទេ។ ខ្ញុំព្យាយាមសុំរយៈពេលពីរថ្ងៃការដេញដោលសំណួរ ក៏ប៉ុន្តែអ្វីដែលខ្ញុំទទួលបាន តែមួយថ្ងៃតែប៉ុណ្ណោះ

ហើយពេលវេលាបន្ថែម ដែលខ្ញុំទទួលបានតែដប់នាទីតែប៉ុណ្ណោះ។ ដូច្នេះការលើកឡើងរបស់សហព្រះរាជអាជ្ញា គឺមិនសមរម្យនោះទេ។

[១៦:១៤:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១៥:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណដល់មេធាវីដែលបានសួរដេញដោលពេញមួយថ្ងៃនេះ ហើយអរគុណសាក្សីដែលបានខិតខំប្រឹងប្រែងជាច្រើនថ្ងៃ នៅក្នុងការផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ឥឡូវនេះពេលវេលាសមលម្មនឹងសម្រាកហើយសម្រាប់ថ្ងៃនេះ។ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ ដោយថ្ងៃស្អែកគឺដល់ពេលវេលា ដែលត្រូវអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោល ចំពោះសាក្សីឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច។ អនុរក្សមន្ទីរឃុំឃាំងឲ្យនាំសាក្សីទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យអញ្ជើញគាត់មកកាន់បន្ទប់សវនាការ កន្លែងផ្ដល់សក្ខីកម្មនេះនៅព្រឹកថ្ងៃស្អែកត្រឹមម៉ោងប្រាំបួន។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំខ្លួនពួកគាត់មកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១៧ នាទី)*